**ធនាគារជាតិ នៃ កម្ពុជា**

ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.



# របាយការណ៍ ប្រចាំឆ្នាំ ២០២០





# មាតិកា

* * *

**អារម្ភកថា**.................................................... i
**អក្សរកាត់**.................................................... v
**ខ្លឹមសារសង្ខេប**.................................................... ix
**ផ្នែកទី១ - របាយការណ៍ប្រចាំឆ្នាំ២០២០**
I- **ស្ថានភាពសេដ្ឋកិច្ចពិភពលោក**.................................................... ១
II- **ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា**.................................................... ៥
១- កំណើនសេដ្ឋកិច្ច.................................................... ៥
២- ស្ថានភាពអតិផរណា.................................................... ៨
៣- អត្រាប្តូរប្រាក់.................................................... ១០
៤- ស្ថានភាពជញ្ជីងទូទាត់.................................................... ១១
៥- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ.................................................... ១៣
III- **ការគ្រប់គ្រងរូបិយវត្ថុ**.................................................... ១៤
១- ស្ថានភាពរូបិយវត្ថុ.................................................... ១៤
២- ការអនុវត្តគោលនយោបាយរូបិយវត្ថុ.................................................... ១៥
IV- **ស្ថានភាពប្រព័ន្ធធនាគារនៅកម្ពុជា**.................................................... ២០
១- ស្ថានភាពទូទៅ.................................................... ២០
២- វិស័យធនាគារ.................................................... ២១
៣- វិស័យមីក្រូហិរញ្ញវត្ថុ.................................................... ២២
៤- វិស័យភតិសន្យាហិរញ្ញវត្ថុ.................................................... ២៣
៥- គ្រឹះស្ថានឥណទានជនបទ.................................................... ២៤
៦- ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុ.................................................... ២៤
៧- ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន.................................................... ២៥
៨- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ.................................................... ២៥
៩- បរិយាបន្នហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន.................................................... ២៧
១០- វឌ្ឍនភាពការងារផ្សេងៗ.................................................... ២៩
V- **ការផ្តត់ផ្គង់សេវាធនាគារកណ្តាល**.................................................... ៣០
១- ប្រព័ន្ធទូទាត់សងប្រាក់.................................................... ៣០
២- ប្រតិបត្តិការប្រព័ន្ធទូទាត់សងប្រាក់.................................................... ៣១
៣- ការគ្រប់គ្រងចរាចរណ៍ធនប័ត្រ.................................................... ៣៣
VI- **ការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម**.................................................... ៣៤
១- ការរាយការណ៍ប្រតិបត្តិការរបស់បុគ្គលរាយការណ៍.................................................... ៣៤
២- ការពង្រឹងក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ និងការអនុវត្តកាតព្វកិច្ចនិងការយល់ដឹងរបស់បុគ្គលរាយការណ៍.................................................... ៣៥

៣- ការពង្រឹងក្របខ័ណ្ឌស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម........... ៣៥
៤- កិច្ចសហប្រតិបត្តិការ ........................................................................ ៣៦
VII- **កិច្ចសហប្រតិបត្តិការអន្តរជាតិ**........................................................ ៣៧
១ -កិច្ចសហប្រតិបត្តិការពហុភាគី.............................................................. ៣៧
២ -កិច្ចសហប្រតិបត្តិការទ្វេភាគី ............................................................... ៣៩
VIII- **ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា**.............................................. ៣៩
១- សមាសភាព និងសកម្មភាពក្រុមប្រឹក្សាភិបាល.............................................. ៣៩
២- ការអភិវឌ្ឍធនធានមនុស្ស .................................................................. ៤០
៣- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងគ្រប់គ្រងហានិភ័យ...................................... ៤២
៤- ការគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា.................................................. ៤៣
**សន្និដ្ឋាន** ........................................................................................ ៤៤
**ផ្នែកទី២ - ទស្សនវិស័យ និងទិសដៅការងារឆ្នាំ២០២១**
១- ការអនុវត្តគោលនយោបាយរូបិយវត្ថុ....................................................... ៤៨
២- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ .......................................................... ៤៨
៣- ការអភិវឌ្ឍប្រព័ន្ធទូទាត់ .................................................................... ៤៨
៤- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ............................................ ៤៨
៥- ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម .................................. ៤៩
៦- ការងារប្រតិបត្តិការ ........................................................................... ៥០
៧- ការបោះផ្សាយនិងឃ្លាំងបេឡា ............................................................. ៥០
៨- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងគ្រប់គ្រងហានិភ័យ...................................... ៥០
៩ - ការគ្រប់គ្រងសាខា ............................................................................ ៥០
១០- គណនេយ្យ .................................................................................... ៥០
១១-ការគ្រប់គ្រង និងបណ្តុះបណ្តាល ........................................................... ៥១
១២-កិច្ចសហប្រតិបត្តិការអន្តរជាតិ ............................................................. ៥១
១៣-ការស្រាវជ្រាវ និងវិភាគសេដ្ឋកិច្ច........................................................... ៥២
១៤ -ការងារស្ថិតិ ................................................................................... ៥២
**ផ្នែកទី៣ - ឧបសម្ព័ន្ធ**
ឧបសម្ព័ន្ធ ១ តារាង ១- ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងសេវា ........................ ៥៣
ឧបសម្ព័ន្ធ ២ តារាង ២ -ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ (អត្រាទិញចុងខែ)....... ៥៤
ឧបសម្ព័ន្ធ ៣ តារាង ៣- ស្ថិតិស្ថានភាពធនាគារកណ្តាល(ប៊ីលានរៀល) ............................ ៥៥
ឧបសម្ព័ន្ធ ៤ តារាង ៤ -ស្ថិតិស្ថានភាពគ្រឹះស្ថានទទួលប្រាក់បញ្ញើផ្សេងទៀត .................. ៥៦
ឧបសម្ព័ន្ធ ៥ តារាង ៥- ស្ថិតិស្ថានភាពគ្រឹះស្ថានទទួលប្រាក់បញ្ញើ ................................. ៥៧
ឧបសម្ព័ន្ធ ៦ តារាង ៦- ស្ថិតិស្ថានភាពគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ............................ ៥៨
ឧបសម្ព័ន្ធ ៧ តារាង ៧- ស្ថិតិស្ថានភាពគ្រឹះស្ថានហិរញ្ញវត្ថុ........................................... ៥៩

ឧបសម្ព័ន្ធ ៨ តារាង ៨- ឥណទានតាមប្រភេទជំនួញក្នុងវិស័យសេដ្ឋកិច្ច ..........................៦០
ឧបសម្ព័ន្ធ ៩ តារាង ៩- សរុបប្រតិបត្តិការប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ ......................៦១
ឧបសម្ព័ន្ធ ១០ តារាង ១០- ជញ្ជីងទូទាត់ប្រទេសកម្ពុជា ....................................................៦២
ឧបសម្ព័ន្ធ ១១ តារាង ១១- បណ្ដាញព័ត៌មានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុពីឆ្នាំ២០១៥-កញ្ញា ២០២០ ..........................................................................................៦៣

# អារម្ភកថា

ពិភពលោកកំពុងឆ្លងកាត់វិបត្តិសុខភាព ដែលបណ្តាលឱ្យសេដ្ឋកិច្ចធ្លាក់ចូលទៅក្នុងវិបត្តិធ្ងន់ធ្ងរ ចាប់តាំងពីមហាវិបត្តិសេដ្ឋកិច្ចនៅទសវត្សរ៍ឆ្នាំ១៩៣០ (The Great Depression)។ វិបត្តិជំងឺកូវីដ-១៩ បានផ្លាស់ប្តូររបៀបនៃការរស់នៅ ទំនាក់ទំនង និងដំណើរការសេដ្ឋកិច្ច ហើយបាននាំទៅរកប្រក្រតីថ្មី ដែលក្នុងនោះការប្រើប្រាស់បច្ចេកវិទ្យាទទួលបានការពេញនិយមនិងអាចក្លាយជាប្រភពកំណើនសក្តានុពលថ្មីសម្រាប់សេដ្ឋកិច្ច។ ប្រឈមនឹងវិបត្តិនេះ ប្រទេសនានាទាំងអភិវឌ្ឍន៍និងកំពុងលូតលាស់បានអនុវត្តគោលនយោបាយសារពើពន្ធនិងរូបិយវត្ថុវិត្ថារកម្មជាមួយនឹងវិធានការគាំពារដើម្បីរក្សាលំនឹងសេដ្ឋកិច្ច-សង្គម។ មូលនិធិរូបិយវត្ថុអន្តរជាតិបានគាំទ្រការអនុវត្តគោលនយោបាយទាំងនេះ ដោយផ្អែកលើលទ្ធភាពនិងស្ថានភាពនៃប្រទេសនីមួយៗ ព្រោះការអូសបន្លាយនៃជំងឺកូវីដ-១៩និងការអនុវត្តគោលនយោបាយទាំងនេះ អាចបង្កើនភាពមិនប្រាកដប្រជាដែលបង្កជាហានិភ័យ ដូចជាការគរពូនខ្ពស់នៃបំណុលរដ្ឋ ក្រុមហ៊ុន-សហគ្រាសនិងគ្រួសារ និងហានិភ័យចិត្តសាស្ត្រ (moral hazard)។ បញ្ហាទាំងនេះត្រូវបានចាត់ទុកថាជាបញ្ហាប្រឈមចម្បងដែលត្រូវដោះស្រាយចំពោះប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍។

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយទស្សនវិស័យវែងឆ្ងាយនិងម៉ឺងម៉ាត់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានទប់ស្កាត់ការឆ្លងនិងការរីករាលដាលនៃជំងឺកូវីដ-១៩យ៉ាងមានប្រសិទ្ធភាព ហើយកម្ពុជាត្រូវបានមជ្ឈដ្ឋានកម្ពុជាដែលមានភាពបើកទូលាយ មិនអាចគេចផុតពីឥទ្ធិពលអវិជ្ជមាននៃវិបត្តិនេះបានទេ ជាពិសេសវិស័យទេសចរណ៍ ការនាំចេញផលិតផលសម្លៀកបំពាក់និងស្បែកជើង និងវិស័យសំណង់និងអចលនទ្រព្យ។ ទោះយ៉ាងណា ដោយសារកំណើននៃវិស័យកសិកម្មនិងធនាគារ ជាមួយនឹងការកើនឡើងនៃការនាំចេញផលិតផលមួយចំនួនដែលជាលទ្ធផលនៃការធ្វើពិពិធកម្មកន្លងមក សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងធ្លាក់ចុះត្រឹមប្រមាណ -១,៩% នៅឆ្នាំ២០២០។

ទន្ទឹមនឹងការគ្រប់គ្រងបានល្អលើការរីករាលដាលនៃជំងឺកូវីដ-១៩ ជំនឿទុកចិត្តមកលើសេដ្ឋកិច្ចកម្ពុជាក៏ត្រូវបានគាំទ្រផងដែរដោយស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ គោលនយោបាយរូបិយវត្ថុត្រូវបានអនុវត្តដោយមានភាពបត់បែនដើម្បីរួមចំណែកគ្រប់គ្រងសម្ពាធអតិផរណា ហើយធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ដើម្បីរក្សាស្ថិរភាពតម្លៃប្រាក់រៀល ខណៈដែលរូបិយប័ណ្ណក្នុងតំបន់ប្រឈមនឹងការប្រែប្រួលខ្លាំង។ លើសពីនេះ កម្រិតខ្ពស់នៃទុនបម្រុងអន្តរជាតិបានរួមចំណែកយ៉ាងសំខាន់ក្នុងការអនុវត្តគោលនយោបាយទាំងនេះប្រកបដោយប្រសិទ្ធភាព។

ឈរលើបន្ទាត់គោលនយោបាយរបស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជាបានដាក់ចេញគោលនយោបាយរូបិយវត្ថុវិត្ថារកម្មនិងវិធានការម៉ាក្រូប្រុងប្រយ័ត្ន សំដៅបង្កើនសន្ទនីយភាពនៅក្នុងប្រព័ន្ធធនាគារ និងលើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបន្តផ្តល់ឥណទានដល់វិស័យអាទិភាពនិងផ្តល់ការអនុគ្រោះដល់ប្រជាជនក្រីក្រដែលរងផលប៉ះពាល់តាមរយៈការរៀបចំឥណទានឡើងវិញ។ ប្រសិទ្ធភាពនៃគោលនយោបាយទាំងនេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈការបន្តមានកំណើនឥណទាន, កម្រិតទាបនៃឥណទានមិនដំណើរការ និងនិន្នាការថយចុះនៃចំនួនគណនីក៏ដូចជាទឹកប្រាក់នៃ

ឥណទានរៀបចំឡើងវិញ។ គួររំលេចថា គោលនយោបាយរូបិយវត្ថុអាចមានលទ្ធភាពបន្ថែមទៀត ក្នុងការស្តារនិងជំរុញសកម្មភាពសេដ្ឋកិច្ច ដូចជា ការកាត់បន្ថយអត្រាការប្រាក់នៅលើទីផ្សារ, ការចាក់បញ្ចូលសាច់ប្រាក់នៅក្នុងសេដ្ឋកិច្ច និងការទិញមូលបត្ររដ្ឋ នៅពេលដែលប្រាក់រៀលត្រូវបានប្រើប្រាស់ទូលំទូលាយ និងមានវត្តមានមូលបត្ររដ្ឋ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាបានគាំទ្ររាជរដ្ឋាភិបាលក្នុងការរៀបចំក្របខ័ណ្ឌនិងយន្តការបោះផ្សាយមូលបត្ររដ្ឋ និងជំរុញការប្រើប្រាស់ប្រាក់រៀលដែលមានកម្រិតទាបនៅឡើយ ដែលនឹងអនុញ្ញាតឱ្យរាជរដ្ឋាភិបាលទទួលបានហិរញ្ញប្បទានរយៈពេលវែងបន្ថែមទៀតនិងផ្តល់លទ្ធភាពដល់ធនាគារជាតិនៃកម្ពុជាក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុកាន់តែមានប្រសិទ្ធភាពផ្អែកលើយន្តការទីផ្សារ។

ស្របតាមនិន្នាការថ្មីនៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលឱ្យក្លាយជាប្រភពកំណើនថ្មីមួយ ធនាគារជាតិនៃកម្ពុជាបានចាត់ទុកបច្ចេកវិទ្យាហិរញ្ញវត្ថុនិងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់ ជាគោលដៅចម្បងមួយនៃការអភិវឌ្ឍប្រព័ន្ធធនាគារ។ ក្នុងទិសដៅនេះ ប្រព័ន្ធទូទាត់ទាំងក្នុងស្រុកនិងតំបន់ត្រូវបានអភិវឌ្ឍនិងពង្រីកវិសាលភាពជាលំដាប់ សំដៅសម្រួលប្រតិបត្តិការដោះដូរ ការវិនិយោគ និងពាណិជ្ជកម្មអន្តរជាតិ ជាពិសេសក្នុងបរិការណ៍នៃការរក្សាគម្លាតសង្គម និងការរឹតត្បិតនៃការធ្វើដំណើរឆ្លងប្រទេស។ ក្នុងចំណោមប្រព័ន្ធទូទាត់ដែលបានដាក់ឱ្យប្រើប្រាស់ ប្រព័ន្ធបាគងដែលប្រើប្រាស់បច្ចេកវិទ្យាប្លុកឆេន (Blockchain) ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ហើយត្រូវបានអន្តរជាតិទទួលស្គាល់ថា ជាប្រព័ន្ធទូទាត់មួយដែលប្រើប្រាស់បច្ចេកវិទ្យាចុងក្រោយនៅលើពិភពលោក។ ប្រព័ន្ធបាគងក៏នឹងក្លាយជាប្រព័ន្ធទូទាត់កន្លោងមួយសម្រួលដល់ការផ្ទេរប្រាក់និងទូទាត់សងប្រាក់ជាមួយគ្រប់គ្រឹះស្ថាននិងប្រតិបត្តិករដែលផ្តល់សេវាទូទាត់។ ទោះយ៉ាងណា ការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗទាមទារឱ្យមានការប្រុងប្រយ័ត្នខ្ពស់ទាំងចំពោះគ្រឹះស្ថានផ្តល់សេវាហិរញ្ញវត្ថុនិងអតិថិជន ដើម្បីចៀសវាងពីហានិភ័យនានា ជាពិសេសឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា (cybercrime)។

ជាមួយគ្នានេះ កម្ពុជាបានពង្រឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដើម្បីរួមចំណែកអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងសេដ្ឋកិច្ចកម្ពុជា ជាពិសេសក្នុងដំណាក់កាលនៃការរីករាលដាលនៃជំងឺកូវីដ-១៩។ ការពង្រឹងសកម្មភាពទាំងនេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈការកែលម្អក្របខ័ណ្ឌគតិយុត្តដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្ត និងការពង្រីកវិសាលភាពនៃសហប្រតិបត្តិការជាមួយអាជ្ញាធរនិងភាគីពាក់ព័ន្ធទាំងក្នុងស្រុកនិងអន្តរជាតិ។ ទោះយ៉ាងណា ការយល់ដឹងរបស់បុគ្គលរាយការណ៍នៅតែមានភាពចាំបាច់ដែលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបាននិងកំពុងលើកកម្ពស់ជាប្រចាំដើម្បីបង្ការ ទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មឱ្យបានទាន់ពេលវេលានិងមានប្រសិទ្ធភាព។

គួររំលេចថា ការអូសបន្លាយនៃជំងឺកូវីដ-១៩ បាននាំឱ្យចំណូលរបស់ប្រជាជនថយចុះ ដែលអាចបង្កើនតម្រូវការខ្ចី ហើយកត្តានេះអាចបណ្តាលឱ្យការប្រើប្រាស់សេវាហិរញ្ញវត្ថុក្រៅផ្លូវការកើនឡើងផងដែរ។ ឆ្លើយតបនឹងបញ្ហានេះ ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់យ៉ាងប្រុងប្រយ័ត្ន, ទទួលមតិសាធារណជនលើការប្រើប្រាស់សេវាហិរញ្ញវត្ថុ, លើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុរបស់សាធារណជន, ពង្រឹងកិច្ចគាំពារអតិថិជន និងបង្កើនគុណភាពនិងតម្លាភាពនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។ លើសពីនេះ អង្គភាពការពារប្រាក់បញ្ញើនិងក្របខ័ណ្ឌដំណោះស្រាយគ្រឹះស្ថានធនាគារ

និងហិរញ្ញវត្ថុត្រូវបានបង្កើតឡើង ដើម្បីរៀបចំក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្កើតប្រព័ន្ធការពារប្រាក់បញ្ញើ និងក្របខ័ណ្ឌដំណោះស្រាយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សំដៅពង្រឹងជំនឿទុកចិត្តលើប្រព័ន្ធធនាគារ។

នៅឆ្នាំ២០២១ខាងមុខ សេដ្ឋកិច្ចពិភពលោកត្រូវបានព្យាករថានឹងមានភាពធូរស្រាលជាលំដាប់ដោយសារការរំពឹងទុកពីការប្រើប្រាស់វ៉ាក់សាំងដើម្បីបង្ការការឆ្លងជំងឺកូវីដ-១៩។ ប៉ុន្តែ ភាពមិនជាក់លាក់នៃការរំពឹងទុកនេះ គួបផ្សំនឹងបញ្ហាភូមិសាស្ត្រនយោបាយ ភាពតានតឹងផ្នែកពាណិជ្ជកម្មនិងបច្ចេកវិទ្យា (Trade tensions and technology frictions) និងការប្រែប្រួលអាកាសធាតុ បន្តធ្វើឱ្យទស្សនវិស័យសេដ្ឋកិច្ចពិភពលោកមានភាពមិនប្រាកដប្រជាខ្ពស់។ ក្នុងស្ថានភាពនេះ សេដ្ឋកិច្ចកម្ពុជាក៏រំពឹងថាងើបឡើង ដែលអាចគាំទ្រដោយកត្តាអំណោយផលមួយចំនួនរួមមាន៖ i/-ការកើនឡើងនៃការនាំចេញដែលគាំទ្រដោយប្រព័ន្ធអនុគ្រោះពន្ធដែលមានស្រាប់និងទើបទទួលបានថ្មីៗ ជាមួយនឹងកំណើនចំណូលរបស់ប្រទេសដែលជាគោលដៅនាំចេញ ii/-ការកើនឡើងវិញនៃការវិនិយោគពីប្រទេសក្នុងតំបន់ ជាពិសេសប្រទេសចិន ដែលសេដ្ឋកិច្ចបាននិងកំពុងងើបឡើងវិញយ៉ាងឆាប់រហ័ស iii/-ការកើនឡើងផលិតកម្មក្នុងវិស័យកសិកម្មដែលគាំទ្រដោយការ វិនិយោគលើអនុវិស័យកសិ-ឧស្សាហកម្ម iv/-កំណើនទេសចរណ៍ក្នុងស្រុកនិងកំណើនសន្សឹមៗនៃទេសចរណ៍អន្តរជាតិ v/-ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចដែលរួមចំណែកដោយស្ថិរភាពថ្លៃ អត្រាប្តូរប្រាក់និងកម្រិតខ្ពស់នៃទុនបម្រុងអន្តរជាតិ vi/-លទ្ធភាពខ្ពស់នៃវិស័យធនាគារក្នុងការឆ្លើយតបនឹងតម្រូវការហិរញ្ញប្បទានរបស់វិស័យឯកជនទាំងក្នុងពេលជួបវិបត្តិនិងពេលដែលសកម្មភាពសេដ្ឋកិច្ចងើបឡើងវិញ និង vii/-ការរក្សាបានស្ថិរភាពហិរញ្ញវត្ថុនិងជំនឿទុកចិត្តមកលើប្រព័ន្ធធនាគារ។ ទោះយ៉ាងណា ការងើបឡើងនៃសេដ្ឋកិច្ចកម្ពុជាក៏ប្រឈមនឹងហានិភ័យមួយចំនួនផងដែរ ដូចជា៖ i/-ការប្រឈមនឹងរលកថ្មីនៃជំងឺកូវីដ-១៩ ii/-កំណើនយឺតជាងការរំពឹងទុកក្នុងវិស័យទេសចរណ៍ iii/-ការកើនឡើងការប្រកួតប្រជែងក្នុងវិស័យនាំចេញផលិតផលកាត់ដេរសម្លៀកបំពាក់និងស្បែកជើង iv/-កំណើនបំណុលសាជីវកម្មនិងគ្រួសារដោយសារការធ្លាក់ចុះនៃចំណូល v/-ការថយល្បឿនកំណើនក្នុងវិស័យសំណង់និងអចលនទ្រព្យ និង vi/-ភាពមិនច្បាស់លាស់នៃការប្រែប្រួលអាកាសធាតុដែលអាចប៉ះពាល់ដល់វិស័យកសិកម្ម។ ទន្ទឹមនេះ កម្ពុជាក៏បន្តប្រឈមនឹងបញ្ហារចនាសម្ព័ន្ធមួយចំនួនផងដែររួមមាន ថ្លៃដើមផលិតកម្មនៅមានកម្រិតខ្ពស់ស្របពេលដែលផលិតភាពការងារនៅមានកម្រិតទាប និងការធ្វើពិពិធកម្មសេដ្ឋកិច្ចនៅមានល្បឿនយឺតនៅឡើយ។

ដើម្បីបន្តគាំទ្រដល់ការរក្សាលំនឹងសេដ្ឋកិច្ច-សង្គមនិងការស្តារឡើងវិញនៃសេដ្ឋកិច្ច ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជានឹងបន្តរួមចំណែក៖ i/-រក្សាស្ថិរភាពថ្លៃនិងអត្រាប្តូរប្រាក់ ii/-គរពូនទុនបម្រុងអន្តរជាតិឱ្យបានក្នុងកម្រិតគ្រប់គ្រាន់ iii/-ដាក់ចេញវិធានការម៉ាក្រូនិងមីក្រូប្រុងប្រយ័ត្នដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុ iv/-ធ្វើទំនើបកម្មប្រព័ន្ធទូទាត់និងហេដ្ឋារចនា-សម្ព័ន្ធផ្សេងទៀតដើម្បីគាំទ្រចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងការប្រែក្លាយសេដ្ឋកិច្ចកម្ពុជាទៅជាសេដ្ឋកិច្ចឌីជីថល v/-ជំរុញបរិយាបន្នហិរញ្ញវត្ថុនិងលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុដើម្បីគាំទ្រកំណើនប្រកបដោយបរិយាបន្ន និង vi/-លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលតាមយន្តការទីផ្សារនិងការអភិវឌ្ឍទីផ្សារអន្តរធនាគារដើម្បីបង្កើនប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ។ ម៉្យាងទៀត

ប្រព័ន្ធធនាគារកម្ពុជានឹងបន្តអនុវត្តគោលការណ៍ហិរញ្ញប្បទានបៃតងនិងប្រកបដោយចីរភាព ទាំងតាមរយៈការវិនិយោគនិងការផ្តល់ហិរញ្ញប្បទាន ដែលនឹងរួមចំណែកក្នុងការការពារបរិស្ថាននិងកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជានឹងបន្តបង្កើនសមាហរណកម្មវិស័យធនាគារនិងហិរញ្ញវត្ថុកម្ពុជាឱ្យកាន់តែស៊ីជម្រៅទៅក្នុងតំបន់, ពង្រឹងបណ្តាញសុវត្ថិភាពហិរញ្ញវត្ថុតំបន់, តភ្ជាប់ប្រព័ន្ធទូទាត់ជាមួយប្រទេសនានា និងគាំទ្រដល់គំនិតផ្តួចផ្តើមពង្រឹងកិច្ចសហប្រតិបត្តិការនានា ជាពិសេស គោលដៅរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC), ពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM) ក្នុងក្របខ័ណ្ឌអាស៊ាន+៣, កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយបណ្តាប្រទេសជាដៃគូនានា។ល។ ម៉្យាងទៀត អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជានឹងបន្តពង្រឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ក្នុងគោលដៅដំឡើងចំណាត់ថ្នាក់របស់កម្ពុជា។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាដែលតែងតែផ្តល់ការគាំទ្រ និងមន្ត្រីបុគ្គលិកគ្រប់ជាន់ថ្នាក់ដែលបានខិតខំបំពេញភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ សំដៅរួមគ្នាកសាងប្រព័ន្ធធនាគារឱ្យមានការអភិវឌ្ឍប្រកបដោយចីរភាព។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា ដែលបានផ្តល់កិច្ចសហប្រតិបត្តិការល្អនាពេលកន្លងមក។ ខ្ញុំជឿជាក់យ៉ាងមុតមាំថា សមាជិកក្រុមប្រឹក្សាភិបាល មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់និងភាគីពាក់ព័ន្ធនានា នឹងបន្តគាំទ្រនិងរួមចំណែកសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀតក្នុងវិស័យធនាគារ ដែលនឹងបម្រើជាប្រយោជន៍រួមសម្រាប់ជាតិមាតុភូមិនិងប្រជាជនកម្ពុជា។

ទេសាភិបាល

ជា-ចាន់តូ

# អក្សរកាត់

| | | |
|---|---|---|
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប | Gross Domestic Product (GDP) |
| ស.ហ.ក | អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | Cambodia Financial Intelligence Unit (CAFIU) |
| ABIF | ក្របខ័ណ្ឌសមាហរណកម្មវិស័យធនាគារអាស៊ាន | ASEAN Banking Integration Framework |
| ACCA | សមាគមគណនេយ្យករជំនាញ | Association of Certified Chartered Accountants |
| AFI | សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ | Alliance for Financial Inclusion |
| APG | ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្ដីពីការសម្អាតប្រាក់ | Asia/Pacific Group on Money Laundering |
| AMRO | អង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ | The ASEAN+3 Macroeconomic Research Office |
| ATM | ម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ | Automated Teller Machine |
| BCLMV | ព្រុយណេ កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម | Brunei, Cambodia, Myanmar and Vietnam |
| BIS | ធនាគារសម្រាប់ការទូទាត់អន្តរជាតិ | Bank for International Settlements |
| CAL | សេរីភាវូបនីយកម្មគណនីមូលធន | Capital Account Liberation |
| CMD | ការអភិវឌ្ឍទីផ្សារទុន | Capital Market Development |
| CMIM | ពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ | Chiang Mai Initiative Multilateralization |
| CFA | អ្នកជំនាញវិភាគហិរញ្ញវត្ថុ | Chartered Financial Analyst |
| CIA | ជំនាញសវនកម្មផ្ទៃក្នុង | Certified Internal Audit |
| CIFRS | ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា | Cambodia International Financial Reporting Standards |
| CPA | ជំនាញគណនេយ្យករសាធារណៈ | Certified Public Accountant |
| CRISP | ផ្លែតហ្វមចែករំលែកព័ត៌មាន និងភាពធន់ប្រព័ន្ធសន្តិសុខបច្ចេកវិទ្យា | Cybersecurity Resilience and Information Sharing Platform |

| | | |
|---|---|---|
| CSS | ប្រព័ន្ធខេមបូឆានស៊ែស្វីច | Cambodian Shared Switch |
| CUFA | សហព័ន្ធឥណទានមូលដ្ឋានអូស្ត្រាលី | Credit Union Foundation Australia |
| DTN | បណ្តាញសម្រាប់ចែករំលែកព័ត៌មាន | Data Transmission Network |
| EGMONT | ក្រុមអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ | Egmont Group of Financial Intelligence Units |
| EMV | អឺរ៉ូផេ, ម៉ាស្ទឺកាត, និងវីសា | Europay, MasterCard and Visa |
| ENEER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចេញ | Export-weighted Nominal Effective Exchange Rate |
| EREER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចេញ | Export-weighted Real Effective Exchange Rate |
| FATF | ក្រុមការងារហិរញ្ញវត្ថុ | Financial Action Task Force |
| FIDF | មូលនិធិអភិវឌ្ឍន៍គ្រឹះស្ថានហិរញ្ញវត្ថុ | Financial Institutions Development Fund |
| FINC | បរិយាបន្នហិរញ្ញវត្ថុ | Financial Inclusion |
| FMIS | ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ | Financial Management Information System |
| FPP | កម្មវិធីនិងគោលនយោបាយហិរញ្ញវត្ថុ | Financial Programing and Policies |
| FSI Connect | កម្មវិធីសិក្សារបស់វិទ្យាស្ថានស្ថិរភាពហិរញ្ញវត្ថុ | Financial Stability Institute Connect |
| FSL | សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ | Financial Services Liberalization |
| GSP | ប្រព័ន្ធអនុគ្រោះពន្ធទូទៅ | Generalised Scheme of Preferences |
| ICRG-JG | ក្រុមការងារត្រួតពិនិត្យរួមគ្នានៃប្រទេសអាស៊ី-ប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ | International Cooperation Review Group- Joint Group |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ | International Monetary Fund |
| INEER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចូល | Import-weighted Nominal Effective Exchange Rate |

| | | |
|---|---|---|
| IREER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចូល | Import-weighted Real Effective Exchange Rate |
| LPCO | ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា | Liquidity-Providing Collateralized Operation |
| MSDS | ប្រព័ន្ធទិន្នន័យសម្រាប់ការតាមដានម៉ាក្រូសេដ្ឋកិច្ច | Macroeconomic Surveillances Database System |
| NCD | មូលបត្រអាចជួញដូរបាន | Negotiable Certificate of Deposit |
| OBS | ប្រព័ន្ធធនាគារអនឡាញ | Online Banking System |
| PSS | ប្រព័ន្ធទូទាត់សងប្រាក់ | Payment and Settlement System |
| RCEP | ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ | Regional Comprehensive Economic Partnership |
| RPPI | សន្ទស្សន៍ថ្លៃលំនៅដ្ឋាន | Residential Property Price Indices |
| RTGS | ប្រព័ន្ធទូទាត់ដុលភ្លាមៗ | Real Time Gross Settlement |
| SCCB | គណៈកម្មាធិការដឹកនាំការកសាងសមត្ថភាព | Steering Committee on Capacity Building |
| SMEs | អង្គភាពធុនតូចនិងមធ្យម | Small and medium-sized entities |
| UNCDF | មូលនិធិអភិវឌ្ឍន៍មូលធនរបស់អង្គការសហប្រជាជាតិ | United Nations Capital Development Fund |
| UNESCAP | គណៈកម្មាធិការសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិសម្រាប់តំបន់អាស៊ីនិងប៉ាស៊ីហ្វិក | United Nations Economic and Social Commission for Asia and the Pacific |

# ខ្លឹមសារសង្ខេប

នៅឆ្នាំ២០២០នេះ សេដ្ឋកិច្ចពិភពលោកបានទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីការរីករាលដាលនៃជំងឺកូវីដ-១៩ ហើយមូលនិធិរូបិយវត្ថុអន្តរជាតិបានប៉ាន់ស្មានថា កំណើនសេដ្ឋកិច្ចអាចធ្លាក់ចុះ -៤,៩% ក្នុងនោះសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ធ្លាក់ចុះ -៥,៨% និងសេដ្ឋកិច្ចប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ធ្លាក់ចុះ -៣,៣%។ ទន្ទឹមនេះ កំណើនសេដ្ឋកិច្ចតំបន់អាស៊ានអាចធ្លាក់ចុះ -៣,៤%។ ឆ្លើយតបនឹងវិបត្តិសុខភាពនិងសេដ្ឋកិច្ចនេះ រដ្ឋាភិបាលនៃប្រទេសនានាបានដាក់ចេញនូវគោលនយោបាយសារពើពន្ធវិត្ថារកម្ម ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ចនិងគោលនយោបាយគាំពារសង្គមផ្សេងៗ ហើយធនាគារកណ្តាលភាគច្រើនបានអនុវត្តគោលនយោបាយរូបិយវត្ថុវិត្ថារកម្ម ដោយបានបន្ទាបអត្រាការប្រាក់គោល ចាក់បញ្ចូលសាច់ប្រាក់ក្នុងទីផ្សារ និងបន្ធូរបន្ថយការរឹតបន្តឹងផ្នែកបទប្បញ្ញត្តិក្នុងវិស័យធនាគារ ដើម្បីស្តារស្ថានភាពសេដ្ឋកិច្ចឡើងវិញ។

សេដ្ឋកិច្ចកម្ពុជាក៏ត្រូវបានប៉ាន់ស្មានថាអាចធ្លាក់ចុះ -១,៩% ដោយសារការធ្លាក់ចុះនៃវិស័យដែលពឹងផ្អែកលើតម្រូវការខាងក្រៅ រួមមាន វិស័យទេសចរណ៍ កម្មន្តសាល សំណង់និងអចលនទ្រព្យ ខណៈដែលវិស័យកសិកម្មបន្តកើនឡើងយ៉ាងល្អ។ ជញ្ជីងទូទាត់កម្ពុជាត្រូវបានប៉ាន់ស្មានថាមានអតិរេក ដោយសារកំណើនការនាំចេញនិងការធ្លាក់ចុះការនាំចូល គួបផ្សំនឹងការបន្តទទួលបានវិនិយោគផ្ទាល់បរទេស ទោះបីជាលំហូរចូលមានកម្រិតទាបជាងមុនក្តី។ អតិរេកជញ្ជីងទូទាត់បានរួមចំណែកបង្កើនទុនបម្រុងអន្តរជាតិដល់ ២១,៣ ប៊ីលានដុល្លារអាមេរិក ដែលមានកម្រិតជាង១០ខែនៃការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់ ខ្ពស់ជាងកម្រិតអប្បបរមាសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ (៣ខែ)។

អតិផរណាបន្តមានកម្រិតទាបក្នុងអត្រា ២,៩% ដែលខ្ពស់ជាងគ្រាដូចគ្នាឆ្នាំមុនបន្តិច (១,៩%) ដោយសារកំណើនថ្លៃក្រុមម្ហូបអាហារ ខណៈដែលថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈបានធ្លាក់ចុះ។ ជាមួយគ្នានេះ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកបន្តមានស្ថិរភាព ដោយមានកម្រិតជាមធ្យមក្នុងរង្វង់ ៤.០៩០ រៀលក្នុងមួយដុល្លារអាមេរិក ខ្ពស់ជាងគ្រាដូចគ្នាឆ្នាំមុន (៤.០៦១ រៀល)។ កម្រិតទាបនៃអតិផរណានិងស្ថិរភាពអត្រាប្តូរប្រាក់ បានរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។

ដើម្បីរួមចំណែកកាត់បន្ថយផលប៉ះពាល់ពីឥទ្ធិពលនៃជំងឺកូវីដ-១៩ មកលើសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានអនុវត្តគោលនយោបាយរូបិយវត្ថុវិត្ថារកម្ម និងបានធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ ដោយបានបង្កើនកម្រិតសន្ទនីយភាពក្នុងប្រព័ន្ធធនាគារ និងបានពង្រឹងជំនឿទុកចិត្តមកលើវិស័យធនាគារនិងប្រាក់រៀល។ ជាក់ស្តែង អត្រាប្រាក់បម្រុងកាតព្វកិច្ចទាំងប្រាក់រៀលនិងរូបិយប័ណ្ណត្រូវបានទម្លាក់មកត្រឹម ៧% ស្របពេលដែលអត្រាការប្រាក់លើមូលបត្រអាចជួញដូរបាន (NCD) និងប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ត្រូវបានបន្ទាប ដើម្បីកាត់បន្ថយថ្លៃដើមលើប្រាក់កម្ចីជារៀល។ NCD បានបម្រើដល់ការរក្សាសន្ទនីយភាពលើសរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលក្នុងនោះការចេញផ្សាយ NCD ចារឹកជាដុល្លារអាមេរិកមាន ៣០,៨ ប៊ីលានដុល្លារអាមេរិក ដែលបានកើនឡើង ៩៥,៣% និងជារៀលមាន ១០,៩ ទ្រីលានរៀល ដោយមានកំណើន ៤%។

ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាបានផ្តត់ផ្គង់សន្ទនីយភាពជារៀលទៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានតម្រូវការសន្ទនីយភាពជាប្រាក់រៀល តាមរយៈប្រតិបត្តិការ LPCO ចំនួន ២៣ លើក សរុប ៥,៩ ទ្រីលានរៀល ដែលបានកើនឡើង ២៩,៥%។ ក្នុងបរិការណ៍នៃការធ្លាក់ចុះកំណើនសេដ្ឋកិច្ច បរិមាណរូបិយវត្ថុទូទៅ (M2) ក៏បានថយចុះផងដែរក្នុងអត្រា ១៤,៧% (ទាបជាងគ្រាដូចគ្នាឆ្នាំមុនដែលមានកម្រិត ១៨,២%) ប៉ុន្តែស្ថិតក្នុងកម្រិតសមស្របសម្រាប់គាំទ្រតម្រូវការរូបិយវត្ថុក្នុងសេដ្ឋកិច្ច។ គួររំលេចថា ឥណទានជាប្រាក់រៀលធៀបនឹងសំពៀតឥណទានសរុបរក្សាបានក្នុងកម្រិត ១២,៨% ហើយកម្រិតដុល្លារូបនីយកម្ម (ប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងរូបិយវត្ថុទូទៅ) នៅបន្តស្ថិតក្នុងកម្រិតខ្ពស់ ៨៣,៨%។

វិស័យធនាគារបន្តរីកចម្រើននិងមានស្ថិរភាពយ៉ាងរឹងមាំ ព្រមទាំងបានរួមចំណែកយ៉ាងសកម្មក្នុងការគាំទ្រសកម្មភាពសេដ្ឋកិច្ច។ ទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារបានកើនឡើង ១៥,៧% (ដល់ ២១៧% នៃផ.ស.ស.) ក្នុងនោះឥណទានកើន ១៤,៨% (១៣៦% នៃផ.ស.ស.) ហើយប្រាក់បញ្ញើមានកំណើន ១៥,៤% (១២៣% នៃផ.ស.ស.)។ បណ្តាញប្រតិបត្តិការនិងសេវាហិរញ្ញវត្ថុត្រូវបានបន្តអភិវឌ្ឍនិងពង្រីកទៅដល់គ្រប់តំបន់ទូទាំងប្រទេស ដែលបានលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុជាលំដាប់ ដោយចំនួនគណនីប្រាក់បញ្ញើអតិថិជនកើនដល់ ៨,៩ លានគណនី (កើន ១៦,៨%) និងគណនីឥណទានអតិថិជនកើនដល់ ៣,២ លានគណនី (កើន ៣,៩%)។ ជាមួយគ្នានេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានផ្តល់ការអនុគ្រោះដល់អ្នកខ្ចីប្រាក់ តាមរយៈការរៀបចំឥណទានឡើងវិញចំនួន ២៨៥.០៧៤ គណនី ស្មើនឹងប្រមាណ ៤,២ ប៊ីលានដុល្លារអាមេរិក ដែលមាននិន្នាការថយចុះជាលំដាប់ចាប់ពីខែសីហាមក។ ធនាគារជាតិនៃកម្ពុជាបានអនុវត្តក្របខ័ណ្ឌត្រួតពិនិត្យផ្អែកលើហានិភ័យនិងទស្សនៈអនាគត ព្រមទាំងបានដាក់ចេញជាបន្តបន្ទាប់នូវវិធានការម៉ាក្រូនិងមីក្រូប្រុងប្រយ័ត្នដែលមានលក្ខណៈបុរេសកម្ម ដើម្បីពង្រឹងស្ថិរភាពហិរញ្ញវត្ថុ។ លើសពីនេះ បរិយាបន្នហិរញ្ញវត្ថុ ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន ក៏ត្រូវបានលើកកម្ពស់ជាប្រចាំ តាមរយៈយុទ្ធនាការអប់រំផ្នែកហិរញ្ញវត្ថុដល់សាធារណជន, ការផ្សព្វផ្សាយពីវិស័យមីក្រូហិរញ្ញវត្ថុនៅតាមមូលដ្ឋាន, ការទទួលនិងដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ហើយអង្គភាពការពារប្រាក់បញ្ញើ និងក្របខ័ណ្ឌដំណោះស្រាយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក៏ត្រូវបានបង្កើតឡើងផងដែរ។

ស្របតាមនិន្នាការពិភពលោកនិងតំបន់ បច្ចេកវិទ្យាហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ដោយប្រុងប្រយ័ត្ន ជាពិសេសនៅក្នុងប្រព័ន្ធទូទាត់សងប្រាក់ ដើម្បីឱ្យការទូទាត់កាន់តែមានប្រសិទ្ធភាព សុវត្ថិភាព និងតម្លៃសមរម្យ។ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការជាផ្លូវការប្រព័ន្ធបាគង ដែលជាប្រព័ន្ធទូទាត់កន្លោង មួយជួយសម្រួលការផ្ទេរប្រាក់និងការទូទាត់សងប្រាក់ឆ្លងគ្រឹះស្ថាន តាមរយៈប្រព័ន្ធអេឡិចត្រូនិក។ ទន្ទឹមនេះ ប្រព័ន្ធខេមបូឌានស៊ែស្វីចនិងប្រព័ន្ធរីថែលផេកំពុងត្រូវបានដាក់ឱ្យដំណើរការបឋម ហើយគ្រោងដាក់ឱ្យដំណើរការជាផ្លូវការក្នុងពេលឆាប់ៗខាងមុខ។ ស្តង់ដា QR កូត ក៏ត្រូវបានបង្កើតឡើងសម្រាប់អនុវត្តក្នុងប្រព័ន្ធទូទាត់សងប្រាក់ សំដៅសម្រួលដល់ការទូទាត់ឆ្លងគ្នារវាងគ្រឹះស្ថានផ្តល់សេវាទូទាត់និងការអនុវត្តគម្រោងភ្ជាប់ការទូទាត់ជាមួយប្រទេសក្នុងតំបន់។ ដើម្បីគាំទ្រដល់ពាណិជ្ជកម្មនិងវិនិយោគឆ្លងដែននៃប្រទេសទាំងពីរ ក៏ដូចជាពង្រីកការ

ប្រើប្រាស់រូបិយវត្ថុជាតិ ធនាគារជាតិនៃកម្ពុជានិងធនាគារកណ្តាលថៃបានដាក់ឱ្យប្រើប្រាស់ QR កូត សម្រាប់ការទូទាត់ឆ្លងដែនជាប្រាក់រៀលនិងប្រាក់បាតថៃ។

ធនាគារជាតិនៃកម្ពុជាបានបន្តគ្រប់គ្រងចរាចរណ៍សាច់ប្រាក់ប្រកបដោយប្រសិទ្ធភាព និង សុវត្ថិភាព ដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រជាជនទូទាំងប្រទេស។ គុណភាពនិងសោភ័ណភាព ក្រដាសប្រាក់ត្រូវបានពង្រឹង ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យា។ ដើម្បីលើកកម្ពស់អភិបាលកិច្ច ល្អនិងប្រសិទ្ធភាពការងារ ការធ្វើសវនកម្មនិងអធិការកិច្ចបានបន្តយកចិត្តទុកដាក់លើការការពារ ហានិភ័យ និងការរក្សានិរន្តរភាពការងារ។ ធនធានមនុស្សត្រូវបានបន្តអភិវឌ្ឍជាអាទិភាព ដោយ បច្ចុប្បន្ន មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាមានចំនួន ១.៧៩២ រូប ជាមួយនឹងការអភិវឌ្ឍសមត្ថភាព ជំនាញនិងឯកទេសកម្មជាប្រចាំ ជាពិសេសការសិក្សាតាមប្រព័ន្ធអនឡាញ ក្នុងស្ថានភាពនៃវិបត្តិ សុខភាពពិភពលោកនេះ។

លើសពីនេះ កិច្ចសហប្រតិបត្តិការអន្តរជាតិទាំងក្នុងក្របខ័ណ្ឌទ្វេភាគីនិងពហុភាគីត្រូវបាន ពង្រឹងនិងពង្រីកជាលំដាប់។ ធនាគារជាតិនៃកម្ពុជាបានចូលរួមពង្រឹងសមាហរណកម្មនិងបណ្តាញ សុវត្ថិភាពហិរញ្ញវត្ថុតំបន់ តាមរយៈការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើម ឈៀងម៉ៃ (CMIM), ការពង្រឹងប្រតិបត្តិការនៃកិច្ចព្រមព្រៀង CMIM ដោយបានចូលរួមក្នុងការសាកល្បង ដំណើរការយន្តការ CMIM (Test Run), ការជំរុញការប្រើប្រាស់រូបិយវត្ថុក្នុងស្រុកក្នុងគំនិតផ្តួចផ្តើម ទីផ្សារសញ្ញាប័ណ្ណអាស៊ី និងការបំពេញតួនាទីជាសហប្រធានគណៈកម្មការជាន់ខ្ពស់អាស៊ាន (SLC) ដោយជោគជ័យ។ ធនាគារជាតិនៃកម្ពុជាក៏ត្រូវបានជ្រើសរើសធ្វើជាសហប្រធានគណៈកម្មការ បរិយាបន្នហិរញ្ញវត្ថុអាស៊ាន (WC-FINC) ជាមួយធនាគារកណ្តាលឥណ្ឌូណេស៊ី សម្រាប់អាណត្តិ ឆ្នាំ២០២០-២០២២ ផងដែរ។

ដោយឡែក ទោះបីជាស្ថិតនៅក្នុងស្ថានភាពវិបត្តិនៃជំងឺកូវីដ-១៩ក្តី ដំណើរការនៃការរៀបចំ សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នៅតែប្រព្រឹត្តទៅបាន រហូតទទួលបានការអនុម័ត និងប្រកាសឱ្យប្រើប្រាស់កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០។ ដើម្បី ផ្សព្វផ្សាយខ្លឹមសារច្បាប់នេះឱ្យបានទូលំទូលាយ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) បានរៀបចំសិក្ខាសាលាដោយមានការចូលរួមពីតំណាងមកពីក្រសួង-ស្ថាប័ន និងបុគ្គលរាយការណ៍ ពាក់ព័ន្ធ។ ស.ហ.ក បានពង្រឹងជាប់ជាប្រចាំលើការតាមដាននិងទប់ស្កាត់សកម្មភាពសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ព្រមទាំងបានវាយតម្លៃគុណវុឌ្ឍិនិងបទពិសោធន៍របស់មន្ត្រីប្រតិបត្តិតាម ប្រព័ន្ធអនឡាញ និងជួបពិភាក្សាជាមួយបុគ្គលរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍ នៅក្នុងរបាយការណ៍ត្រួតពិនិត្យ។ ទន្ទឹមនេះ កិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងដៃគូអន្តរជាតិនានា ត្រូវបានពង្រឹងនិងពង្រីក ដើម្បីលើកកម្ពស់ការអនុវត្តការងារឱ្យកាន់តែមាន ប្រសិទ្ធភាពនិងវិសាលភាពកាន់តែទូលំទូលាយ។

# ផ្នែកទី១ - របាយការណ៍ប្រចាំឆ្នាំ២០២០

## I- ស្ថានភាពសេដ្ឋកិច្ចពិភពលោក

សេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំ២០២០បានធ្លាក់ចូលទៅក្នុងវិបត្តិធ្ងន់ធ្ងរ ដោយសារឥទ្ធិពលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ដែលបានរារាំងដល់សកម្មភាពសេដ្ឋកិច្ច ជាពិសេសវិស័យទេសចរណ៍ និងការវិនិយោគ។ យោងតាមការប៉ាន់ស្មានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)[១] កំណើនសេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំនេះធ្លាក់ចុះដល់ -៤,៤% ក្នុងនោះសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ធ្លាក់ចុះដល់ប្រមាណ -៥,៨% សេដ្ឋកិច្ចប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ប្រមាណ -៣,៣%។ កំណើនសេដ្ឋកិច្ចប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ក្នុងតំបន់អាស៊ី ត្រូវបានប៉ាន់ស្មានថានឹងថយចុះដល់ -១,៧% ក្នុងនោះសេដ្ឋកិច្ចអាស៊ាន-៥[២] ធ្លាក់ចុះដល់ -៣,៤% ខណៈដែលប្រទេសចិនត្រូវបានប៉ាន់ស្មានថានឹងមានកំណើន ១,៩% ដោយសារការបើកឱ្យដំណើរការសេដ្ឋកិច្ចឡើងវិញយ៉ាងឆាប់រហ័ស។

ក្នុងអំឡុងពេលនៃវិបត្តិសុខភាពនេះ រដ្ឋាភិបាលនៃប្រទេសជាច្រើន បានអនុវត្តគោលនយោបាយសារពើពន្ធវិត្ថារកម្មដើម្បីជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ក្នុងនោះប្រទេសអភិវឌ្ឍន៍បានចេញវិធានការដែលមានទំហំទឹកប្រាក់ប្រមាណជាង ៩% នៃ ផ.ស.ស. ស្របពេលដែលប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ប្រមាណ ៣,៥% នៃផ.ស.ស.[៣]។ វិធានការសំខាន់ៗទាំងនោះរួមមាន៖ i/-ការអនុម័តកញ្ចប់ថវិកាទ្រង់ទ្រាយធំដើម្បីស្តារសេដ្ឋកិច្ចចេញពីវិបត្តិសុខភាព, ii/-ការផ្តល់សាច់ប្រាក់ជួយសង្គ្រោះដល់ក្រុមហ៊ុននិងគ្រួសារដែលងាយរងគ្រោះ, iii/-ការជួយឧបត្ថម្ភធនដល់ក្រុមហ៊ុនដើម្បីបើកប្រាក់ខែជូនបុគ្គលិក, iv/-ការពង្រីកវិសាលភាពធានារ៉ាប់រងនិកម្មភាព និង v/-ការពន្យារពេលបង់ពន្ធជូនរដ្ឋជាដើម។ ជាមួយគ្នានេះ បណ្តាធនាគារកណ្តាល បានប្រកាន់យកគោលនយោបាយរូបិយវត្ថុវិត្ថារកម្មដើម្បីគាំទ្រសន្ទនីយភាពក្នុងទីផ្សារ ក្នុងនោះធនាគារកណ្តាលនៃប្រទេសអភិវឌ្ឍន៍បានបង្កើនការចាក់បញ្ចូលសាច់ប្រាក់ក្នុងសេដ្ឋកិច្ចប្រមាណ ១១% នៃផ.ស.ស. ស្របពេលដែលធនាគារកណ្តាលនៃប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ប្រមាណជាង ២% នៃផ.ស.ស.[៤]។ គោលនយោបាយរូបិយវត្ថុវិត្ថារកម្មចម្បងៗទាំងនោះរួមមាន៖ i/-ការកាត់បន្ថយអត្រាការប្រាក់គោល ii/-ការទិញទ្រព្យសកម្មទ្រង់ទ្រាយធំ, iii/-ការជំរុញការរៀបចំឥណទានសារឡើងវិញ និង iv/-ការបន្ធូរបន្ថយបទប្បញ្ញត្តិទៅលើការត្រួតពិនិត្យធនាគារ និងការអនុញ្ញាតឱ្យប្រើប្រាស់ទ្រនាប់ដើមទុនដើម្បីទូទាត់ការខាតបង់ ជាដើម។

---

[១] មូលនិធិរូបិយវត្ថុអន្តរជាតិបច្ចុប្បន្នភាពត្រឹមខែតុលាឆ្នាំ២០២០

[២] អាស៊ាន-៥ រួមមាន ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងវៀតណាម

[៣] របាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចពិភពលោក ខែតុលា ឆ្នាំ២០២០

[៤] របាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចពិភពលោក ខែតុលា ឆ្នាំ២០២០

**ក្រាហ្វ ១ ៖ កំណើនសេដ្ឋកិច្ចពិភពលោក និងតំបន់**

(គិតជាភាគរយ, ឆ្នាំ២០០៦ - ២០២១ព្យាករណ៍)




ប្រភព៖ Trading Economics

**ក្រាហ្វ ២៖ កំណើនសេដ្ឋកិច្ចតំបន់**

(គិតជាភាគរយ, ឆ្នាំ២០០៨, ២០២០ប៉ាន់ស្មាន និង២០២១ព្យាករណ៍)




ប្រភព៖ មូលនិធិរូបិយវត្ថុអន្តរជាតិ

## ប្រអប់ ១ ៖ គោលនយោបាយរបស់ធនាគារកណ្តាលមួយចំនួន ក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩

ធនាគារកណ្តាលទាំងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ បានប្រកាន់យកគោលនយោបាយរូបិយវត្ថុវិត្ថារកម្ម ដើម្បីស្តារស្ថានភាពសេដ្ឋកិច្ចឡើងវិញក្នុងអំឡុងពេលវិបត្តិជំងឺកូវីដ-១៩ ស្របពេលដែលអតិផរណានៅមានកម្រិតទាប។ ធនាគារកណ្តាលរបស់ប្រទេសដែលជាដៃគូពាណិជ្ជកម្មកម្ពុជា បានបន្តអនុវត្តគោលនយោបាយសំខាន់ៗរួមមាន ៖

**ធនាគារកណ្តាលអាមេរិក**៖ i/-កាត់បន្ថយអត្រាការប្រាក់គោលមកក្នុងចន្លោះពី 0% ទៅ ០,២៥% នៅខែមីនា ឆ្នាំ២០២០ ii/-បង្កើនការទិញសញ្ញាប័ណ្ណរដ្ឋតាមការចាំបាច់ iii/-ពង្រីកហិរញ្ញប្បទានរយៈពេលខ្លីដល់ធនាគារដែលខ្វះសន្ទនីយភាព iv/-កាត់បន្ថយថ្លៃដើមសម្រាប់កម្ចីរយៈពេលខ្លីពីធនាគារកណ្តាល (Discount Window) v/-ពង្រីកប្រតិបត្តិការស្វប់ជាដុល្លារអាមេរិក និងផ្តល់ឥណទានបណ្តោះអាសន្នរយៈពេលខ្លីជាមួយធនាគារកណ្តាលនិងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិជាដៃគូ vi/-បង្កើតឧបករណ៍ហិរញ្ញវត្ថុថ្មីៗបន្ថែមដើម្បីសម្រួលដល់លំហូរឥណទាននៅក្នុងសេដ្ឋកិច្ច vii/-កាត់បន្ថយការរឹតបន្តឹងការត្រួតពិនិត្យ អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារប្រើប្រាស់ទ្រនាប់ដើមទុននិងសន្ទនីយភាពរបស់ខ្លួន កែសម្រួលនីតិវិធីក្នុងការត្រួតពិនិត្យ និងផ្តល់ពេលវេលាបន្ថែមដល់គ្រឹះស្ថានធនាគារដើម្បីអនុវត្តតាមអនុសាសន៍របស់អាជ្ញាធរត្រួតពិនិត្យ viii/-បន្ធូរបន្ថយបទប្បញ្ញត្តិចំពោះការត្រួតពិនិត្យ និង ix/-ជំរុញឱ្យសាជីវកម្មអចលនទ្រព្យរបស់រដ្ឋ Fannie Mae and Freddie Mac អនុគ្រោះដល់អ្នកខ្ចីប្រាក់ក្នុងការបង់ឥណទានអចលនទ្រព្យចំនួន១២ខែ, ផ្អាកការរាយការណ៍ទៅការិយាល័យឥណទានចំពោះការសងយឺតពេល, ផ្អាកការរឹបអូសនិងលក់ឡាយឡុងអចលនទ្រព្យដែលមានបញ្ហាបំណុល និងរៀបចំឥណទានឡើងវិញ។ល។

**ធនាគារកណ្តាលអឺរ៉ុប៖** i/-រក្សាអត្រាការប្រាក់គោល 0% ii/-ចាក់បញ្ចូលសាច់ប្រាក់បន្ថែម ១២០ប៊ីលានអឺរ៉ូ ដល់ចុងឆ្នាំ២០២០ iii/-ផ្តល់ឥណទានបំពេញបន្ថែម (Fixed Rate Full Allotment) ដល់ធនាគារក្នុងអត្រាការប្រាក់ទាប ០,៥% ចាប់ពីខែមិថុនា ឆ្នាំ២០២០ ដល់ ខែមិថុនា ឆ្នាំ២០២១ ដើម្បីធានាសន្ទនីយភាពក្នុងទីផ្សារ iv/-បង្កើតឧបករណ៍ហិរញ្ញវត្ថុ PELTRO សម្រាប់ដោះស្រាយបន្ទាន់ចំពោះវិបត្តិជំងឺរាតត្បាតជាសកល ក្នុងអត្រាការប្រាក់ទាប ដែលមានឥណប្រតិទាននៅខែកញ្ញា ឆ្នាំ២០២១ v/-ក្នុងខែមិថុនា ធនាគារកណ្តាលអឺរ៉ុបបានចាក់បញ្ចូលសាច់ប្រាក់បន្ថែមក្នុងទីផ្សារ ១,៣៥ ទ្រីលានអឺរ៉ូ ដើម្បីទិញសញ្ញាប័ណ្ណរដ្ឋនិងក្រុមហ៊ុនឯកជន រហូតដល់ខែមិថុនា ឆ្នាំ២០២១ vi/-កាត់បន្ថយស្តង់ដាទ្រព្យបញ្ចាំសម្រាប់ប្រតិបត្តិការហិរញ្ញប្បទានក្នុងប្រព័ន្ធហិរញ្ញវត្ថុអឺរ៉ុប vii/-បង្កើតឧបករណ៍ហិរញ្ញវត្ថុសម្រាប់ជួយដល់ធនាគារកណ្តាលជាដៃគូដែលខ្វះសន្ទនីយភាពជាប្រាក់អឺរ៉ូ ជាមួយនឹងប្រតិបត្តិការស្វ៊ប់ទ្វេភាគី viii/-អនុញ្ញាតឱ្យស្ថាប័នហិរញ្ញវត្ថុសំខាន់ៗធ្វើប្រតិបត្តិការក្រោមគោលការណ៍ Pillar2 ជាបណ្តោះអាសន្ន ix/-អនុគ្រោះជាបណ្តោះអាសន្នដល់ការធ្វើចំណាត់ថ្នាក់ឥណទាននិងឥណទានមិនដំណើរការ ដែលត្រូវបានធានាដោយរដ្ឋ x/-ស្នើឱ្យគ្រឹះស្ថានធនាគារផ្អាកការបែងចែកភាគលាភសម្រាប់ឆ្នាំ២០១៩ និងឆ្នាំ២០២០ ឬទិញត្រឡប់នូវប័ណ្ណភាគហ៊ុនវិញក្នុងពេលវិបត្តិ និង xi/-កែសម្រួលដើមទុនកាតព្វកិច្ចអប្បបរមារបស់គ្រឹះស្ថានធនាគារជាបណ្តោះ-អាសន្ន។ល។

**អាជ្ញាធររូបិយវត្ថុហុងកុង៖** i/-បន្ថយអត្រាការប្រាក់គោលមកត្រឹម ០,៨៥% ii/-បន្ថយអត្រាទ្រនាប់ដើមទុន និងប្រាក់បម្រុងកាតព្វកិច្ច ដើម្បីបង្កើនលទ្ធភាពរបស់ធនាគារក្នុងការផ្តល់ឥណទាន iii/-បង្កើនសន្ទនីយភាពក្នុងប្រព័ន្ធធនាគារ ទាំងជាដុល្លារហុងកុង ទាំងជាដុល្លារអាមេរិក ដោយមានកិច្ចសហការទ្វេភាគីជាមួយធនាគារកណ្តាលអាមេរិក iv/-ជំរុញឱ្យធនាគាររក្សាទ្រនាប់សន្ទនីយភាពប្រកបដោយភាពទន់ភ្លន់ v/-ជួយសម្រួលហិរញ្ញប្បទានអន្តរធនាគារ vi/-សម្រាលបន្ទុកធនាគារក្នុងការអនុវត្តតាមគោលការណ៍បាសែលIII vii/-ផ្តល់ឥណទានដែលមានការប្រាក់ទាប ៥០ ប៊ីលានដុល្លារហុងកុង សម្រាប់អាជីវកម្មធុនតូចនិងមធ្យម ដោយមានការធានា ១០០% ពីរដ្ឋាភិបាល viii/-បង្កើនកម្រិតអតិបរមានៃឥណទានសម្រាប់ក្រុមហ៊ុនដែលទទួលបានការធានាពីរដ្ឋាភិបាល ix/-អនុញ្ញាតឱ្យសាជីវកម្មមួយចំនួនផ្អាកការសងប្រាក់ដើមមួយរយៈ និង x/-ជំរុញឱ្យធនាគារពន្យារការសងប្រាក់ចំពោះសហគ្រាសធុនតូចនិងមធ្យម និងគ្រួសារដែលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ស្របតាមគោលការណ៍គ្រប់គ្រងហានិភ័យរបស់ធនាគារទាំងនោះ។ល។

**អាជ្ញាធររូបិយវត្ថុសិង្ហបុរី៖** i/-ជំរុញឱ្យគ្រឹះស្ថានធនាគារជួយសម្រាលបន្ទុកដល់អតិថិជនដែលរងគ្រោះដោយវិបត្តិកូវីដ-១៩ ii/-សហការជាមួយស្ថាប័នហិរញ្ញវត្ថុដើម្បីបង្កើតនូវវិធានការជាកញ្ចប់ សំដៅជួយអតិថិជនដែលជួបបញ្ហាលំហូរសាច់ប្រាក់រយៈពេលខ្លី តាមរយៈការរៀបចំឥណទានឡើងវិញតាមការស្នើសុំរបស់អតិថិជន កាត់បន្ថយការប្រាក់ចំពោះឥណទានមួយចំនួន និងធានាឱ្យមានសន្ទនីយភាពគ្រប់គ្រាន់ទាំងជាប្រាក់ដុល្លារអាមេរិក ទាំងជាប្រាក់ដុល្លារសិង្ហបុរី ក្នុងទីផ្សារអន្តរធនាគារ iii/-បង្កើតប្រតិបត្តិការស្វ៊ប់ទ្វេភាគីជាមួយធនាគារកណ្តាលអាមេរិកក្នុងទំហំទឹកប្រាក់ ៦០ ប៊ីលានដុល្លារអាមេរិក iv/-បន្ធូរបន្ថយបទប្បញ្ញត្តិនិងសកម្មភាពត្រួតពិនិត្យមួយចំនួនដើម្បីឱ្យ

ធនាគារទាំងនោះមានលទ្ធភាពដោះស្រាយបញ្ហាបាន និង v/-រៀបចំកញ្ចប់ជំនួយ ១២៥ លានដុល្លារសិង្ហបុរី ដើម្បីពង្រឹងសេវាហិរញ្ញវត្ថុនិងបច្ចេកវិទ្យាហិរញ្ញវត្ថុ។ល។

**ធនាគារកណ្តាលឡាវ៖** i/-ទម្លាក់អត្រាប្រាក់បម្រុងកាតព្វកិច្ចពី ១០% ទៅ ៨% លើរូបិយប័ណ្ណ និងពី ៥% ទៅ ៤% លើរូបិយវត្ថុ ចាប់ពីថ្ងៃទី២ ខែមេសា ii/-ដាក់ចេញគោលនយោបាយឥណទានថ្មី តាមរយៈការស្នើឱ្យធនាគាររៀបចំឥណទានឡើងវិញ និងផ្តល់ឥណទានថ្មីដល់អាជីវកម្មដែលទទួលរងផលប៉ះពាល់ពីឥទ្ធិពលជំងឺកូវីដ-១៩។ ក្រោមគោលនយោបាយនេះ ធនាគារដែលអនុវត្តតាមនឹងទទួលបានអត្ថប្រយោជន៍ពីការពន្យារពេលក្នុងការអនុវត្តបទប្បញ្ញត្តិលើចំណាត់ថ្នាក់ឥណទាន និងការផ្តល់ឥណទាន iii/-ទម្លាក់អត្រាការប្រាក់គោល iv/-ចេញសេចក្តីណែនាំស្តីពីការអនុវត្តលើការពង្រីកវិសាលភាពនៃគោលនយោបាយឥណទានទៅកាន់គ្រឹះស្ថានមិនមែនធនាគារ រួមមាន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហជីពឥណទាននិងសន្សំ ក្រុមហ៊ុនភតិសន្យា និងហាងបញ្ចាំ v/-ត្រៀមទឹកប្រាក់ ២០០ ប៊ីលានគីបឡាវ សម្រាប់ផ្តល់កម្ចីជូនសហគ្រាសធុនតូចនិងមធ្យម តាមរយៈធនាគារពាណិជ្ជ និង vi/-គ្រប់គ្រងអត្រាប្តូរប្រាក់ ប៉ុន្តែពុំបានចេញវិធានការគ្រប់គ្រងមូលធនទេ។ល។

**ធនាគារកណ្តាលថៃ៖** i/-ទម្លាក់អត្រាការប្រាក់គោលពី ១,២៥% ទៅ ០,៥% និងកាត់បន្ថយការបង់ប្រាក់របស់គ្រឹះស្ថានធនាគារទៅក្នុងមូលនិធិអភិវឌ្ឍន៍គ្រឹះស្ថានហិរញ្ញវត្ថុ (FIDF) ពី ០,៤៦% ទៅ ០,២៣% នៃមូលដ្ឋានប្រាក់បញ្ញើ ដើម្បីផ្តល់លទ្ធភាពកាត់បន្ថយអត្រាផ្តល់កម្ចីនាពេលអនាគត ii/-ចេញវិធានការជួយគាំទ្រដល់ធុរកិច្ច ដូចជាការផ្តល់ឥណទានទៅកាន់គ្រឹះស្ថានហិរញ្ញវត្ថុ ៥០០ ប៊ីលានបាត សម្រាប់ផ្តល់ដល់សហគ្រាសធុនតូចនិងមធ្យម, ការធានារបស់រដ្ឋាភិបាលលើការបង់អត្រាការប្រាក់ពី ៦០-៧០% នៃឥណទានសម្រាប់ ៦ ខែដំបូង, និងការបន្ថយលក្ខខណ្ឌសងសម្រាប់អាជីវកម្ម និង iii/-ចេញវិធានការគាំទ្រដល់ស្ថិរភាពហិរញ្ញវត្ថុ រួមមាន ការបង្កើតមូលនិធិស្ថិរភាពសញ្ញាប័ណ្ណសាជីវកម្មដើម្បីផ្តល់ហិរញ្ញប្បទាន ៤០០ ប៊ីលានបាតដល់ក្រុមហ៊ុនកម្រិតខ្ពស់ ដែលមានសញ្ញាប័ណ្ណដល់កាលកំណត់ក្នុងអំឡុងឆ្នាំ២០២០-២០២១, ការទិញសញ្ញាប័ណ្ណរាជរដ្ឋាភិបាលដើម្បីធានាដំណើរការជាប្រក្រតីនៅក្នុងទីផ្សារសញ្ញាប័ណ្ណ, ការកាត់បន្ថយការចេញផ្សាយសញ្ញាប័ណ្ណធនាគារកណ្តាលថៃ, និងការផ្តល់សន្ទនីយភាពពិសេសសម្រាប់មូលនិធិសង្គហ តាមរយៈធនាគារ និង iv/-ផ្តល់សន្ទនីយភាពក្នុងទីផ្សារប្តូរប្រាក់ និងអនុញ្ញាតឱ្យអត្រាប្តូរប្រាក់កែតម្រូវដោយខ្លួនឯង។ល។

**ធនាគារកណ្តាលវៀតណាម៖** i/-ទម្លាក់អត្រាការប្រាក់គោលដល់ ៤% ii/-ចេញផ្សាយគោលការណ៍ណែនាំដល់ធនាគារពាណិជ្ជក្នុងការកាត់បន្ថយ/លើកលែងការប្រាក់ និងពន្យារពេលសងបំណុល iii/-ផ្តល់កញ្ចប់ឥណទាន ៣០០ ទ្រីលានដុង (៣,៨% នៃផ.ស.ស) ជាមួយនឹងអត្រាការប្រាក់ទាបដល់គ្រឹះស្ថានធនាគារ (គិតត្រឹមចុងខែមិថុនា) ដែលបានជួយដល់អតិថិជនជិត ៩២០ពាន់នាក់ (ជាមួយនឹងឥណទានមានទឹកប្រាក់ជិត ២.០០០ ទ្រីលានដុង) ដោយបានជួយជំរុញឱ្យមានការរៀបចំឥណទានឡើងវិញ ការលើកលែងឬកាត់បន្ថយអត្រាការប្រាក់លើបំណុលមានស្រាប់ និងផ្តល់ឥណទានថ្មីៗបន្ថែមទៀត iv/-លើកលែងនិងកាត់បន្ថយថ្លៃសេវាដល់គ្រឹះស្ថាន

ហិរញ្ញវត្ថុ v/-អនុញ្ញាតឱ្យក្រុមហ៊ុនដែលទទួលរងផលប៉ះពាល់មានសិទ្ធិទទួលបានឥណទានសម្បទានពីធនាគារគោលនយោបាយសង្គមវៀតណាមដោយគ្មានការប្រាក់ ដើម្បីទូទាត់បៀវត្សរ៍ដល់បុគ្គលិកដែលឈប់ធ្វើការជាបណ្ដោះអាសន្ន និង vi/-ណែនាំគ្រឹះស្ថានធនាគារឱ្យកាត់បន្ថយប្រាក់អត្ថប្រយោជន៍បន្ថែមនិងបៀវត្សរ៍ បន្ថយចំណាយប្រតិបត្តិការ កែសម្រួលផែនការធុរកិច្ចទាន់ពេលវេលា (បូករួមទាំងការមិនទូទាត់ភាគលាភជាសាច់ប្រាក់) និងប្រើប្រាស់ធនធានដែលបានរក្សាទុកដើម្បីកាត់បន្ថយការប្រាក់ vii/-ត្រៀមចាក់បញ្ចូលសន្ទនីយភាពតាមរយៈឧបករណ៍ហិរញ្ញប្បទានដល់ធនាគារគោលនយោបាយសង្គមវៀតណាមនិងគ្រឹះស្ថានឥណទានដើម្បីអនុវត្តកម្មវិធីរបស់រដ្ឋ និងជួយដល់គ្រឹះស្ថានឥណទានដោះស្រាយបញ្ហាឥណទានមិនដំណើរការ។ viii/-ផ្តល់ហិរញ្ញប្បទានដល់ធនាគារគោលនយោបាយសង្គមវៀតណាម ក្នុងទឹកប្រាក់ ១៦ ទ្រីលានដុង និងមានអត្រាការប្រាក់សូន្យភាគរយ និង ix/-ប្រកាសថានឹងធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់តាមការចាំបាច់ដើម្បីកាត់បន្ថយការប្រែប្រួលខ្លាំងនៃអត្រាប្តូរប្រាក់។ល។

ប្រភព៖ មូលនិធិរូបិយវត្ថុអន្តរជាតិ និង Tradingeconomic.com (បច្ចុប្បន្នភាពគិតត្រឹមថ្ងៃ១២ ខែវិច្ឆិកា ឆ្នាំ២០២០)

## II- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា

### ១- កំណើនសេដ្ឋកិច្ច

សេដ្ឋកិច្ចកម្ពុជាបានទទួលរងការប៉ះទង្គិចធ្ងន់ធ្ងរពីឥទ្ធិពលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសទៅលើវិស័យដែលមានការពឹងផ្អែកខ្លាំងពីតម្រូវការខាងក្រៅ ដែលរួមមាន វិស័យទេសចរណ៍ វិស័យកម្មន្តសាល និងសំណង់ ដែលកន្លងមក វិស័យទាំងនេះបានរួមចំណែកប្រមាណបីភាគបួននៃកំណើនសេដ្ឋកិច្ច។

- **វិស័យទេសចរណ៍**

វិស័យទេសចរណ៍ (ដែលឆ្លុះបញ្ចាំងដោយវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន) បានទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេ ដោយត្រូវបានប៉ាន់ស្មានថាធ្លាក់ចុះ -៩,៧%។ ភ្ញៀវទេសចរអន្តរជាតិចូលមកកម្ពុជា បានធ្លាក់ចុះយ៉ាងគំហុកក្នុងអត្រា -៨០,៣% (ប៉ាន់ស្មាន) ធៀបនឹងកំណើនឆ្នាំមុន ៦,៦% ដោយភ្ញៀវទេសចរចិនដែលឈរលំដាប់ទី១នៃភ្ញៀវទេសចរសរុប (មានសមាមាត្រ ២៥%) បានធ្លាក់ចុះរហូតដល់ -៨៤%។ ផ្អែកតាមគោលបំណងនៃការធ្វើដំណើរ[៥] ភ្ញៀវទេសចរអន្តរជាតិមកក្នុងគោលបំណងកម្សាន្តនិងធុរកិច្ចបានធ្លាក់ចុះ -៧៥,៥% និង -៧៩,២% រៀងគ្នា។ ការងើបឡើងវិញនៃទេសចរណ៍ក្នុងស្រុកនាពេលថ្មីៗនេះ បាននិងកំពុងរួមចំណែកជួយកាត់បន្ថយការប៉ះពាល់មួយផ្នែកមកលើវិស័យសណ្ឋាគារ ភោជនីយដ្ឋាន ការធ្វើដំណើរ និងពាណិជ្ជកម្ម ដោយភ្ញៀវទេសចរក្នុងស្រុកត្រូវបានប៉ាន់ស្មានថាមានចំនួន ៥,៣លាននាក់ (សមាមាត្រ ៨០% នៃភ្ញៀវទេសចរសរុប)។

[៥] ទិន្នន័យរយៈពេល១០ខែ

**ក្រាហ្វ ៣៖ ភ្ញៀវទេសចរអន្តរជាតិ**

(ឆ្នាំ២០១៣ - ២០២០ប៉ាន់ស្មាន)




ប្រភព៖ ក្រសួងទេសចរណ៍

- **វិស័យកម្មន្តសាល**

វិស័យកម្មន្តសាលបានធ្លាក់ចុះគួរឱ្យកត់សម្គាល់ ជាចម្បងដោយសារការធ្លាក់ចុះនៃតម្រូវការខាងក្រៅ ជាពិសេស ពីប្រទេសដែលជាគោលដៅទីផ្សារនាំចេញសំខាន់ៗ។ ផ្អែកតាមតួលេខក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រោងចក្រចំនួន ៩៥ បានបិទទ្វារ និងបានប៉ះពាល់ដល់កម្លាំងពលកម្មប្រមាណជាង ៥ម៉ឺននាក់ (បើទោះមានរោងចក្រចុះបញ្ជីបើកថ្មីក៏ដោយ)។ ជាមួយនឹងស្ថានភាពនេះ ផលិតផលសម្រេចក្នុងវិស័យនេះ[៦]បានធ្លាក់ចុះ -២៧% (ប៉ាន់ស្មាន) ដោយក្នុងនោះ ផលិតផលឧស្សាហកម្មសម្រាប់នាំចេញ និងផលិតផលឧស្សាហកម្មបម្រើទីផ្សារក្នុងស្រុកបានធ្លាក់ចុះ -៣៣% និង -៩% រៀងគ្នា។ ទោះយ៉ាងណា វិនិយោគិនបន្តមានសុទិដ្ឋិនិយមចំពោះវិស័យកម្មន្តសាល ដោយរោងចក្រធុនធំបើកថ្មីមានចំនួន ២០៩[៧] និងភាគច្រើនជារោងចក្រកែច្នៃលោហៈធាតុ។

**ក្រាហ្វ ៤៖ ផលិតផលសរុបសម្រេចបាន**

(ប៊ីលានដុល្លារអាមេរិក, ឆ្នាំ២០១៥ - ២០២០ប៉ាន់ស្មាន)




**ក្រាហ្វ ៥៖ ចំនួនរោងចក្រសរុប**

(ឆ្នាំ២០១៥ - ខែវិច្ឆិកា ឆ្នាំ២០២០)




ប្រភព៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

[៦] គ្របដណ្តប់តែរោងចក្រធុនធំដោយផ្អែកលើទិន្នន័យរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

[៧] គិតត្រឹម ១១ខែដើមឆ្នាំ២០២០

- ## វិស័យសំណង់

វិស័យសំណង់បានធ្លាក់ចុះ -៣% (ប៉ាន់ស្មាន) ជាចម្បងដោយសារការថយចុះនៃសកម្មភាពវិនិយោគក្នុងស្រុក និងលំហូរទុនវិនិយោគផ្ទាល់បរទេស។ ការថយចុះនេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈសូចនាករសំខាន់ៗ ដូចជា ការថយចុះនៃចំនួនគម្រោង តម្លៃនិងផ្ទៃក្រឡាសំណង់ដែលបានស្នើ និងការនាំចូលសម្ភារនិងបរិក្ខារសំណង់។ កំណើនចំនួនគម្រោង តម្លៃនិងផ្ទៃក្រឡាគម្រោងសំណង់បានធ្លាក់ចុះ[៨] -០,៥%, -២៥% និង -១៧% រៀងគ្នា ជាពិសេសលើប្រភេទផ្ទៃក្រឡាគម្រោងសំណង់ទេសចរណ៍ (ធ្លាក់ចុះ -៥៥,២%) និងឧស្សាហកម្ម (-៣១%)។ ទន្ទឹមនេះ ការនាំចូលសម្ភារនិងបរិក្ខារសំណង់គិតជាតម្លៃ បានធ្លាក់ចុះ -១០,៨% (ប៉ាន់ស្មាន) ដែលឆ្លុះបញ្ចាំងពីការថមថយសកម្មភាពសាងសង់ ដោយសារការផ្អាកឬព្យួរគម្រោងមួយចំនួន ក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩។

**ក្រាហ្វ ៦ ៖ ចំនួននិងតម្លៃគម្រោងសំណង់**
(ឆ្នាំ២០១៦ - ១១ខែ ឆ្នាំ២០២០)




ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**ក្រាហ្វ ៧ ៖ កំណើននៃការនាំចូលសម្ភារនិងបរិក្ខារសំណង់**
(ឆ្នាំ២០១៦ - ២០២០ប៉ាន់ស្មាន)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

- ## វិស័យកសិកម្ម

វិស័យកសិកម្មមានវឌ្ឍនភាពល្អជាមួយនឹងអត្រាកំណើនជិត ១% (ប៉ាន់ស្មាន) ក្រោមភាពអំណោយផលពីបម្រែបម្រួលកម្លាំងពលកម្មជាបណ្តោះអាសន្នពីវិស័យដែលកំពុងប្រឈម និងការគាំទ្រពីគោលនយោបាយពិពិធកម្មទៅកាន់វិស័យកសិ-ឧស្សាហកម្ម បើទោះជាបានរងផលប៉ះពាល់ពីគ្រោះរាំងស្ងួត និងជំនន់ទឹកភ្លៀងក្នុងរយៈពេលខ្លីក៏ដោយ។ យោងតាមទិន្នន័យពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្ទៃដីដាំដុះ និង

**ក្រាហ្វ ៨ ៖ ផ្ទៃដីដាំដុះនិងបរិមាណស្រូវរដូវវស្សា**
(គិតត្រឹម៩ខែ ឆ្នាំ២០១៨ - ៩ខែ ឆ្នាំ២០២០)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

---

[៨] គិតត្រឹម ១១ខែដើមឆ្នាំ២០២០

បរិមាណស្រូវរដូវវស្សាមានកំណើន[9] ១,៣% និង ១៧,៤% (ឆ្នាំលើឆ្នាំ) រៀងគ្នា ស្របពេលដែលទិន្នផលវារីវប្បកម្ម (ចិញ្ចឹមត្រីនិងបង្គា) បានកើនឡើងខ្ពស់ ២០,៧%។ ដោយឡែក ដោយសារតម្រូវការទីផ្សារអន្តរជាតិនៅបន្តមានកម្រិតទាប ផលកៅស៊ូនិងបរិមាណបញ្ចេញលក់បានថមថយល្បឿនកំណើនមកត្រឹម ៤,១% និង ៣,៨% រៀងគ្នា ស្របពេលដែលតម្លៃកៅស៊ូបានបន្តថយចុះ -១,២% (មកត្រឹម ១.២៨៨ដុល្លារអាមេរិកក្នុងមួយតោន)។

**ក្រាហ្វ ៩ ៖ ការរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចតាមវិស័យចម្បងៗ**

(ឆ្នាំ២០០៤ - ២០២១ព្យាករណ៍)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ

## ២- ស្ថានភាពអតិផរណា

អតិផរណាបន្តមានកម្រិតទាបក្នុងអត្រា ២,៩% ប៉ុន្តែខ្ពស់ជាងឆ្នាំមុនបន្តិច (១,៩%) ជាចម្បងដោយសារកំណើនថ្លៃក្រុមម្ហូបអាហារ បើទោះក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈបានធ្លាក់ថ្លៃ ហើយកំណើនថ្លៃក្រុមទំនិញស្នូលបានថមថយក៏ដោយ[10]។

ថ្លៃក្រុមម្ហូបអាហារបានកើនឡើង ៤,៦% (២,១% នៅឆ្នាំ២០១៩) ជាចម្បងដោយសារឥទ្ធិពលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលបានធ្វើឱ្យមានកំណើនតម្រូវការ និងការរអាក់រអួលក្នុងការដឹកជញ្ជូនទំនិញនាំចូល ស្របពេលដែលថ្លៃម្ហូបអាហារនៅប្រទេសសំខាន់ៗដែលកម្ពុជានាំចូលក៏បានកើនឡើងផងដែរ ដូចជាប្រទេសវៀតណាម ថៃ និងចិន ក្នុងហេតុផលដូចគ្នា។ ផ្ទុយទៅវិញ ថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈមានបរិត្តផរណា -៣,៣% (-១,១% នៅឆ្នាំមុន) ដោយសារការធ្លាក់ថ្លៃប្រេងឆៅពិភពលោកដែលបណ្តាលមកពីការថយចុះតម្រូវការ ស្របពេលដែលបរិមាណនៃការផ្គត់ផ្គង់ត្រូវបានកាត់បន្ថយតិចតួច និងកង្វះទីតាំងស្តុកប្រេង។

---

[9] គិតត្រឹម៩ខែដើមឆ្នាំ២០២០

[10] ក្រុមម្ហូបអាហារ ក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ និងក្រុមមុខទំនិញស្នូល មានសមាមាត្ររៀងគ្នា ៤៤,៨%, ១៥,៦% និង ៣៩,៦% ក្នុងកន្ត្រកទំនិញប្រើប្រាស់។

អតិផរណាស្នូលបានថមថយមកត្រឹម ២,១% (២,៧% នៅឆ្នាំ២០១៩) ជាចម្បងដោយសារការថយល្បឿនកំណើនថ្លៃក្រុមភោជនីយដ្ឋាននៅពេលតម្រូវការបានធ្លាក់ចុះគួរកត់សម្គាល់ និងក្រុមភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ គួបផ្សំនឹងការថមថយកំណើនថ្លៃក្រុមសុខាភិបាល និងក្រុមគ្រឿងសង្ហារិម-សម្ភារប្រើប្រាស់គ្រួសារនិងការថែទាំផ្ទះជាប្រចាំ។

**ក្រាហ្វ ១០៖ អតិផរណារួម និងការរួមចំណែកក្នុងអតិផរណារួម**

(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ខែមករា ឆ្នាំ២០១៨ - ខែធ្នូ ឆ្នាំ២០២០ប៉ាន់ស្មាន)




**ក្រាហ្វ ១១ ៖ អតិផរណានៃក្រុមទាំងបី**

(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ខែមករា ឆ្នាំ២០១៨ - ខែធ្នូ ឆ្នាំ២០២០ប៉ាន់ស្មាន)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា (*ប៉ាន់ស្មាន)

- **អតិផរណាព្យាករណ៍ឆ្នាំ២០២១**[១១]

អតិផរណាសម្រាប់ឆ្នាំ២០២១ត្រូវបានព្យាករថាមានកម្រិត ២,៩% ដូចនឹងឆ្នាំ២០២០ ក្រោមការសន្មត៖ i/-កំណើនថ្លៃម្ហូបអាហារថមថយមកវិញ ដោយសារការថយចុះនៃការរំពឹងទុកពីកំណើនថ្លៃ និងភាពប្រសើរឡើងនៃការផ្គត់ផ្គង់ ស្របពេលដែលសន្ទស្សន៍ថ្លៃក្រុមម្ហូបអាហារមានកម្រិតខ្ពស់ស្រាប់នៅឆ្នាំ២០២០ (ដែលធ្វើឱ្យការគណនាបម្រែបម្រួលថ្លៃឆ្នាំលើឆ្នាំមានកម្រិតទាប) ii/-ថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ កើនឡើងវិញទៅតាមថ្លៃប្រេងឆៅពិភពលោកដោយសារការថយចុះនៃការរឹតត្បិតក្នុងការធ្វើដំណើរ និង iii/-អតិផរណាស្នូលកើនឡើងបន្តិចមកវិញទៅតាមនិន្នាការងើបឡើងវិញនៃកំណើនសកម្មភាពសេដ្ឋកិច្ច។

[១១] ការព្យាករត្រូវបានធ្វើឡើងដោយប្រើម៉ូឌែល ១/- Multiple regression ដែលសិក្សាពីទំនាក់ទំនងរវាងអតិផរណា និងសូចនាករសំខាន់មួយចំនួនរួមមាន អតិផរណានៅត្រីមាសមុន អតិផរណាដៃគូនាំចូល បម្រែបម្រួលថ្លៃប្រេងឥន្ធនៈពិភពលោក កំណើនឥណទាន និងបម្រែបម្រួលអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក។ ២/- ARIMA(p,d,q) ដែលធ្វើការព្យាករក្រុមទាំង ១២ នៅក្នុងកន្ត្រកទំនិញប្រើប្រាស់ ដោយផ្អែកលើតម្លៃគ្រាមុននិងគន្លងរបស់អថេរទាំងនោះ។ ៣/- VARX ដែលមានអត្រាអតិផរណា កំណើនឥណទាន បម្រែបម្រួលអត្រាប្តូរប្រាក់ អតិផរណាដៃគូនាំចូល និងដាក់ថ្លៃប្រេងជា exogenous variables ៤/- ARIMA (៣,១,៣) អត្រាអតិផរណាគ្រាមុនៗចំនួន ៣ ត្រីមាស និង ៥/- VARX ដែលព្យាករអតិផរណាស្នូល អតិផរណាក្រុមម្ហូបអាហារ និងអតិផរណាក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ។

**ក្រាហ្វ ១២ ៖ អតិផរណាព្យាករណ៍**

(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ឆ្នាំ២០១៩ - ២០២១)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា (ទិន្នន័យប៉ាន់ស្មាន ត្រី.៤ ឆ្នាំ២០២០)

## ៣- អត្រាប្តូរប្រាក់

អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកបន្តមានស្ថិរភាព ទោះជាបានថយថ្លៃបន្តិចប្រមាណ ០,៨% ធៀបនឹងឆ្នាំមុន ដោយមានកម្រិតជាមធ្យមក្នុងរង្វង់ ៤.០៩០ រៀលក្នុងមួយដុល្លារអាមេរិក (៤.០៦១ រៀល ឆ្នាំមុន)។ ការថយថ្លៃនេះមាននិន្នាការស្របនឹងស្ថានភាពក្នុងតំបន់ផងដែរ ដោយសារការថយចុះនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកនិងការថយចុះលំហូរមូលធនពីខាងក្រៅ។ ដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ធនាគារជាតិនៃកម្ពុជាបានផ្គត់ផ្គង់ប្រាក់រៀលទៅតាមស្ថានភាពទីផ្សារ តាមរយៈប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) និងការស្រូបយកប្រាក់រៀលដោយការបោះផ្សាយមូលបត្រអាចជួញដូរបាន (NCD)។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានផ្អាកជាបណ្តោះអាសន្ននៃការទិញប្រាក់ដុល្លារអាមេរិកពីគ្រឹះស្ថានធនាគារនិងអាជីវករប្តូរប្រាក់ ព្រមទាំងបានដេញថ្លៃលក់ប្រាក់ដុល្លារអាមេរិកដល់ទីផ្សារទៀតផង។

អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចូល (IREER) ត្រូវបានប៉ាន់ស្មានថាថយចុះ -១,១% ដែលបានជួយបន្ទាបសម្ពាធអតិផរណាពីការនាំចូល ដោយសារអត្រាអតិផរណានៅប្រទេសដៃគូនាំចូលមានកម្រិតទាបជាងកម្ពុជា បើទោះជាអត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចូល (INEER)[១២] បានកើនឡើងបន្តិចក៏ដោយ។ គួររំលេចថា INEER បានកើនឡើងបន្តិច ០,៣% ដោយសាររូបិយប័ណ្ណមួយចំនួន រួមមាន ប្រាក់យ៉ន់ចិន ដុងវៀតណាម ដុល្លារតៃវ៉ាន់ ដុល្លារហុងកុង និងយ៉េនជប៉ុន បានឡើងថ្លៃធៀបនឹងប្រាក់ដុល្លារអាមេរិក គួបផ្សំនឹងការថយថ្លៃនៃប្រាក់រៀលធៀបនឹងដុល្លារអាមេរិក។

អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចេញ (EREER) ត្រូវបានប៉ាន់ស្មានថាថយចុះបន្តិច -០,៥% ដែលបណ្តាលមកពីអត្រាអតិផរណានៅប្រទេសដៃគូនាំចេញមានកម្រិតទាបជាងកម្ពុជា[១៣] បើទោះជាអត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចេញ (ENEER)[១៤] បានកើនឡើងក៏ដោយ។ ការថយចុះនៃអត្រា EREER បង្ហាញថាឧត្តមភាពប្រកួតប្រជែងលើការនាំចេញរបស់កម្ពុជាថយចុះបន្តិច។

---

[១២] ប្រទេសដៃគូនាំចូលមកកម្ពុជាចម្បងៗរួមមាន៖ ចិន ថៃ វៀតណាម តៃវ៉ាន់ សិង្ហបុរី ជប៉ុន ហុងកុង កូរ៉េ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី និង សហរដ្ឋ-អាមេរិក។

[១៣] ប្រទេសដៃគូនាំចេញរបស់កម្ពុជាទាំងអស់មានអត្រាអតិផរណាទាបជាងកម្ពុជា លើកលែងប្រទេសវៀតណាម។

[១៤] ប្រទេសគោលដៅនាំចេញរបស់កម្ពុជាជាចម្បងៗរួមមាន៖ សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស អាល្លឺម៉ង់ ជប៉ុន កាណាដា ចិន ថៃ អេស្ប៉ាញ បែលហ្ស៊ិក បារាំង ហូឡង់ វៀតណាម ហុងកុង អ៊ីតាលី។

ក្រាហ្វ ១៣ ៖ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក
(រៀលក្នុង១ដុល្លារអាមេរិក, ខែមករា ឆ្នាំ២០១៥ - ខែធ្នូ ឆ្នាំ២០២០)




ក្រាហ្វ ១៤ ៖ អត្រាប្តូរប្រាក់ប្រសិទ្ធភាព
(សន្ទស្សន៍ ២០១៥=១០០, ឆ្នាំ២០១៥ - ២០២០ប៉ាន់ស្មាន)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៤- ស្ថានភាពជញ្ជីងទូទាត់[១៥]

ជញ្ជីងទូទាត់ត្រូវបានប៉ាន់ស្មានថានឹងបន្តមានអតិរេក ១,៧% នៃផ.ស.ស. (៤៧៦ លានដុល្លារអាមេរិក) ធៀបនឹង ៩,៨% ឆ្នាំមុន ដែលគាំទ្រដោយលំហូរទុនវិនិយោគផ្ទាល់បរទេស និងការនាំចេញ។

ក្រាហ្វ ១៥ ៖ ជញ្ជីងទូទាត់កម្ពុជា
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១០ - ២០២០ប៉ាន់ស្មាន)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### - គណនីចរន្ត និងដើមទុន

គណនីចរន្តត្រូវបានប៉ាន់ស្មានថាមានឱនភាព ៧,៦% នៃផ.ស.ស. (២,១ ប៊ីលានដុល្លារអាមេរិក) ធៀបនឹង ១៥% នៃផ.ស.ស. ឆ្នាំមុនដោយសារការធ្លាក់ចុះឱនភាពពាណិជ្ជកម្មទំនិញ និងចំណូលបឋម ខណៈដែលគណនីសេវាសុទ្ធមានឱនភាព[១៦] និងចំណូលបន្ទាប់បន្សំបានថយចុះ[១៧]។ ដោយឡែក គណនីដើមទុនមានលំហូរចូលសុទ្ធត្រឹមតែ ២៥៩ លានដុល្លារអាមេរិក ដែលបានធ្លាក់ចុះ -២៧% ធៀបនឹង ៣៥៥ លានដុល្លារអាមេរិក ឆ្នាំមុន។

---

[១៥] ស្ថិតិជញ្ជីងទូទាត់កម្ពុជាត្រូវបានចងក្រងផ្អែកតាមវិធីសាស្រ្តចងក្រងស្ថិតិជញ្ជីងទូទាត់បោះពុម្ពលើកទី៦ (BPM6) របស់មូលនិធិរូបិយវត្ថុអន្តរជាតិ។

[១៦] គណនីសេវាសុទ្ធ បានធ្លាក់ចុះ -១០៩% (ឆ្នាំលើឆ្នាំ) ដែលបានធ្វើឱ្យអតិរេកគណនីសេវាសុទ្ធប្តូរទៅជាឱនភាពគណនីសេវាសុទ្ធវិញ ជាចម្បងដោយសារការធ្លាក់ចុះចំណូលពីសេវាធ្វើដំណើរ -៧៩% ដែលបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ បានធ្វើឱ្យចំនួនភ្ញៀវទេសចរសរុបធ្លាក់ចុះ -៧៨%។

[១៧] អតិរេកគណនីចំណូលបន្ទាប់បន្សំបានធ្លាក់ចុះ -១៥% ជាចម្បងបណ្តាលមកពីការធ្លាក់ចុះប្រាក់បង្វែររបស់ពលករពីក្រៅប្រទេស -១៥% និងប្រាក់ជំនួយរបស់រាជរដ្ឋាភិបាល -១៧%។




**ក្រាហ្វ ១៦ ៖ គណនីចរន្ត និងដើមទុន**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១០ - ២០២០ប៉ាន់ស្មាន)

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ជញ្ជីងពាណិជ្ជកម្មទំនិញបន្តមានឱនភាព ប៉ុន្តែបានថយចុះគួរឱ្យកត់សម្គាល់មកត្រឹម -៩,៧% នៃផ.ស.ស. (ធៀបនឹង -២៦,៧% នៃផ.ស.ស. ឆ្នាំមុន) ដែលបណ្តាលមកពីការកើនឡើងការនាំចេញ ស្របពេលដែលការនាំចូលបានថយចុះ។ ការនាំចេញសរុបបានកើនឡើង ១៥,៩% (ធៀបនឹងឆ្នាំមុន ១៥,៦%) ជាចម្បងបណ្តាលមកពីការកើនឡើងការនាំចេញផលិតផលផ្សេងៗក្រៅពីកាត់ដេរ (៧៦,៧%) ក្នុងនោះមានការកើនឡើងការនាំចេញ មាស (៦,៩ ដង) គ្រឿងអេឡិចត្រូនិក (១,៥ដង) ទោចក្រយាន (២៦%) អង្ករ (១៦,៧%) និងកៅស៊ូ (២,៦%) ខណៈដែលការនាំចេញផលិតផលកាត់ដេរបានធ្លាក់ចុះ (-៧,៨%)[១៨]។ ការនាំចូលសរុបបានថយចុះ -១០,១% ធៀបនឹងឆ្នាំមុន (កើន ១៨,៣%) ជាចម្បងដោយសារការថយចុះការនាំចូលវត្ថុធាតុដើមសម្រាប់វិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើង (-៩,៥%) សម្ភារសំណង់ (-១០,៨%) យានយន្ត (-២៥%) និងប្រេងឥន្ធនៈ (-១៥,៣%) ស្របពេលដែលការនាំចូលម្ហូបអាហារនិងភេសជ្ជៈបានកើនឡើង (១,១%)។

ក្រៅពីឱនភាពជញ្ជីងពាណិជ្ជកម្មទំនិញ ការថយចុះឱនភាពចំណូលបឋម (-២,២% នៃផ.ស.ស.) ក៏បានរួមចំណែកក្នុងការថយចុះឱនភាពគណនីចរន្តផងដែរ ខណៈដែលអតិរេកចំណូលបន្ទាប់បន្សំបានថយចុះ (-១,១% នៃផ.ស.ស.) និងអតិរេកគណនីសេវាសុទ្ធបានប្តូរមកជាឱនភាពគណនីសេវាសុទ្ធវិញ។

- **គណនីហិរញ្ញវត្ថុ**[១៩]

លំហូរវិនិយោគផ្ទាល់បរទេសមកកម្ពុជាមានភាពថមថយ ប៉ុន្តែអាចជួយឱ្យគណនីហិរញ្ញវត្ថុបន្តមានអតិរេក និងផាត់ទាត់ឱនភាពគណនីចរន្ត ព្រមទាំងបន្តគរពូនទុនបម្រុងអន្តរជាតិ។ គណនីហិរញ្ញវត្ថុត្រូវបានប៉ាន់ស្មានថាមានទ្រព្យអកម្មបរទេសសុទ្ធ ២.៩៩២ លានដុល្លារអាមេរិក បានថយចុះ -៥៣% ធៀបនឹងឆ្នាំ២០១៩។ ការថយចុះនេះ ជាចម្បងបណ្តាលមកពី គណនីវិនិយោគផ្សេងទៀត

---

[១៨] ក្នុងនោះមាន ការនាំចេញសម្លៀកបំពាក់ បានធ្លាក់ចុះ -១០,៩% ស្បែកជើង -៦,៦% និងផលិតផលកាត់ដេរផ្សេងទៀតបានកើនឡើង ១១%។

[១៩] មានទ្រព្យសកម្មបរទេសសុទ្ធ មានន័យថា មានលំហូរចេញសុទ្ធ។ មានទ្រព្យអកម្មបរទេសសុទ្ធមានន័យថា មានលំហូរចូលសុទ្ធ។

បានប្តូរពីសមតុល្យទ្រព្យអកម្មបរទេសសុទ្ធ ២.៨២១ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩ ទៅជាទ្រព្យសកម្មបរទេសសុទ្ធ[២០] ១៧៨ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២០ នេះ។ ទន្ទឹមនេះ គណនីវិនិយោគផ្ទាល់សុទ្ធមានទ្រព្យអសកម្មសុទ្ធ ៣.១៥៨ លានដុល្លារអាមេរិក បានថយចុះ -១១,៣% បើធៀបនឹងឆ្នាំ២០១៩។

**ក្រាហ្វ ១៧ ៖ គណនីហិរញ្ញវត្ថុ**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១០ - ២០២០ប៉ាន់ស្មាន)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

វិនិយោគផ្ទាល់បរទេសនៅកម្ពុជាត្រូវបានប៉ាន់ស្មានមាន ៣,២ ប៊ីលានដុល្លារអាមេរិក (១១,៩% នៃផ.ស.ស.) ទាបជាងគ្រាដូចគ្នាឆ្នាំមុន ដែលមាន ៣,៦ ប៊ីលានដុល្លារអាមេរិក (១៣,១% នៃផ.ស.ស) ជាចម្បងបណ្តាលមកពីការថយចុះវិនិយោគលើវិស័យធនាគារ (-១៤,២%) និងវិស័យមិនមែនធនាគារ (-៩,៨%)[២១]។ វិនិយោគផ្ទាល់បរទេសលើវិស័យធនាគារនៅតែឈរនៅលំដាប់ទី១ ដែលមានសមាមាត្រ ៣២,៧% នៃវិនិយោគផ្ទាល់បរទេសសរុប ខណៈការវិនិយោគលើវិស័យកាត់ដេរសម្លៀកបំពាក់មាន ៨,៨% វិស័យកាត់ដេរស្បែកជើងមាន ១,៩% និងវិស័យផលិតផលធ្វើដំណើរមាន ៤,១% នៃវិនិយោគផ្ទាល់បរទេសសរុប។

## ៥- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

ទុនបម្រុងអន្តរជាតិបានកើនឡើងប្រមាណ ១៥% ធៀបនឹងឆ្នាំមុន បើទោះបីជាទីផ្សារហិរញ្ញវត្ថុពិភពលោក បានទទួលរងផលប៉ះពាល់ខ្លាំងពីវិបត្តិនៃការរីករាលដាលជំងឺកូវីដ-១៩ ក៏ដោយ។ ទុនបម្រុងអន្តរជាតិបានកើនឡើងដល់ប្រមាណ ២១,៣ ប៊ីលានដុល្លារអាមេរិក ស្មើនឹងជាង១០ខែនៃការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់ ខ្ពស់ជាងកម្រិតអប្បបរមាសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ (៣ខែ)។ កម្រិតខ្ពស់នៃទុនបម្រុងអន្តរជាតិបានអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងអត្រាប្តូរប្រាក់ ផ្គត់ផ្គង់តម្រូវការសន្ទនីយភាពក្នុងស្រុកដើម្បីរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ គរពូនទ្រព្យសម្បត្តិជាតិ និងបង្កើនជំនឿទុកចិត្តមកលើប្រទេស។

---

[២០] ជាលទ្ធផលពីការកើនឡើងទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ(៣ដង,១) និងអង្គភាពគ្រួសារ(៣ដង,៦) ខណៈកម្ចីរាជរដ្ឋាភិបាលកើនឡើង ៤៥%។

[២១] ជាចម្បងបណ្តាលមកពីការថយចុះការវិនិយោគមកកម្ពុជាគ្រប់វិស័យចម្បងៗ រួមមាន i/-វិស័យកម្មន្តសាល ថយចុះ -១០% ii/-វិស័យសណ្ឋាគារនិងការកម្សាន្ត ថយចុះ -៨% iii/-វិស័យអចលនទ្រព្យ ថយចុះ -១៨% iv/-វិស័យសំណង់ ថយចុះ -២% និង v/-វិស័យកសិកម្ម ថយចុះ -១៣% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

**ក្រាហ្វ ១៨ ៖ ទុនបម្រុងអន្តរជាតិ និងចំនួនខែនៃការនាំចូលទំនិញនិងសេវាគ្រាបន្ទាប់**

(ឆ្នាំ២០០៨ - ២០២០)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ការគ្រប់គ្រងទុនបម្រុងអន្តរជាតិរបស់ធនាគារជាតិនៃកម្ពុជា ត្រូវបានអនុវត្តយ៉ាងប្រុងប្រយ័ត្ន ដោយគោរពតាមសេចក្តីណែនាំការវិនិយោគ និងរក្សាបានតាមគោលការណ៍លំដាប់អាទិភាព៖ i/-ការរក្សាដើមទុន ii/-សន្ទនីយភាព និង iii/-ចំណូល។ ការអូសបន្លាយនៃបញ្ហាវិបត្តិសុខភាពពិភពលោកបានធ្វើឱ្យទីផ្សារហិរញ្ញវត្ថុពិភពលោកប្រែប្រួលខ្លាំង ដែលបានបង្កជាបញ្ហាប្រឈម និងហានិភ័យថ្មីៗសម្រាប់ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ។ ដើម្បីធានាបានការវិនិយោគទុនបម្រុងប្រកបដោយប្រសិទ្ធភាព ហានិភ័យនៃការវិនិយោគត្រូវបានគ្រប់គ្រង និងតាមដានយ៉ាងហ្មត់ចត់ ព្រមទាំងធានាថាការវិនិយោគត្រូវស្ថិតនៅក្នុងកម្រិតហានិភ័យដែលបានកំណត់។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បាននិងកំពុងសិក្សាជាមួយបណ្តាដៃគូវិនិយោគ លើការអនុវត្តតាមគោលនយោបាយ វិនិយោគប្រកបដោយការទទួលខុសត្រូវទៅលើបរិស្ថាន សង្គម និងអភិបាលកិច្ចល្អ ក្នុងគោលដៅពង្រឹងចីរភាព សុវត្ថិភាពការវិនិយោគទុនបម្រុង និងស្របតាមនិន្នាការនៃការវិនិយោគសកលប្រកបដោយការទទួលខុសត្រូវដែលបានបង្កើតឡើងដោយវិនិយោគិនជាស្ថាប័នហិរញ្ញវត្ថុធំៗ និងធនាគារកណ្តាលមួយចំនួននៅក្នុងពិភពលោក។

## III- ការគ្រប់គ្រងរូបិយវត្ថុ

### ១- ស្ថានភាពរូបិយវត្ថុ

រូបិយវត្ថុទូទៅ (M2) បានកើនឡើង ១៤,៧% ទាបជាងកំណើនឆ្នាំមុន (១៨,២%) និងមធ្យមរយៈពេល៥ឆ្នាំចុងក្រោយ (២១%)។ ការថមថយល្បឿនកំណើននេះបណ្តាលមកពីកំណើនទាបជាងមុននៃរូបិយវត្ថុក្នុងចរាចរណ៍ និងប្រាក់បញ្ញើសរុបរបស់និវាសជន (ទាំងជាប្រាក់ដុល្លារអាមេរិកនិងប្រាក់រៀល) ក្នុងអត្រា ១១,៥% និង ១៥% រៀងគ្នា ធៀបនឹងកំណើនឆ្នាំមុន ៣២,១% និង ១៦,៨%។ កំណើនទាបនៃរូបិយវត្ថុក្នុងចរាចរណ៍បណ្តាលមកពីការផ្អាកធ្វើអន្តរាគមន៍ទិញប្រាក់ដុល្លារអាមេរិកចាប់ពីខែឧសភា ឆ្នាំ២០២០មក គួបផ្សំនឹងការឆ្លើយតបនឹងតម្រូវការខ្ពស់លើប្រាក់រៀលក្នុងឆ្នាំ២០១៩ ទោះបីជាប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) បានកើនឡើង ២៤,៥% ក៏ដោយ។

គួររំលេចថា កម្រិតដុល្លារូបនីយកម្មដែលវាស់តាមអនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងរូបិយវត្ថុទូទៅ (FCD/M2) បន្តស្ថិតក្នុងកម្រិតខ្ពស់ ៨៣,៨% (ធៀបនឹងឆ្នាំមុន ៨៤,១%)។ ប្រាក់រៀលក្នុងចរាចរណ៍មានសមាមាត្រ ៩,៨% (៣,២ ប៊ីលានដុល្លារអាមេរិក) នៃរូបិយវត្ថុទូទៅ ប្រាក់បញ្ញើជារៀលមានសមាមាត្រ ៧,៧% នៃប្រាក់បញ្ញើសរុប ហើយឥណទានជារៀលមានសមាមាត្រ ១២,៨% នៃសំពៀតឥណទានសរុប។

**ក្រាហ្វ ១៩ ៖ សមាសធាតុ និងកំណើនរូបិយវត្ថុទូទៅ**
(ឆ្នាំ២០០៩ - ២០២០ប៉ាន់ស្មាន)




**ក្រាហ្វ ២០ ៖ ប្រាក់បញ្ញើជារៀល និងរូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើ**
(ឆ្នាំ២០០៩ - ២០២០ប៉ាន់ស្មាន)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ២- ការអនុវត្តគោលនយោបាយរូបិយវត្ថុ

### ក-ការធ្វើអន្តរាគមន៍ទីផ្សារប្តូរប្រាក់

ដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់ក្នុងស្ថានភាព ដែលសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកថយចុះ និងវិស័យខាងក្រៅរងការធ្លាក់ចុះយ៉ាងខ្លាំង ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍លក់ប្រាក់ដុល្លារអាមេរិក ៨០,២ លានដុល្លារអាមេរិក (៤លើក) ទៅគ្រឹះស្ថានធនាគារនិងអាជីវករប្តូរប្រាក់ និងបានលក់ប្រាក់រៀល ឆ្លើយតបនឹងតម្រូវការចំនួន ៦៩,៥ប៊ីលានរៀល (១៧លានដុល្លារអាមេរិក)។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បានលក់ប្រាក់ដុល្លារអាមេរិកសុទ្ធ ១៤៧,១ លានដុល្លារអាមេរិក (ទិញមាន ៨០,៣ លានដុល្លារអាមេរិក) ទៅស្ថាប័នរដ្ឋ។ ការធ្វើអន្តរាគមន៍ទាំងនេះបានកាត់បន្ថយនិន្នាការថយថ្លៃប្រាក់រៀល និងបានរក្សាតម្លៃប្រាក់រៀលឱ្យមានស្ថិរភាពល្អ ដែលរួមចំណែកក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។

**ក្រាហ្វ ២១ ៖ អន្តរាគមន៍ទិញប្រាក់ដុល្លារអាមេរិកពីធនាគារនិងអាជីវករប្តូរប្រាក់**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១១ - ២០២០)




**ក្រាហ្វ ២២ ៖ អន្តរាគមន៍ទិញលក់ប្រាក់ដុល្លារអាមេរិកជាមួយស្ថាប័នរដ្ឋ**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១១ - ២០២០)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ប្រអប់២៖ ឥទ្ធិពលនៃអន្តរាគមន៍លក់ប្រាក់ដុល្លារអាមេរិក និងបម្រែបម្រួលអត្រាប្តូរប្រាក់រៀល**

ដើម្បីរួមចំណែករក្សាស្ថិរភាពប្រាក់រៀល នៅចុងខែតុលានិងដើមខែវិច្ឆិកា ធនាគារជាតិនៃកម្ពុជា បានធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ ដោយលក់ប្រាក់ដុល្លារអាមេរិកចំនួន៤លើកមានទឹកប្រាក់សរុប ៨០,២ លានដុល្លារអាមេរិក (លើកទី១ ថ្ងៃទី២១ តុលា=៣០,២ លានដុល្លារអាមេរិក លើកទី២ ថ្ងៃទី២៦ តុលា=២០ លានដុល្លារអាមេរិក លើកទី៣ ថ្ងៃទី៤ វិច្ឆិកា=១៥ លានដុល្លារអាមេរិក និងលើកទី៤ ថ្ងៃទី៦ វិច្ឆិកា=១៥ លានដុល្លារអាមេរិក)។

- ការធ្វើអន្តរាគមន៍លើកទី១ បានធ្វើឱ្យប្រាក់រៀលឡើងថ្លៃ ១០ រៀលនៅថ្ងៃអន្តរាគមន៍ និង ១៨ រៀលនៅថ្ងៃបន្ទាប់ (ធៀបនឹងថ្ងៃមុនអន្តរាមន៍១ថ្ងៃ)។
- អន្តរាគមន៍លើកទី២បានធ្វើឱ្យប្រាក់រៀលឡើងថ្លៃចំនួន ៩រៀលនៅថ្ងៃអន្តរាគមន៍ និង ១៣រៀលនៅថ្ងៃបន្ទាប់
- អន្តរាគមន៍លើកទី៣ បានធ្វើឱ្យប្រាក់រៀលឡើងថ្លៃ ១ រៀលប៉ុណ្ណោះនៅថ្ងៃអន្តរាគមន៍ និងស្ថិតនៅកម្រិតដដែលនៅថ្ងៃបន្ទាប់
- អន្តរាគមន៍លើកទី៤ ពុំបានធ្វើឱ្យប្រាក់រៀលឡើងថ្លៃនៅថ្ងៃអន្តរាគមន៍នោះទេ ប៉ុន្តែបានធ្វើឱ្យប្រាក់រៀលឡើងថ្លៃ ៧ រៀលនៅថ្ងៃបន្ទាប់។

## ការលក់ប្រាក់ដុល្លារអាមេរិក, LPCO ដេញថ្លៃឈ្នះ និងបម្រែបម្រួលអត្រាប្តូរប្រាក់រៀល

(ទំហំទឹកប្រាក់គិតជាលានដុល្លារអាមេរិក (ស្តាំ) និង អត្រាប្តូរប្រាក់គិតជារៀលក្នុង១ដុល្លារអាមេរិក)




## ការឡើងថ្លៃនៃប្រាក់រៀល (គិតជារៀល) ក្រោយអន្តរាគមន៍លក់ចេញប្រាក់ដុល្លារអាមេរិក

| កាលបរិច្ឆេទ | ទំហំទឹកប្រាក់លក់ USD (គិតជាលានដុល្លារអាមេរិក) | ការឡើងថ្លៃនៃប្រាក់រៀល Dថ្ងៃ ក្រោយការលក់ចេញប្រាក់ដុល្លារអាមេរិក | | | | |
|---|---|---|---|---|---|---|
| | | D = ០ថ្ងៃ | D = ១ថ្ងៃ | D = ៣ថ្ងៃ | D =៧ថ្ងៃ | D =១៤ថ្ងៃ |
| ២១ តុលា | ៣០,២ | ១០ | ១៨ | ១៧ | ២១ | ២១ |
| ២៦ តុលា | ២០ | ៩ | ១៣ | ៩ | ៧ | ៩ |
| ៤ វិច្ឆិកា | ១៥ | ១ | ១ | ៤ | ៧ | ១២ |
| ៦ វិច្ឆិកា | ១៥ | ០ | ៧ | ៧ | ១០ | ១២ |
| **សរុប** | **៨០,២** | **២០** | **៤៧** | **៣៧** | **៤៥** | **៥៤** |

## ការឡើងថ្លៃនៃប្រាក់រៀលក្រោយផាត់ទាត់កត្តារដូវកាល (គិតជារៀល) ក្រោយអន្តរាគមន៍លក់ចេញប្រាក់ដុល្លារអាមេរិក

| កាលបរិច្ឆេទ | ទំហំទឹកប្រាក់លក់ USD (គិតជាលានដុល្លារអាមេរិក) | ការឡើងថ្លៃនៃប្រាក់រៀល Dថ្ងៃ ក្រោយការលក់ចេញប្រាក់ដុល្លារអាមេរិក (ឥទ្ធិពលក្រោយផាត់ទាត់កត្តារដូវកាល ដោយយកឆ្នាំ២០១៨ជាឆ្នាំគោល) | | | | |
|---|---|---|---|---|---|---|
| | | D = ០ថ្ងៃ | D = ១ថ្ងៃ | D = ៣ថ្ងៃ | D =៧ថ្ងៃ | D =១៤ថ្ងៃ |
| ២១ តុលា | ៣០,២ | ១០ | ១៨ | ១៨ | ២៣ | ១៤ |
| ២៦ តុលា | ២០ | ៩ | ៩ | ៤ | -៧ | -១២ |
| ៤ វិច្ឆិកា | ១៥ | ២ | ៤ | ១០ | ១២ | ១៥ |
| ៦ វិច្ឆិកា | ១៥ | ៤ | ១៣ | ១១ | ១១ | ១២ |
| **សរុប** | **៨០,២** | **២៥** | **៤៤** | **៤៣** | **៣៨** | **២៩** |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ខ- អត្រាប្រាក់បម្រុងកាតព្វកិច្ច

ធនាគារជាតិនៃកម្ពុជាបានទម្លាក់អត្រាប្រាក់បម្រុងកាតព្វកិច្ចជារៀល និងជាដុល្លារអាមេរិក មកត្រឹម ៧% ចាប់ពីខែមេសា ឆ្នាំ២០២០ ពីកម្រិត ៨% ចំពោះប្រាក់រៀល និង ១២,៥% ចំពោះរូបិយប័ណ្ណបរទេស ដើម្បីផ្តល់សន្ទនីយភាពបន្ថែមដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ កម្រិតខ្ពស់នៃសន្ទនីយភាពបានផ្តល់ភាពអំណោយផលដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការគ្រប់គ្រងហានិភ័យសន្ទនីយភាពបានយ៉ាងប្រសើរ, ផ្តល់លទ្ធភាពបង្កើនឥណទាន និងផ្តល់ការអនុគ្រោះនានាដល់អតិថិជនដែលទទួលរងផលប៉ះពាល់ពីឥទ្ធិពលនៃជំងឺកូវីដ-១៩។

**ក្រាហ្វ ២៣ ៖ ទំហំនិងអត្រាប្រាក់បម្រុងកាតព្វកិច្ច**

(ឆ្នាំ១៩៩៣ - ២០២០)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### គ-មូលបត្រអាចជួញដូរបាន (NCD)

មូលបត្រអាចជួញដូរបាន បានបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ការចេញផ្សាយ NCD ចារឹកជាដុល្លារអាមេរិកមាន ៣០,៨ ប៊ីលានដុល្លារអាមេរិក ដែលបានកើនឡើង ៩៥,៣% ធៀបនឹងឆ្នាំមុន ដោយសារគ្រឹះស្ថានធនាគារមានសន្ទនីយភាពខ្ពស់។ ចំណែកឯ ការចេញផ្សាយ NCD ចារឹកជារៀលមាន ១០,៩ ទ្រីលានរៀល ដោយបានកើនឡើងត្រឹម ៤% ប៉ុណ្ណោះ។ ទន្ទឹមនេះ អត្រាការប្រាក់ NCD ត្រូវបានកាត់បន្ថយ ក្នុងគោលបំណងជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបង្វែរសន្ទនីយភាពពីការទិញ NCD ទៅផ្តល់ឥណទានសម្រាប់គាំទ្រសកម្មភាពសេដ្ឋកិច្ច ដែលបាននិងកំពុងទទួលរងផលប៉ះពាល់ពីវិបត្តិសុខភាពពិភពលោក។

**ក្រាហ្វ ២៤ ៖ អត្រាការប្រាក់ NCD ចារឹកជាប្រាក់ដុល្លារអាមេរិក និងជាប្រាក់រៀល**

(គិតជាភាគរយ, អត្រាមធ្យមប្រចាំឆ្នាំ២០២០)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ២៥ ៖ NCD ចារឹកជាប្រាក់ដុល្លារអាមេរិកដែលបានចេញផ្សាយ និងមិនទាន់ដល់ឥណប្រតិទាន**
(លានដុល្លារអាមេរិក, ឆ្នាំ២០១៥ - ២០២០)




**ក្រាហ្វ ២៦ ៖ NCD ចារឹកជាប្រាក់រៀលដែលបានចេញផ្សាយ និងមិនទាន់ដល់ឥណប្រតិទាន**
(ប៊ីលានរៀល, ឆ្នាំ២០១៥ - ២០២០)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ឃ-ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)

ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) បានផ្តល់សន្ទនីយភាពជាប្រាក់រៀលដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានតម្រូវការប្រាក់រៀល ក្នុងអត្រាការប្រាក់ទាបសមស្របដើម្បីគាំទ្រដល់ការប្រើប្រាស់ប្រាក់រៀលនិងវិស័យដែលប្រើប្រាស់ប្រាក់រៀលច្រើនជាពិសេសវិស័យកសិកម្ម។ ប្រតិបត្តិការ LPCO ត្រូវបានធ្វើឡើងចំនួន ២៣ លើក ដែលបានផ្តល់សន្ទនីយភាពជាប្រាក់រៀលសរុប ៥,៩ ទ្រីលានរៀល ដោយបានកើនឡើង ២៨,៥% ធៀបនឹងឆ្នាំមុន ជាមួយនឹងអត្រាការប្រាក់ដេញថ្លៃឈ្នះជាមធ្យម ៣,០៣% សម្រាប់ឥណប្រតិទាន៣ខែ ៣,៤៤% សម្រាប់ឥណ-ប្រតិទាន៦ខែ និង ៣,៧៧% សម្រាប់ឥណប្រតិទាន១ឆ្នាំ។ ទំហំទឹកប្រាក់ប្រតិបត្តិការ LPCO ដែលមិនទាន់ដល់ឥណប្រតិទានមាន ៣,៩ ទ្រីលានរៀល គិតត្រឹមចុងខែធ្នូ ឆ្នាំ២០២០។ គួររំលេចថាអត្រាការប្រាក់ដេញថ្លៃអប្បបរមា LPCO ត្រូវបានកាត់បន្ថយ ០,៥% គ្រប់ឥណប្រតិទានទាំងអស់ដើម្បីរួមចំណែកកាត់បន្ថយថ្លៃដើមនៃកម្ចីរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សំដៅរួមចំណែកបន្ថយអត្រាការប្រាក់ឥណទានជារៀលពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដល់អតិថិជន។

**ក្រាហ្វ ២៧ ៖ ការផ្តល់សន្ទនីយភាពជារៀលតាមរយៈប្រតិបត្តិការ LPCO ប្រចាំខែ**
(គិតជាប៊ីលានរៀល, ខែមករា - ខែធ្នូ ឆ្នាំ២០២០)




**ក្រាហ្វ ២៨ ៖ ការផ្តល់សន្ទនីយភាពជារៀលតាមរយៈ: ប្រតិបត្តិការ LPCO ប្រចាំឆ្នាំ**
(គិតជាប៊ីលានរៀល, ឆ្នាំ២០១៧ - ២០២០ប៉ាន់ស្មាន)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## IV- ស្ថានភាពប្រព័ន្ធធនាគារនៅកម្ពុជា

### ១- ស្ថានភាពទូទៅ

ប្រព័ន្ធធនាគារកម្ពុជាមានធនាគារពាណិជ្ជ ៥២ ធនាគារឯកទេស ១៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន ៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៧៥ គ្រឹះស្ថានឥណទានជនបទ ២៤៦ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ១៥ អ្នកដំណើរការតតិយភាគី ៤ គ្រឹះស្ថានផ្តល់សេវាទូទាត់ ២៤ ក្រុមហ៊ុនចែករំលែកព័ត៌មានឥណទាន ១ ការិយាល័យតំណាងធនាគារបរទេស ៦ និងអាជីវកម្មប្តូរប្រាក់ ២.៨៨៩។

ទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារមានកំណើន ១៥,៧% (ដល់ ២៤០,៨ ទ្រីលានរៀល ស្មើនឹង ៥៩,៤ ប៊ីលានដុល្លារអាមេរិក) ក្នុងនោះឥណទានអតិថិជនកើន ១៤,៨% (ដល់ ១៥១,៣ ទ្រីលានរៀល ស្មើនឹង ៣៧,៣ ប៊ីលានដុល្លារអាមេរិក)។ ប្រាក់បញ្ញើអតិថិជនមានកំណើន ១៥,៤% (ដល់ ១៣៦,៩ ទ្រីលានរៀល ស្មើនឹង ៣៣,៨ ប៊ីលានដុល្លារអាមេរិក) និងដើមទុនមានកំណើន ១០,៤% (ដល់ ២៥,៧ ទ្រីលានរៀល ស្មើនឹង ៦,៣ ប៊ីលានដុល្លារអាមេរិក)។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបន្តលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ដោយចំនួនគណនីប្រាក់បញ្ញើអតិថិជនកើនដល់ ៨,៩ លានគណនី និងគណនីឥណទានអតិថិជនកើនដល់ ៣,២ លានគណនី។ ទីស្នាក់ការកណ្តាល និងសាខានៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានចំនួន ២.៥២៧ និងមានម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ (ATM) ចំនួន ៣.១៦៨។ លើសពីនេះ ដើម្បីរួមចំណែកជួយសម្រាលបន្ទុកប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានផ្តល់ការអនុគ្រោះដល់អ្នកខ្ចីប្រាក់ តាមរយៈការរៀបចំឥណទានឡើងវិញចំនួន ២៨៥.០៧៤ គណនី ស្មើនឹង ១៦,៨ ទ្រីលានរៀល (៤,២ ប៊ីលានដុល្លារអាមេរិក)។

**ក្រាហ្វ ២៩៖ ចំនួនប្រាក់បញ្ញើ និងឥណទានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ**
(គិតជាប៊ីលានរៀល, ឆ្នាំ២០១៤ - ២០២០ប៉ាន់ស្មាន)




**ក្រាហ្វ ៣០៖ ចំនួនគណនីប្រាក់បញ្ញើ និងគណនីឥណទានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ**
(គិតជាគណនី, ឆ្នាំ២០១៤ - ២០២០ប៉ាន់ស្មាន)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ២- វិស័យធនាគារ

ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារបានកើនឡើង ១៦,២% (ដល់ ២០៥,៣ ទ្រីលានរៀល ស្មើនឹង ៥០,៧ ប៊ីលានដុល្លារអាមេរិក) ដែលឥណទានអតិថិជនកើន ១៥,៣% (ដល់ ១២២,៤ ទ្រីលានរៀល ស្មើនឹង ៣០,២ ប៊ីលានដុល្លារអាមេរិក) ដោយមានចំនួន ១,២ លានគណនី។ ឥណទានត្រូវបានផ្តល់ទៅកាន់វិស័យសេដ្ឋកិច្ចសំខាន់ៗ ដូចជា៖ ការជួញដូររាយ (១៥,៥%) នៃឥណទានសរុប) ការឱ្យខ្ចីទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន (១២,៨%) ការជួញដូរដុំ (៩,៧%) ការឱ្យខ្ចីជាបុគ្គល (៩,៨%) សំណង់ (៩,២%) ការជួញដូរអចលនទ្រព្យ (៨,៤%) កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (៧,៧%) និងផ្សេងៗ (២៦,៩%)។ ប្រាក់បញ្ញើបានកើនឡើង ១៥,៥% (ដល់ ១២១,៧ ទ្រីលានរៀល ស្មើនឹង ៣០,០ ប៊ីលានដុល្លារអាមេរិក) និងមានចំនួន ៦,៣ លានគណនី។ ទីស្នាក់ការកណ្តាលនិងសាខានៃគ្រឹះស្ថានធនាគារមាន ១.៣១៦ និងម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ (ATM) មាន ២.៨០៨។ ជាមួយគ្នានេះ គ្រឹះស្ថានធនាគារបានផ្តល់ការអនុគ្រោះដល់អ្នកខ្ចីប្រាក់ តាមរយៈការរៀបចំឥណទានឡើងវិញចំនួន ៤៣.២៩១ គណនី ស្មើនឹង ១២.២១៤,៩ ប៊ីលានរៀល (៣.០១៧,៥លានដុល្លារអាមេរិក) ដោយក្នុងនោះមាន៖

- វិស័យទេសចរណ៍ ៤.២៥៨ គណនី ស្មើនឹង ៣.២៥២,៨ ប៊ីលានរៀល (៨០៣,៦ លានដុល្លារអាមេរិក)
- វិស័យកាត់ដេរ ២.៣៩២ គណនី ស្មើនឹង ១៧៤,៦ ប៊ីលានរៀល (៤៣,១ លានដុល្លារអាមេរិក)
- វិស័យសំណង់ ៧.៥៧០ គណនី ស្មើនឹង ១.៩៣០,៧ ប៊ីលានរៀល (៤៧៧ លានដុល្លារអាមេរិក)
- វិស័យដឹកជញ្ជូននិងឡជីស្ទីក ២.៨៩៣ គណនី ស្មើនឹង ៤៨៨,២ ប៊ីលានរៀល (១២០,៦ លានដុល្លារអាមេរិក) និង
- វិស័យផ្សេងៗ ២៦.១៧៨ គណនី ស្មើនឹង ៦.៣៦៨,៦ប៊ីលានរៀល (១.៥៧៣,៣ លានដុល្លារអាមេរិក)។

អត្រាការប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារជារៀលបានថយចុះបន្តិចដល់ ៥,៩៣% ធៀបនឹង ៦,៣៥% ក្នុងឆ្នាំ២០១៩ ខណៈប្រាក់បញ្ញើជាដុល្លារអាមេរិក មានអត្រា ៤,៩៣% ប្រហាក់ប្រហែលនឹងឆ្នាំមុន (៤,៨៣%)។ អត្រាការប្រាក់ឥណទានជារៀលនិងជាដុល្លារអាមេរិកបានកើនឡើងដល់ ១១,៥៩% និង ៩,៨៨% ធៀបនឹងឆ្នាំ២០១៩ (១០,៤៧% និង ៨,៧៧% រៀងគ្នា)។

**ក្រាហ្វ ៣១៖ ឥណទានគ្រឹះស្ថានធនាគារតាមវិស័យសេដ្ឋកិច្ច**
(ឆ្នាំ២០២០)




**ក្រាហ្វ ៣២ ៖ អត្រាការប្រាក់របស់គ្រឹះស្ថានធនាគារ**
(ឆ្នាំ២០១៣ - វិច្ឆិកា ២០២០)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ប្រអប់ ៣ ៖ ការចូលរួមអភិវឌ្ឍទីផ្សារមូលបត្រ

### ក- ទីផ្សារមូលបត្របំណុល

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៥ បានបោះផ្សាយមូលបត្របំណុលក្នុងផ្សារមូលបត្រកម្ពុជា ដែលមានទឹកប្រាក់សរុបចំនួន ៤៥២ ប៊ីលានរៀល ដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

| ល.រ | គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ | ទំហំសាច់ប្រាក់ ដែលបានបោះផ្សាយ (គិតជាប៊ីលានរៀល) |
|---|---|---|
| ១ | ធនាគារ ហត្ថា ម.ក | ១២០ |
| ២ | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ | ៨៤,៨ |
| ៣ | ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក | ៤០ |
| ៤ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក | ១២៧,២ |
| ៥ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី | ៨០ |
| សរុប | | **៤៥២** |

### ខ- ការអភិវឌ្ឍមូលបត្រកម្មសិទ្ធិ

ធនាគារ អេស៊ីលីដា ភីអិលស៊ី បានចុះបញ្ជីមូលបត្រកម្មសិទ្ធិក្នុងទំហំទឹកប្រាក់ ៣៤៣ ប៊ីលានរៀល នៅផ្សារមូលបត្រកម្ពុជា។

## ៣- វិស័យមីក្រូហិរញ្ញវត្ថុ

ទ្រព្យសកម្មគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកើនឡើង ១២,៦% (ដល់ ៣៣,៩ ទ្រីលានរៀល ស្មើនឹង ៨,៤ ប៊ីលានដុល្លារអាមេរិក) ដែលក្នុងនោះឥណទានអតិថិជនបានកើនឡើង ១២,៥% (ដល់ ២៧,៦ ទ្រីលានរៀល ស្មើនឹង ៦,៨ ប៊ីលានដុល្លារអាមេរិក) ដោយមាន ១,៩លានគណនី។ ឥណទានទាំងនេះបានផ្តល់ទៅកាន់វិស័យសេដ្ឋកិច្ច រួមមាន៖ ក្រុមគ្រួសារ ៣១,២% (នៃឥណទានសរុប) ពាណិជ្ជកម្មនិងជំនួញ ២០,៩% កសិកម្ម ១៨,៩% សេវាកម្ម ១៦,២% ដឹកជញ្ជូន ៦% សំណង់ ៣,៨% និងផ្សេងៗ ៣%។ ទន្ទឹមនេះ វិស័យមីក្រូហិរញ្ញវត្ថុបានកេណ្ឌប្រមូលប្រាក់បញ្ញើ ១៥,២ ទ្រីលានរៀល (៣,៧ ប៊ីលានដុល្លារអាមេរិក) ដោយមាន ២,៧ លានគណនី។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានបណ្តាញប្រតិបត្តិការគ្របដណ្តប់ទូទាំងប្រទេស ដែលមានការិយាល័យចំនួន ១.១៧៥ និងបានធ្វើទំនើបកម្មលើសេវាកម្មរបស់ខ្លួនដូចជា ឥណទាន ប្រាក់បញ្ញើ ការផ្ទេរប្រាក់ ធនាគារចល័ត និងការដកនិងដាក់ប្រាក់តាមម៉ាស៊ីន ATM ជាដើម ដែលធ្វើឱ្យអតិថិជនមានលទ្ធភាពប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការបានកាន់តែច្រើន។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានផ្តល់ការអនុគ្រោះដល់អ្នកខ្ចីប្រាក់ តាមរយៈការរៀបចំឥណទានឡើងវិញចំនួន ២៥១.៧៨៣គណនី ស្មើនឹង

៩.៦១១,៤ ប៊ីលានរៀល (១.១៣៩,២ លានដុល្លារអាមេរិក) ដោយក្នុងនោះមាន ៖

-វិស័យទេសចរណ៍ ២១.៥០៨ គណនី ស្មើនឹង ៩៥៣,៥ ប៊ីលានរៀល (១១២ លានដុល្លារអាមេរិក)

-វិស័យកាត់ដេរ ៧២.៩៩៥ គណនី ស្មើនឹង ៧២១,៦ ប៊ីលានរៀល (១៧៨,៣ លានដុល្លារអាមេរិក)

-វិស័យសំណង់ ១៤.០៥១ គណនី ស្មើនឹង ៩៧៥,១ ប៊ីលានរៀល (១១៧,៤ លានដុល្លារអាមេរិក)

-វិស័យដឹកជញ្ជូននិងឡជីស្ទីក ១១.១៩៤ គណនី ស្មើនឹង ៣៧០,៣ ប៊ីលានរៀល (៩១,៥ លានដុល្លារអាមេរិក) និង

-វិស័យផ្សេងៗ ១២២.០៣៥ គណនី ស្មើនឹង ២.៥៩០,៨ ប៊ីលានរៀល (៦៤០ លានដុល្លារអាមេរិក)។

អត្រាការប្រាក់បញ្ញើជារៀលនិងដុល្លារអាមេរិកបានថយចុះបន្តិចមក ៧,៣១% និង ៧,២៥% ធៀបនឹងឆ្នាំ២០១៩ (៧,៩៣% និង ៧,៧១% រៀងគ្នា)។ ទន្ទឹមនេះ អត្រាការប្រាក់ឥណទានជារៀល និងដុល្លារអាមេរិកក៏មានការថយចុះផងដែរពី ១៧,៩២% និង ១៥,៩៥% នៅឆ្នាំ២០១៩ មក ១៦,៥៦% និង ១៤,៨៦% រៀងគ្នា ក្នុងឆ្នាំ២០២០។

**ក្រាហ្វ ៣៣ ៖ ឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតាមវិស័យសេដ្ឋកិច្ច**
(ឆ្នាំ២០២០)




**ក្រាហ្វ ៣៤ ៖ អត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**
(គិតជាភាគរយ, ឆ្នាំ២០១៤ - ខែវិច្ឆិកា ឆ្នាំ២០២០)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៤- វិស័យភតិសន្យាហិរញ្ញវត្ថុ

វិស័យភតិសន្យាហិរញ្ញវត្ថុបន្តចូលរួមយ៉ាងសកម្ម ក្នុងការផ្តល់សេវាដល់អតិថិជន តាមរយៈការផ្តល់លទ្ធភាពទិញឧបករណ៍សម្រាប់ជាមធ្យោបាយផលិតកម្ម ដឹកជញ្ជូន និងកសិកម្ម។ ទីស្នាក់ការកណ្តាល និងសាខារបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមានចំនួន ៣៥ ការិយាល័យ ហើយទ្រព្យសកម្មបានកើនឡើង ១៧,៦% (ដល់ ១,៦ ទ្រីលានរៀល ស្មើនឹង ៣៩២,១ លានដុល្លារអាមេរិក) ដែលក្នុងនោះឥណទានភតិសន្យាកើន ១២,១% (ដល់ ១,៣ ទ្រីលានរៀល ស្មើនឹង ៣២១,៨ លានដុល្លារអាមេរិក) ដោយមាន ៩៩.៨០៦គណនី។ ប្រភពទុនចម្បងនៃឥណទានភតិសន្យាបានមកពីមូលនិធិភាគទុនិក ដែលបានកើនឡើង ៣៣,២% (ដល់ ៦០៧,៨ ប៊ីលានរៀល ស្មើនឹង ១៤៩,៩ លានដុល្លារអាមេរិក)។

## ៥- គ្រឹះស្ថានឥណទានជនបទ

គ្រឹះស្ថានឥណទានជនបទ បានចូលរួមផ្តល់ឥណទានខ្នាតតូចសម្រាប់អតិថិជននៅតាមជនបទ ដើម្បីចាប់ផ្តើមនិងពង្រីកអាជីវកម្ម។ គ្រឹះស្ថានឥណទានជនបទ ដែលទទួលបានវិញ្ញាបនបត្រពីធនាគារជាតិនៃកម្ពុជា មានចំនួន ២៥៦ និងមានឥណទានសរុប ២៨៥,៣ ប៊ីលានរៀល (៦៩,៦ លានដុល្លារអាមេរិក) ដោយមាន ៩៣.៩៧២គណនី។

## ៦- ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុ

នៅឆ្នាំ២០២០នេះ ប្រព័ន្ធធនាគារបន្តមានស្ថិរភាពរឹងមាំ ទោះជារងសម្ពាធពីការថយចុះសកម្មភាពសេដ្ឋកិច្ចក៏ដោយ។ ភាពរឹងមាំនេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈសូចនាករសំខាន់ៗ រួមមាន៖ i/-ស្ថានភាពដើមទុនរបស់ប្រព័ន្ធធនាគារមានកម្រិតល្អ ដោយអនុបាតសាធនភាពជាមធ្យមមានកម្រិត ២៥% សម្រាប់គ្រឹះស្ថានធនាគារ និង ២០% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (កម្រិតអប្បបរមា ១៥%) ii/-អនុបាតគ្របដណ្តប់សន្ទនីយភាពមានកម្រិតខ្ពស់ ក្នុងនោះគ្រឹះស្ថានធនាគារជាមធ្យមមានកម្រិត ១៦៤,២% និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ មានកម្រិត ២៣២,៦% (កម្រិតអប្បបរមា ១០០%) iii/-អនុបាតឥណទានមិនដំណើរការបន្តមានកម្រិតទាបប្រមាណ ២,៧% សម្រាប់គ្រឹះស្ថានធនាគារ និង ១,៨% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង iv/-លទ្ធភាពស្វែងរកប្រាក់ចំណេញមានស្ថិរភាពល្អ ដោយអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម មានកម្រិត ១,៨% សម្រាប់គ្រឹះស្ថានធនាគារ និង ២,៨% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ លើសពីនេះ ការធ្វើស្ត្រេសតេស្តលើភាពគ្រប់គ្រាន់នៃដើមទុន និងភាពគ្រប់គ្រាន់នៃសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានបង្ហាញថា គ្រឹះស្ថានមានភាពធន់ទៅនឹងហានិភ័យដែលអាចកើតឡើងជាយថាហេតុ ខណៈដែលគ្រឹះស្ថានមួយចំនួនត្រូវពង្រឹងភាពគ្រប់គ្រាន់នៃដើមទុននិងសន្ទនីយភាព និងការគ្រប់គ្រងហានិភ័យឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត។

ទោះយ៉ាងណា ហានិភ័យមួយចំនួនដែលអាចប៉ះពាល់ដល់ស្ថិរភាពហិរញ្ញវត្ថុ រួមមាន៖ i/-ការថមថយកំណើនឥណទាន ជាពិសេសការថយចុះលឿននៃកំណើនឥណទានរបស់គ្រឹះស្ថានមីក្រូ-ហិរញ្ញវត្ថុ ii/-ការអាចកើនឡើងនៃឥណទានមិនដំណើរការ iii/-ការអាចថមថយប្រាក់ចំណេញជាងការរំពឹងទុក និង iv/-ការកើនឡើងនៃមូលនិធិកម្ចីពីខាងក្រៅ[២២]។

ប្រឈមនឹងស្ថានភាពមិនប្រាកដប្រជានេះ ធនាគារជាតិនៃកម្ពុជាបានតាមដានហានិភ័យប្រព័ន្ធហិរញ្ញវត្ថុយ៉ាងយកចិត្តទុកដាក់ ជាពិសេសលើស្ថានភាពសន្ទនីយភាព ដើមទុន និងគុណភាពឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ដើម្បីកាត់បន្ថយហានិភ័យទាំងនេះ និងពង្រឹងស្ថិរភាពហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវវិធានការម៉ាក្រូប្រុងប្រយ័ត្ននិងវិធានការផ្សេងៗទៀតមួយចំនួនដូចជា៖ i/-ពន្យារពេលឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរក្សាកម្រិតទ្រនាប់

[២២] ទំហំមូលនិធិកម្ចីមានប្រមាណ ១៥% នៃប្រភពមូលនិធិសរុបរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ហើយក្នុងនោះ ៧០% នៃមូលនិធិកម្ចីសរុបជាកម្ចីរយៈពេលវែង និងភាគច្រើនទទួលបានពីធនាគារមេ ភាគទុនិក និងដៃគូអភិវឌ្ឍន៍។

ដើមទុនខនស៊ីវេសិន (CCB) ត្រឹម ៥០% ii/-អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរៀបចំឥណទានរបស់ខ្លួនឡើងវិញចំពោះអតិថិជនដែលទទួលរងផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ និងគ្រោះទឹកជំនន់ iii/-អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលស្គាល់ប្រាក់ចំណេញក្នុងត្រីមាសដែលបានធ្វើសវនកម្មរួចក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធ (Net Worth) ជាបណ្ដោះអាសន្ន និង iv/-អនុគ្រោះកម្រៃសេវានិង/ឬលើកលែងការផាកពិន័យដូចជា ការបន្តផ្តល់ឥណទានឱ្យកាន់តែសកម្មដល់វិស័យអាទិភាព, ការមិនយកកម្រៃឥណទាន, ការលុបចោលការពិន័យផ្សេងៗ និងការមិនតម្រូវឱ្យយកកម្រៃលើការពិនិត្យឥណទានក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ជាដើម។

## ៧- ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី ដែលជាអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន មានទ្រព្យសកម្មសរុបចំនួន ៥៧,១ ប៊ីលានរៀល។ ប្រព័ន្ធចែករំលែកព័ត៌មានឥណទានមានសមាជិក ១៦៧ ដែលក្នុងនោះគ្រឹះស្ថានធនាគារពាណិជ្ជ ៥១ គ្រឹះស្ថានធនាគារឯកទេស ១៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៧៣ ក្រុមហ៊ុនភតិសន្យា ១៥ និងគ្រឹះស្ថានឥណទានជនបទ ៨។ សំពៀតឥណទានសរុបរបស់សមាជិកបានបញ្ចូល និងចែករំលែកនៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានបានកើនដល់ចំនួន ១៤៣,៤ ទ្រីលានរៀល (៣៥ ប៊ីលានដុល្លារអាមេរិក) ស្មើនឹង ៣.៤៩៨.៨១៣ គណនី ក្នុងនោះ៖ i/-ឥណទានឯកត្តបុគ្គលមានចំនួន ១២២,៦ ទ្រីលានរៀល (២៩,៨ ប៊ីលានដុល្លារអាមេរិក) ស្មើនឹង ៣.៤៩៣.៤៥៤ គណនី និង ii/-ឥណទានក្រុមហ៊ុនមានចំនួន ២១,៣ ទ្រីលានរៀល (៥,២ ប៊ីលានដុល្លារអាមេរិក) ស្មើនឹង ៥.៣៥៩ គណនី។

ធនាគារជាតិនៃកម្ពុជា បានកែសម្រួលប្រកាសស្តីពី ការចែករំលែកព័ត៌មានឥណទាន នៅខែមិថុនា ឆ្នាំ២០២០ ក្នុងគោលបំណងបន្ថែមក្របខ័ណ្ឌគតិយុត្តិ និងកិច្ចសហប្រតិបត្តិការសម្រាប់ការចែករំលែកព័ត៌មានឥណទាន សំដៅដល់ការកាត់បន្ថយហានិភ័យឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងរួមចំណែកក្នុងការបង្កើនបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា។ បន្ថែមលើនេះ ធនាគារជាតិនៃកម្ពុជា បានអនុញ្ញាតឱ្យក្រុមហ៊ុនក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី ដាក់ដំណើរការសាកល្បងនូវកម្មវិធីទូរស័ព្ទ (CBC Mobile) ក្នុងគោលបំណង៖ i/-អតិថិជនអាចត្រួតពិនិត្យរបាយការណ៍ឥណទានផ្ទាល់ខ្លួន ii/-ប្រមូលផ្តុំទៅដោយឯកសារអប់រំពាក់ព័ន្ធនឹងចំណេះដឹងហិរញ្ញវត្ថុ និង iii/-ទទួលបានព័ត៌មានសំខាន់ៗផ្សេងៗពីក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី។ ដើម្បីពង្រឹងគុណភាពនិងតម្លាភាពនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ធនាគារជាតិនៃកម្ពុជាបានបន្តត្រួតពិនិត្យលើរបាយការណ៍ប្រចាំគ្រាដែលបានផ្ញើមកធនាគារជាតិនៃកម្ពុជា និងបន្តតាមដានអនុសាសន៍ដែលបានដាក់ចេញ។

## ៨- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ក្នុងស្ថានភាពដែលប្រព័ន្ធធនាគារកំពុងរងឥទ្ធិពលពីការរីករាលដាលនៃជំងឺកូវីដ-១៩ ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក៏ត្រូវបានលើកកម្ពស់ជាប្រចាំ ដើម្បីតាមដានលើសុខុមាលភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិនានា។

## ក- សកម្មភាពត្រួតពិនិត្យ

ធនាគារជាតិនៃកម្ពុជា បាននិងកំពុងអនុវត្តផែនការត្រួតពិនិត្យផ្អែកលើហានិភ័យ និងទស្សនៈអនាគត ដែលក្នុងនោះ បានរៀបចំរចនាសម្ព័ន្ធអគ្គនាយកដ្ឋានត្រួតពិនិត្យឡើងវិញ ដើម្បីសម្រួលដល់ការត្រួតពិនិត្យកាន់តែមានប្រសិទ្ធភាព។ ការត្រួតពិនិត្យផ្អែកលើហានិភ័យ គឺការពិនិត្យស្ថានភាពទូទៅសកម្មភាពចម្បងៗនៃអាជីវកម្ម ការវិភាគហានិភ័យ ការវាយតម្លៃប្រសិទ្ធភាពនៃការគ្រប់គ្រង[២៣] ការពិនិត្យលើបញ្ហាប្រឈមនិងវិធានការដោះស្រាយ និងការវាយតម្លៃការអនុវត្តតាមច្បាប់ ប្រកាស និងបទប្បញ្ញត្តិប្រុងប្រយ័ត្នដែលបានដាក់ឱ្យអនុវត្ត សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំផែនការចុះត្រួតពិនិត្យដល់ទីកន្លែងនាពេលអនាគត។ លើសពីនេះ វិធីសាស្ត្រនៃការត្រួតពិនិត្យក៏បានរួមបញ្ចូលការធ្វើស្ត្រេសតេស្តអនុបាតក្របខ័ណ្ឌសន្ទនីយភាព និងអនុបាតសាធនភាពរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដើម្បីវាស់វែងពីភាពធន់នៃសន្ទនីយភាព និងដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩។

សម្រាប់ឆ្នាំ២០២០ ការត្រួតពិនិត្យដល់ទីកន្លែងបានផ្តោតការយកចិត្តទុកដាក់លើហានិភ័យជាក់លាក់ ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយចំនួនទៅលើអភិបាលកិច្ច គុណភាពទ្រព្យសកម្ម ហានិភ័យឥណទាន ហានិភ័យព័ត៌មានវិទ្យា ជាដើម។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយចំនួននៅមានបញ្ហាប្រឈម ដូចជា ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនិងប្រព័ន្ធព័ត៌មានវិទ្យានៅមានកម្រិត បញ្ហាប្រភពទុន ការយល់ដឹងពុំទាន់គ្រប់ជ្រុងជ្រោយពីប្រកាសនិងបទប្បញ្ញត្តិមានដូចជា ការអនុវត្តតាមប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមតែរមែន ការអនុវត្តតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងការអនុវត្តតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពធុនតូចនិងមធ្យម។

ជារួម លទ្ធផលនៃការត្រួតពិនិត្យបានបង្ហាញថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានស្ថានភាពហិរញ្ញវត្ថុរឹងមាំដែលឆ្លុះបញ្ចាំងតាមរយៈ អនុបាតប្រុងប្រយ័ត្ន អភិបាលកិច្ច ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាមច្បាប់និងបទប្បញ្ញត្តិប្រុងប្រយ័ត្ននានា។

## ខ- ការដាក់ចេញបទប្បញ្ញត្តិ

ធនាគារជាតិនៃកម្ពុជាបានចេញសារាចរណែនាំស្តីពីការរៀបចំឥណទានឡើងវិញ ចំពោះអតិថិជនស្ថិតក្នុងវិស័យអាទិភាពចំនួន ៤ រួមមាន៖ ទេសចរណ៍ កាត់ដេរ សំណង់ និងការដឹកជញ្ជូន ព្រមទាំងបានពង្រីកវិសាលភាពដល់វិស័យផ្សេងៗដែលរងផលប៉ះពាល់។ ទន្ទឹមនេះ បទប្បញ្ញត្តិមួយចំនួនក៏ត្រូវបានដាក់ឱ្យប្រើប្រាស់ រួមមាន៖

- ប្រកាសស្តីពីប្រាក់បម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើនិងប្រាក់កម្ចីរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយតម្រូវឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុតម្កល់ប្រាក់បម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើនិងប្រាក់កម្ចីជាមធ្យមប្រចាំថ្ងៃនៅធនាគារជាតិនៃកម្ពុជា ស្មើនឹងអត្រា ៧% ចំពោះរូបិយវត្ថុជាតិនិង

[២៣] ផ្នែកប្រតិបត្តិតាម ផ្នែកគ្រប់គ្រងហានិភ័យ និងផ្នែកត្រួតពិនិត្យផ្ទៃក្នុង។

រូបិយប័ណ្ណ (លេខ ធ៧-០២០-២៣០ ប្រ.ក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០)

- សារាចរណែនាំស្តីពីឥណទានរៀបចំឡើងវិញក្នុងអំឡុងពេលរងផលប៉ះពាល់ពីការរីករាលដាលរបស់វីរុសកូវីដ-១៩ (លេខ ធ៧-០២០-០០១ ស.រ.ណ.ន ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០)

- លិខិតស្តីពីការស្នើសុំការបន្ធូរបន្ថយលក្ខខណ្ឌមួយចំនួនពាក់ព័ន្ធនឹងឥណទានរៀបចំឡើងវិញក្នុងអំឡុងពេលផលប៉ះពាល់ពីការរីករាលដាលរបស់ជំងឺកូវីដ-១៩ (លេខ ធ៧-០២០-១៧៤៨ ឆ.ត ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០)

- លិខិតស្តីពី i/-ការកាត់បន្ថយកម្រិតទ្រនាប់ដើមទុនខនស៊ើវេសិន មកត្រឹម ១,២៥% និង ii/-ការទទួលស្គាល់ប្រាក់ចំណេញក្នុងត្រីមាសដែលបានធ្វើសវនកម្មរួច ក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធជាបណ្តោះអាសន្ន ដោយមិនមានការបែងចែកភាគលាភ (លេខ ធ៧-០២០-៦២២ ឆ.ត ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០)

- លិខិតស្តីពីសំណើសុំការអនុគ្រោះបន្ធូរបន្ថយកម្រៃសេវាផ្សេងៗពាក់ព័ន្ធនឹងឥណទាន និង/ឬលើកលែងការផាកពិន័យផ្សេងៗចំពោះអតិថិជន (លេខ ធ៧-០២០-៦៥៧ ឆ-ត ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០)

- ប្រកាសស្តីពីការចែករំលែកព័ត៌មានឥណទានថ្មីជំនួសឱ្យប្រកាសចាស់ (លេខ ធ៧-០២០-៣៥២ ប្រ.ក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០)

- សារាចរណែនាំបន្ថែមស្តីពីការអនុវត្តប្រកាសស្តីពីការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ (លេខ ធ៧-០២០-០០២ ស.រ.ណ.ន ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០) និង

- សារាចរណែនាំស្តីពីសេចក្តីពន្យល់បន្ថែមទៅលើឧបសម្ព័ន្ធ ២ នៃប្រកាសស្តីពីអនុបាតក្របខ័ណ្ឌសន្ទនីយភាព (លេខ ធ៧-០២០-០០៣ ស.រ.ណ.ន ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០)។

## ៩- បរិយាបន្នហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន

### ក- ការអប់រំផ្នែកហិរញ្ញវត្ថុ

ក្រោមកិច្ចសហការរបស់ក្រសួងអប់រំ យុវជន និងកីឡា ចំណេះដឹងផ្នែកហិរញ្ញវត្ថុត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីចំណេះទូទៅពីថ្នាក់ទី១ដល់ទី១២។ ដោយមានជំនួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គម្រោងនេះត្រូវបានអនុវត្តដល់ដំណាក់កាលទី២។ លទ្ធផលដែលបានទទួលពីដំណាក់កាលនេះនឹងត្រូវរៀបចំសៀវភៅសម្រាប់គ្រូនិងសិស្ស និងការធ្វើតេស្តសាកល្បងនៅថ្នាក់ទី៤ និងទី៧។

ម្យ៉ាងទៀត ក្រសួងកិច្ចការនារី ក៏បានសហការផ្សព្វផ្សាយការអប់រំផ្នែកហិរញ្ញវត្ថុ ក្រោមគម្រោង "ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនភាពស្ត្រី"។ គម្រោងនេះមានគោលបំណងបណ្តុះបណ្តាលគ្រូបង្គោល និងលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់មន្ទីរគោលដៅ និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីក្នុងខេត្ត ចំនួន ៤ គឺ ខេត្តសៀមរាប ព្រះវិហារ ក្រចេះ និងស្ទឹងត្រែង។

ធនាគារជាតិនៃកម្ពុជា និងអង្គការ Good Return ក៏បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ ដើម្បីបន្តកិច្ចសហប្រតិបត្តិការ ក៏ដូចជាការអនុវត្តគម្រោងយុទ្ធនាការផ្សព្វផ្សាយថ្មីដែលមានឈ្មោះថា "ការប្រើប្រាស់លុយដោយឆ្លាតវៃ" ក្នុងគោលបំណងបញ្ជាក់ពីសារៈសំខាន់នៃការគិតពិចារណានិងថ្លឹងថ្លែងពីជម្រើស និងជួយដល់អ្នកប្រើប្រាស់ផលិតផលហិរញ្ញវត្ថុនៅកម្ពុជា

ឱ្យយល់ច្បាស់អំពីសិទ្ធិនិងការទទួលខុសត្រូវ និងជម្រើសផលិតផលហិរញ្ញវត្ថុដែលសមស្រប។ ក្រៅពីនេះ សៀវភៅអប់រំផ្នែកហិរញ្ញវត្ថុ "តោះ!និយាយពីលុយ" ក៏ត្រូវបានផ្សព្វផ្សាយនៅតាមមូលដ្ឋានគោលដៅមួយចំនួនដូចជា ខេត្តព្រៃវែង ពោធិ៍សាត់ តាកែវ កំពង់ចាម កំពង់ធំ និងសៀមរាប ដោយបានចែកចាយសៀវភៅហូតដល់ទៅ ២៩.៧១៦ ក្បាល។ យុទ្ធនាការអប់រំផ្នែកហិរញ្ញវត្ថុ "តោះ!និយាយពីលុយ" ក៏ត្រូវបានផ្សព្វផ្សាយតាមរយៈកម្មវិធីក្នុងទូរស័ព្ទដៃ ទំព័រហ្វេសប៊ុក វិទ្យុ និងគេហទំព័ររបស់យុទ្ធនាការអប់រំផ្នែកហិរញ្ញវត្ថុ "តោះ!និយាយពីលុយ" ផងដែរ។

### ខ- ការងារផ្សព្វផ្សាយស្តីពីវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា

សិក្ខាសាលាផ្សព្វផ្សាយស្តីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា" ត្រូវបានបន្តផ្សព្វផ្សាយនៅថ្នាក់ខេត្តចំនួន ៣ដង (មណ្ឌលគិរី បន្ទាយមានជ័យ និងបាត់ដំបង) ព្រមទាំងថ្នាក់ស្រុក-ក្រុងចំនួន ៥ដង (ក្រុងខេមរភូមិន្ទនៃខេត្តកោះកុង ក្រុងបានលុងនៃខេត្តរតនគិរី ស្រុកសូទ្រនិគមនៃខេត្តសៀមរាប ក្រុងស្ទឹងត្រែងនៃខេត្តស្ទឹងត្រែង និងស្រុកមោងឫស្សីនៃខេត្តបាត់ដំបង) ដោយមានអ្នកចូលរួមសរុបចំនួន ១.៩២៩នាក់។ សិក្ខាសាលានេះ គឺជាវេទិកាដ៏មានប្រសិទ្ធភាពមួយដើម្បីពង្រឹងការយល់ដឹងចំពោះវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាជូនដល់អាជ្ញាធរនិងប្រជាពលរដ្ឋនៅតាមមូលដ្ឋាន និងផ្តល់ឱកាសដល់អ្នកចូលរួមរាយការណ៍ពីបញ្ហាប្រឈម សំណូមពរ និងចម្ងល់នានាពាក់ព័ន្ធនឹងការប្រើប្រាស់សេវាហិរញ្ញវត្ថុ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា អាជ្ញាធរមានសមត្ថកិច្ចនិងតំណាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានទទួលនិងផ្តល់ជាដំណោះស្រាយឬអនុសាសន៍ភ្លាមៗនៅនឹងកន្លែង ព្រមទាំងបង្កើនទំនាក់ទំនងនិងកិច្ចសហការយ៉ាងជិតស្និទ្ធរវាងអាជ្ញាធរមូលដ្ឋាននិងភាគីពាក់ព័ន្ធនានា ដើម្បីបន្តក្តាប់ឱ្យបាននូវស្ថានភាពជាក់ស្តែងនៃការប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុ និងបញ្ចៀសការកេងប្រវ័ញ្ចតាមរយៈការប្រើប្រាស់សេវាកម្ចីដែលមិនមានអាជ្ញាប័ណ្ណត្រឹមត្រូវ។

### គ- យន្តការគ្រប់គ្រង និងដោះស្រាយបណ្តឹងអតិថិជន

ធនាគារជាតិនៃកម្ពុជា បានបន្តពង្រឹងលើការអនុវត្តប្រកាសស្តីពីការដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ តាមរយៈប្រព័ន្ធទូរស័ព្ទ Hotline ទាំងទីស្នាក់ការកណ្តាល និងនៅតាមបណ្តាសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ដោយបានទទួលបណ្តឹង និងសាកសួរព័ត៌មានចំនួន ១.០៧៣ ករណី ដែលបណ្តឹងភាគច្រើនពាក់ព័ន្ធនឹង៖ i/-អតិថិជនមិនអាចបង់ផ្តាច់ ឬទទួលរងពិន័យនៅពេលទូទាត់ឥណទានមុនកាលកំណត់ ii/-អតិថិជន មិនអាចដកប្លង់ដី អចលនទ្រព្យធានាបានភ្លាមៗ iii/-អតិថិជនមានបញ្ហាក្នុងការដកប្រាក់បញ្ញើពីគណនី និងតាមរយៈមូលប្បទានបត្រ iv/-ការបាត់ទឹកប្រាក់ពីគណនីដោយមិនមានមូលហេតុ v/-កម្ចីក្រៅប្រព័ន្ធ vi/-ការសងប្រាក់យឺត និងការទទួលពិន័យ vii/-ការស្នើសុំបន្ថយការសងប្រចាំខែ ការស្នើសុំពន្យារពេលសងប្រាក់ដើម ឬការប្រាក់ដោយសាររងផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ viii/-ការស្នើសុំលុបឈ្មោះនៅក្នុងប្រព័ន្ធ CBC ix/-ការស្នើសុំពន្យារពេលការលក់ឡាយឡុងលើទ្រព្យបញ្ចាំ x/-ការស្នើសុំខ្ចីឥណទានបន្ថែមរបស់អតិថិជនតែគ្រឹះស្ថានមិនព្រម និងតម្រូវឱ្យសងឥណទានចាស់សិន និង xi/-ការសាកសួរផ្សេងៗពាក់ព័ន្ធនឹងការប្រើប្រាស់សេវាហិរញ្ញវត្ថុ រួមមាន៖ ការរក្សាទុកប្រវត្តិសងឥណទាននៅក្នុងប្រព័ន្ធ CBC

កាលវិភាគសងថ្មីថាត្រឹមត្រូវដែរឬទេ ខ្លឹមសារនៅក្នុងកិច្ចសន្យា ការធ្វើមូលធនកម្មការប្រាក់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ របាយការណ៍អត្រាការប្រាក់ ចំណាត់ការរបស់ធនាគារជាតិនៃកម្ពុជាក្នុងការជួយដល់អតិថិជនក្នុងអំឡុងពេលជំងឺកូវីដ-១៩ ការរៀបចំឥណទានឡើងវិញចំពោះអតិថិជន និងការខ្ចីពីគ្រឹះស្ថានមួយទៅសងគ្រឹះស្ថានមួយទៀត។

### ឃ- វឌ្ឍនភាពរបស់គម្រោងបង្កើតប្រព័ន្ធការពារប្រាក់បញ្ញើ

ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ និងអនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានបង្កើតក្របខ័ណ្ឌស្ថាប័នក្នុងការអភិវឌ្ឍប្រព័ន្ធការពារប្រាក់បញ្ញើនៅកម្ពុជា តាមរយៈ៖ i/-ការបង្កើតក្រុមការងាររៀបចំយន្តការការពារប្រាក់បញ្ញើដឹកនាំដោយធនាគារជាតិនៃកម្ពុជា និងមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផងដែរ និង ii/-ការបង្កើតអង្គភាពការពារប្រាក់បញ្ញើ និងក្របខ័ណ្ឌដំណោះស្រាយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលស្ថិតក្រោមចំណុះអគ្គនាយកដ្ឋានបច្ចេកទេសនៃធនាគារជាតិនៃកម្ពុជា។

## ១០- វឌ្ឍនភាពការងារផ្សេងៗ

### ក- វឌ្ឍនភាពក្នុងការអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

បន្ទាប់ពីដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្លង់គណនីឯកភាព សៀវភៅណែនាំ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ[២៤] ធនាគារជាតិនៃកម្ពុជាបានបន្តពិនិត្យឡើងវិញ និងកែតម្រូវលើទម្រង់របាយការណ៍នានា ឱ្យស្របតាមស្តង់ដា CIFRS។ ធនាគារជាតិនៃកម្ពុជាក៏បានបន្តពិភាក្សាជាមួយក្រុមហ៊ុនសវនកម្មក្នុងការបង្កើតគោលការណ៍ណែនាំស្តីពីការកំណត់តម្លៃទ្រព្យធានា សម្រាប់គណនាសំវិធានធនតាមស្តង់ដា CIFRS ៩។

ទន្ទឹមនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ជាផ្លូវការនូវប្លង់គណនីឯកភាព សៀវភៅណែនាំ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ ដែលរួមមាន របាយការណ៍ស្តីពីទ្រព្យសកម្មនិងទ្រព្យអកម្ម របាយការណ៍ស្តីពីចំណូលនិងចំណាយ របាយការណ៍ស្តីពីប្រាក់ចំណូលលម្អិតផ្សេងទៀត និងរបាយការណ៍ស្តីពីក្រៅតារាងតុល្យការ សម្រាប់ការអនុវត្តគម្រោង CIFRS សម្រាប់អង្គភាពធុនតូចនិងមធ្យម។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានសិក្សាស្រាវជ្រាវនិងដោះស្រាយនូវបញ្ហាពាក់ព័ន្ធនឹងស្តង់ដា CIFRS ទៅលើបទប្បញ្ញត្តិផ្សេងៗផងដែរ។

---

[២៤] ដែលរួមមាន របាយការណ៍ស្តីពីទ្រព្យសកម្មនិងទ្រព្យអកម្ម របាយការណ៍ស្តីពីចំណូលនិងចំណាយ របាយការណ៍ស្តីពីប្រាក់ចំណូលលម្អិតផ្សេងទៀត និងរបាយការណ៍ស្តីពីក្រៅតារាងតុល្យការ សម្រាប់ការអនុវត្តគម្រោង CIFRS។

## ខ- កិច្ចសម្របសម្រួលរវាងធនាគារជាតិនៃកម្ពុជា និងអគ្គស្នងការដ្ឋាននគរបាលជាតិ

ដើម្បីចូលរួមទប់ស្កាត់សកម្មភាពប្រតិបត្តិការធនាគារមិនស្របច្បាប់ និង/ឬមិនមានការអនុញ្ញាត ពីធនាគារជាតិនៃកម្ពុជា ធនាគារជាតិនៃកម្ពុជាបានបង្កើតក្រុមការងារសម្របសម្រួលជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ។ ក្រុមការងារនេះមានតួនាទី-ភារកិច្ច ដូចតទៅ៖ i/-ស្រាវជ្រាវ តាមដានកំណត់មុខសញ្ញា និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងប្រតិបត្តិការធនាគារមិនស្របច្បាប់ ឬមិនមានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ii/-ជូនដំណឹង និងសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីរៀបចំផែនការ ឬវិធានការដោះស្រាយ ទៅលើក្រុមហ៊ុន ឬបុគ្គលដែលធ្វើប្រតិបត្តិការធនាគារដោយគ្មានច្បាប់អនុញ្ញាត iii/-សហការ ឬចុះប្រតិបត្តិការដល់ទីកន្លែងជាមួយនឹងអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីប្រមូលភស្តុតាង និងចាត់វិធានការចំពោះក្រុមហ៊ុន ឬបុគ្គលល្មើសច្បាប់ iv/-រាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តមុខងារភារកិច្ចខាងលើជូនថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា និង v/-បំពេញមុខងារនិងភារកិច្ចផ្សេងៗទៀតដែលថ្នាក់នាំធនាគារជាតិនៃកម្ពុជាប្រគល់ជូន។

ម្យ៉ាងទៀត ក្រុមការងារសម្របសម្រួលនេះ ក៏បានសហការជាមួយក្រុមការងារចុះស្រាវជ្រាវដកពិសោធន៍ប្រព័ន្ធសន្តិសុខ-សុវត្ថិភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយផ្តោតសំខាន់ទៅលើការពង្រឹងសន្តិសុខ-សុវត្ថិភាពនៅតាមបណ្តាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផងដែរ។

# V- ការផ្គត់ផ្គង់សេវាធនាគារកណ្តាល

## ១- ប្រព័ន្ធទូទាត់សងប្រាក់

### ក- ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់

ប្រព័ន្ធទូទាត់ត្រូវបានធ្វើទំនើបកម្មតាមរយៈការអភិវឌ្ឍ និងដាក់ឱ្យដំណើរការប្រព័ន្ធទូទាត់ថ្មីៗបន្ថែមទៀត។ កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ប្រព័ន្ធបាគងត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការដែលនឹងបម្រើជាប្រព័ន្ធទូទាត់កន្លោង (Backbone Payment System) មួយជួយសម្រួលការផ្ទេរប្រាក់និងទូទាត់សងប្រាក់ឆ្លងគ្រឹះស្ថានជាអេឡិចត្រូនិកប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាព។ បច្ចុប្បន្នប្រព័ន្ធបាគងមានគ្រឹះស្ថានសមាជិកចំនួន១៨ អាចដាក់ឱ្យប្រព័ន្ធដំណើរការជាផ្លូវការ ចំណែកសមាជិកផ្សេងទៀតកំពុងតភ្ជាប់ប្រព័ន្ធ។ ដោយឡែក ប្រព័ន្ធខេមបូឌានស៊ែស្វីចនិងប្រព័ន្ធវីផែលផេកំពុងត្រូវបានដាក់ឱ្យដំណើរការបឋម និងគ្រោងដាក់ឱ្យដំណើរការជាផ្លូវការក្នុងពេលឆាប់ៗខាងមុខ។ លើសពីនេះ ចំនួនគ្រឹះស្ថានដែលបានបញ្ចប់ការធ្វើសន្ធានកម្ម និងចូលរួមក្នុងដំណើរការបឋមប្រព័ន្ធខេមបូឌានស៊ែស្វីចកើនដល់ ២៧ គ្រឹះស្ថាន និងប្រព័ន្ធវីផែលផេមានចំនួន១១គ្រឹះស្ថាន។ ទន្ទឹមនេះ ប្រព័ន្ធទូទាត់ដុលភ្លាមៗ (RTGS) ដែលជាប្រព័ន្ធទូទាត់តម្លៃធំក៏កំពុងត្រូវបានអភិវឌ្ឍសម្រាប់សម្រួល និងកាត់បន្ថយហានិភ័យចំពោះប្រតិបត្តិការទូទាត់សងប្រាក់តម្លៃធំអន្តរធនាគារ ជាពិសេសប្រតិបត្តិការទូទាត់ក្នុងទីផ្សារហិរញ្ញវត្ថុ។

**ប្រអប់ ៤ ៖ ប្រកាសនិងសេចក្តីជូនដំណឹងពាក់ព័ន្ធនឹងប្រព័ន្ធទូទាត់ដែលបាន ដាក់ឱ្យប្រើប្រាស់នៅក្នុងឆ្នាំ២០២០**

ប្រកាសនិងសេចក្តីជូនដំណឹងពាក់ព័ន្ធនឹងប្រព័ន្ធទូទាត់ដែលដាក់ឱ្យប្រើប្រាស់នៅក្នុងឆ្នាំ ២០២០៖ i/-ប្រកាសស្តីពីវិធាននិងនីតិវិធីប្រព័ន្ធបាគងដើម្បីគ្រប់គ្រងប្រតិបត្តិការប្រព័ន្ធនិងការអនុវត្ត តាមរបស់គ្រឹះស្ថានសមាជិកឱ្យកាន់តែមានប្រសិទ្ធភាព ii/-ប្រកាសស្តីពីស្លាកសញ្ញាប្រព័ន្ធបាគងនិង ប្រព័ន្ធរីថែលផេក៏ត្រូវបានដាក់ឱ្យអនុវត្ត ដែលប្រកាសនេះនឹងជួយពង្រឹងការប្រើប្រាស់ ស្លាកសញ្ញា ប្រព័ន្ធទាំងពីរឱ្យបានត្រឹមត្រូវដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ iii/-ប្រកាសស្តីពីគំរូបរិច្ឆិន្នភាព បច្ចេកទេសខេអេចឃ្យូអរកូត (KHQR Code) សម្រាប់ការទូទាត់សងប្រាក់ដែលប្រកាសនេះកំណត់ នូវស្តង់ដា QR កូត សម្រាប់ប្រទេសកម្ពុជា ដើម្បីសម្រួលដល់ការទូទាត់ឆ្លងគ្នា (interoperability) រវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការអនុវត្តគម្រោងភ្ជាប់ការទូទាត់ជាមួយប្រទេសក្នុងតំបន់ និង iv/-សេចក្តីជូនដំណឹងកំណត់ឱ្យគ្រឹះស្ថានសមាជិកអនុវត្តស្តង់ដា Chip EMV លើប័ណ្ណទូទាត់ និងគោលការណ៍សុវត្ថិភាពលើម៉ាស៊ីន ATM និង POS ដើម្បីរួមចំណែកពង្រឹងសុវត្ថិភាពនៃការ ទូទាត់តាមប្រព័ន្ធខេមបូឌានស៊ែស្វីច។

ដើម្បីទប់ស្កាត់ហានិភ័យផ្សេងៗដែលអាចកើតមានឡើង ធនាគារជាតិនៃកម្ពុជាបន្តតាមដាន និងត្រួតពិនិត្យទាំងប្រព័ន្ធទូទាត់សងប្រាក់ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។ ការត្រួតពិនិត្យ លើឯកសារនិងដល់ទីកន្លែងចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវបានអនុវត្តជាប្រចាំ ដោយ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិនានាជាធរមានផ្អែកលើហានិភ័យ និងការគោរពតាមបទប្បញ្ញត្តិ។

## ២- ប្រតិបត្តិការប្រព័ន្ធទូទាត់សងប្រាក់

**ក- ប្រព័ន្ធផាត់ទាត់ជាតិ៖** ប្រព័ន្ធផាត់ទាត់ជាតិមានសមាជិកចំនួន ៤៦ (សមាជិកផ្ទាល់ ៣៤ និងសមាជិកមិនផ្ទាល់ ១២) និងមានមណ្ឌលដោះដូរមូលប្បទានប័ត្រ ៦ នៅតាមសាខាធនាគារជាតិ នៃកម្ពុជា រួមមាន ខេត្តសៀមរាប (សមាជិក ២៤) ខេត្តព្រះសីហនុ (សមាជិក ១៩) ខេត្តកំពង់ចាម (សមាជិក ១៦) ខេត្តបាត់ដំបង (សមាជិក ១៧) ខេត្តបន្ទាយមានជ័យ (សមាជិក ៥) និងខេត្តស្វាយរៀង (សមាជិក៦)។ មណ្ឌលដោះដូរមូលប្បទានប័ត្រទាំង ៦ ធ្វើតែសកម្មភាពដោះដូរមូលប្បទានប័ត្រ រូបវន្តប៉ុណ្ណោះ។

ប្រព័ន្ធផាត់ទាត់ជាតិ បានដំណើរការទូទាត់លើឧបករណ៍ទូទាត់ ២ ប្រភេទគឺ មូលប្បទានប័ត្រ និងបញ្ជាផ្ទេរឥណទាន ៖

- **សេវាទូទាត់មូលប្បទានប័ត្រ៖** ការទូទាត់មូលប្បទានប័ត្រជាប្រាក់រៀលមាន ២៣,៩ ទ្រីលាន រៀល (៣៥,៨៩ ពាន់សន្លឹក) កើនឡើង ៧៩,៧% ហើយការទូទាត់មូលប្បទានប័ត្រជាប្រាក់ដុល្លារ អាមេរិកមាន ៥១,៧ ប៊ីលានដុល្លារអាមេរិក (១,២ លានសន្លឹក) កើនឡើង ១៤,៥%។

- **សេវាទូទាត់បញ្ញើផ្ទេរឥណទាន៖** ការទូទាត់បញ្ញើផ្ទេរឥណទានដែលជាឧបករណ៍ទូទាត់សងប្រាក់អេឡិចត្រូនិកក៏មានការកើនឡើងផងដែរ ដោយប្រតិបត្តិការបញ្ញើផ្ទេរឥណទានជាប្រាក់រៀលមាន ៤,៥ ទ្រីលានរៀល (៩,៥ ពាន់ប្រតិបត្តិការ) កើនឡើង ៦១% ខណៈដែលប្រតិបត្តិការបញ្ញើផ្ទេរឥណទានជាប្រាក់ដុល្លារអាមេរិកមាន ៧,៨ ប៊ីលានដុល្លារអាមេរិក (៣០៨,៦ ពាន់ប្រតិបត្តិការ) កើនឡើង ២,៦%។

កំណើននៃការប្រើមូលប្បទាប័ត្រ និងបញ្ញើផ្ទេរឥណទាន បង្ហាញអំពីកំណើនទូទាត់ក្នុងសេដ្ឋកិច្ចដោយប្រើប្រាស់ឧបករណ៍ទូទាត់អេឡិចត្រូនិក និងមូលប្បទានប័ត្រជំនួសឱ្យការប្រើប្រាស់សាច់ប្រាក់។

**ខ- ប្រព័ន្ធសេវាទូទាត់រហ័ស៖** ប្រព័ន្ធសេវាទូទាត់រហ័សមានសមាជិកសរុបចំនួន ៥៦ ដោយរួមទាំងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៦។ ប្រព័ន្ធសេវាទូទាត់រហ័ស បានដំណើរការទូទាត់លើប្រតិបត្តិការបញ្ញើផ្ទេរឥណទានជាប្រាក់រៀលចំនួន ១៩០,២៥ ប៊ីលានរៀល (៤៤,៥៧ ពាន់ប្រតិបត្តិការ) កើនឡើងជិត២ដង។

**គ- ប្រព័ន្ធខេមបូឌានស៊ែរស្វីច (CSS)៖** ប្រព័ន្ធ CSS មានសមាជិកចំនួន ៤៨ គ្រឹះស្ថាន ក្នុងនោះសមាជិកផ្ទាល់ដែលជាធនាគារពាណិជ្ជមាន ៤០ សមាជិកផ្ទាល់ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមាន ៦ និងសមាជិកមិនផ្ទាល់ជាធនាគារពាណិជ្ជមាន ២។ ប្រព័ន្ធ CSS បានដំណើរការលើប្រតិបត្តិការប័ណ្ណឥណពន្ធជាប្រាក់រៀលសរុប ៣៩,១ ប៊ីលានរៀល (២១៦,៣៩ ពាន់ប្រតិបត្តិការ) កើនឡើង ២ដង ហើយប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមាន ៤,២ លានដុល្លារអាមេរិក (៤៣ ពាន់ប្រតិបត្តិការ) កើនឡើង ១១,៦%។

**ឃ- សេវាផ្ទេរប្រាក់តាមប្រព័ន្ធធនាគារអនឡាញ (OBS)៖** ប្រតិបត្តិការផ្ទេរប្រាក់តាមប្រព័ន្ធ OBS[២៥] មាន ៣០.២៨៥ ប្រតិបត្តិការ ស្មើនឹង ១៨៧,៦ទ្រីលានរៀល (កើន ១៨,៨%) ក្នុងនោះការផ្ទេរប្រាក់រវាងគណនីនៅស្នាក់ការកណ្តាលជារៀលមាន ១៧.៩២៨ ប្រតិបត្តិការ ស្មើនឹង ៦០,១ ទ្រីលានរៀល (កើន ១៩,៧%) និងជាប្រាក់ដុល្លារអាមេរិកមាន ១០.៦៦៣ ប្រតិបត្តិការ ស្មើនឹង ៣០,៧ ប៊ីលានដុល្លារអាមេរិក (កើន ១៨,៨%) និងការផ្ទេរប្រាក់ពីគណនីនៅស្នាក់ការកណ្តាលទៅសាខារាជធានី-ខេត្តជារៀលមាន ៩១៦ ប្រតិបត្តិការ ស្មើនឹង ២,៤ ទ្រីលានរៀល (កើន ១,៧%) និងជាដុល្លារអាមេរិកមាន ៧៧៩ ប្រតិបត្តិការ ស្មើនឹង ៥៩៤,១ លានដុល្លារអាមេរិក (កើន ២០,៩%)។

**ង- សេវាគ្រប់គ្រងគណនី៖** គណនីសរុបដែលបានបើកនៅស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជាមានចំនួន ១.៨៩៥ គណនី (កើន ៤%) ក្នុងនោះ ស្ថាប័នរដ្ឋមាន ៩៣១គណនី (កើន ២៧ គណនី) គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមាន ៩២៧ គណនី (កើន ៤៦គណនី) និងអង្គភាពផ្សេងៗ (ដូចជា ធនាគារកណ្តាលបរទេស គ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិសាធារណៈ និងមន្ទីរសាការី) មាន ៣៧គណនី។

---

[២៥] ប្រតិបត្តិការតាមប្រព័ន្ធ OBS រវាងគណនីនៅស្នាក់ការកណ្តាល មិនត្រូវបានគិតកម្រៃសេវាទេ ប៉ុន្តែការផ្ទេរប្រាក់ពីគណនីនៅស្នាក់ការកណ្តាលទៅគណនីនៅសាខារាជធានី-ខេត្ត ត្រូវគិតកម្រៃសេវា ០,១% នៃចំនួនប្រាក់ផ្ទេរ ដែលកម្រៃអតិបរមាគឺ ៤លានរៀល និងអប្បបរមា ១២.០០០ រៀល។ ចំពោះការផ្ទេរប្រាក់ដែលជាថវិការដ្ឋមិនត្រូវបានគិតកម្រៃសេវាទេ។

ធនាគារជាតិនៃកម្ពុជាបានបន្តគាំទ្រនិងសហការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលក្នុងដំណាក់កាលទី៣ (២០១៦-២០២០) ដែលជាដំណាក់កាល "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" ជាពិសេសតាមរយៈការប្រើប្រាស់សេវាប្រព័ន្ធ OBS ដែលត្រូវធ្វើសន្ធានកម្មជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជា បានបើកគណនីប្រាក់រង្វាន់ និងសម្របសម្រួលការផ្ទេរថវិកា និងការផ្ទេរប្រាក់បៀវត្សរ៍ (២ដងក្នុង១ខែ) របស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធដែលបើកគណនីនៅធនាគារដៃគូដោយអនុវត្តថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ៣- ការគ្រប់គ្រងចរាចរណ៍ធនប័ត្រ

### ក- សកម្មភាពបេឡាប្រតិបត្តិការ

ការទទួលនិងបើកប្រាក់រៀលជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងស្ថាប័នរដ្ឋ បានកើនឡើង ២៩,៦% និង ១១,៦% រៀងគ្នា ខណៈដែលការទទួលប្រាក់ដុល្លារអាមេរិកបានថយចុះ -៧,៦% និងការបើកប្រាក់ដុល្លារអាមេរិក បានកើនឡើង ៤៥,៥% ធៀបនឹងឆ្នាំ២០១៩។

**ក្រាហ្វ ៣៥ ៖ ការទទួលនិងបើកប្រាក់រៀល**

(គិតជាប៊ីលានរៀល, ឆ្នាំ២០១៦ - ២០២០)




**ក្រាហ្វ ៣៦ ៖ ការទទួលនិងបើកប្រាក់ដុល្លារអាមេរិក**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៦ - ២០២០)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ខ- ការងារគ្រប់គ្រងសាច់ប្រាក់

ក្រដាសប្រាក់រៀលគ្រប់ប្រភេទត្រូវបានផ្គត់ផ្គង់ទៅក្នុងចរាចរណ៍ ដើម្បីបំពេញតម្រូវការរបស់សាធារណជនទូទាំងប្រទេស ហើយក្រដាសប្រាក់ចាស់ត្រូវបានប្រមូលមកវិញ និងការប្តូរក្រដាសប្រាក់រៀលថ្មីជូនប្រជាជន និងអាជីវករ។ ទន្ទឹមនេះ គុណភាពនិងសោភ័ណភាពក្រដាសប្រាក់ត្រូវបានពង្រឹងជាលំដាប់តាមរយៈការផ្លាស់ប្តូររចនាបថថ្មីស្របតាមការរីកចម្រើននៃបច្ចេកវិទ្យា ក្នុងគោលបំណងទប់ស្កាត់ការក្លែងបន្លំក្រដាសប្រាក់ ហើយលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលថែមទៀត។ ម្យ៉ាងវិញទៀត យុទ្ធនាការស្រឡាញ់ប្រាក់រៀលបានជួយសម្រួលដល់ប្រជាពលរដ្ឋ ប្តូរក្រដាសប្រាក់

រៀលថ្មីដោយទូលំទូលាយ ជាពិសេសក្នុងឱកាសបុណ្យប្រពៃណីជាតិធំៗ ដូចជា បុណ្យចូលឆ្នាំខ្មែរ និងបុណ្យភ្ជុំបិណ្ឌ ជាដើម។ ធនាគារជាតិនៃកម្ពុជាក៏បានរៀបចំទិវាប្រាក់រៀល និងការតាំងពិព័រណ៍ប្រវត្តិរូបិយវត្ថុជាតិ កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ ដើម្បីអបអរសាទរទិវាប្រាក់រៀលខួបលើកទី៤០ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ ផងដែរ។

ការផ្គត់ផ្គង់ប្រាក់រៀលទៅឱ្យសាខារាជធានី-ខេត្ត បានថយចុះ -១,៩% ខណៈដែលការដឹកជញ្ជូនប្រាក់រៀលចាស់និងលើសពីតម្រូវការមកស្នាក់ការកណ្ដាលវិញ បានកើនឡើង ៣៦,៣%។ ចំណែកឯការផ្គត់ផ្គង់ប្រាក់ដុល្លារអាមេរិកទៅឱ្យសាខា បានកើនឡើង ៨៨,៨% ខណៈដែលការដឹកជញ្ជូនប្រាក់ដុល្លារអាមេរិកមកស្នាក់ការកណ្ដាលវិញបានថយចុះ -២៩,៩% ធៀបនឹងឆ្នាំ២០១៩។

**ក្រាហ្វ ៣៧ ៖ ប្រាក់រៀលដឹកទៅ-មកសាខា ធនាគារជាតិនៃកម្ពុជា**
(គិតជាប៊ីលានរៀល, ឆ្នាំ២០១៦ - ២០២០)




**ក្រាហ្វ ៣៨ ៖ ប្រាក់ដុល្លារអាមេរិកដឹកទៅ-មកសាខា ធនាគារជាតិនៃកម្ពុជា**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៦ - ២០២០)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ក្រោមកិច្ចសហការជាប្រចាំជាមួយអាជ្ញាធរមានសមត្ថកិច្ច និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រដាសប្រាក់រៀលក្លែងក្លាយ (ដែលភាគច្រើនមានលក្ខណៈជាប្រភេទថតចម្លង) និងក្រដាសប្រាក់ដុល្លារអាមេរិកក្លែងក្លាយដែលបានដកហូត បានថយចុះ -៦០% និង -៦០,២% រៀងគ្នា ធៀបនឹងឆ្នាំ២០១៩ ក្នុងនោះ ក្រដាសប្រាក់ក្លែងក្លាយដែលបានដកហូតមានប្រភេទ ១០.០០០ រៀល និង ១០០ ដុល្លារអាមេរិក។

## VI- ការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

### ១- ការរាយការណ៍ប្រតិបត្តិការរបស់បុគ្គលរាយការណ៍

បើទោះបីជាមានសភាពការណ៍វិបត្តិជំងឺកូវីដ-១៩ ក្នុងឆ្នាំ២០២០ នេះក្តី ក៏សកម្មភាពរាយការណ៍ប្រតិបត្តិការទាំងនោះ នៅតែបន្តជាប្រក្រតី។ ទន្ទឹមនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) បានភ្ជាប់ប្រព័ន្ធរាយការណ៍ជាមួយធនាគារពាណិជ្ជចំនួន៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន១៤ និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុចំនួន៥ បន្ថែមទៀត។ ស.ហ.ក ក៏បាននិងកំពុងសម្របសម្រួលភ្ជាប់ប្រព័ន្ធរាយការណ៍ ជូនបុគ្គលរាយការណ៍ថ្មីៗ ជាបន្តបន្ទាប់។

## ២- ការពង្រឹងក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ និងការអនុវត្តកាតព្វកិច្ចនិងការយល់ដឹងរបស់បុគ្គលរាយការណ៍

ក្រោមជំនួយបច្ចេកទេសពីមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងក្រសួងមហាផ្ទៃអូស្ត្រាលី ស.ហ.ក រៀបចំសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់នាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ជាមួយនឹងច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។ ច្បាប់ទាំងនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងជំរុញប្រសិទ្ធភាពនៃក្របខ័ណ្ឌគតិយុត្តនៅកម្ពុជាពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទាន ដល់ការរីកសាយភាយអាវុធមហាប្រល័យ។ ទន្ទឹមនេះ នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០ ស.ហ.ក បានចេញផ្សាយសេចក្តីណែនាំស្តីពីការកំណត់ចំនួនទឹកប្រាក់ក្នុងការអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនសម្រាប់កាស៊ីណូ និងគ្រឹះស្ថានល្បែងស៊ីសងផ្សេងៗ ស្របតាមស្តង់ដានិងឧត្តមានុវត្តអន្តរជាតិ។

សម្រាប់ឆ្នាំ២០២០នេះ ស.ហ.ក បានបន្តជាប្រក្រតីក្នុងការពិនិត្យនិងតាមដានលើការអនុវត្តកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ក្នុងនោះមានការវាយតម្លៃគុណវុឌ្ឍិនិងបទពិសោធន៍របស់មន្ត្រីប្រតិបត្តិតាមរយៈប្រព័ន្ធអនឡាញ និងជួបពិភាក្សាអំពីវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍នៅក្នុងរបាយការណ៍ត្រួតពិនិត្យដល់ទីកន្លែងជាមួយគ្រឹះស្ថានធនាគារចំនួន ១២ តាមរយៈប្រព័ន្ធអនឡាញ។

ទន្ទឹមនេះ កាលពីថ្ងៃទី២០-២១ ខែកុម្ភៈ ឆ្នាំ២០២០ ស.ហ.ក បានរៀបចំសិក្ខាសាលាចំនួន ៤លើក ដើម្បីផ្សព្វផ្សាយប្រកាសស្តីពីការដាក់ទណ្ឌកម្មខាងវិន័យដល់គ្រឹះស្ថានធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គ្រឹះស្ថានផ្តល់សេវាទូទាត់ ក្រុមហ៊ុនអចលនទ្រព្យ កាស៊ីណូ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ អាជីវកម្មប្តូរប្រាក់ និងមុខរបរវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុដែលជាបុគ្គលរាយការណ៍ទាំងអស់ ដោយមានសិក្ខាកាមចូលរួមសរុបចំនួន ៣៣៨រូប។ កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ ស.ហ.ក បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដល់បញ្ញត្តិករ មន្ត្រីអនុវត្តច្បាប់ ព្រះរាជអាជ្ញា និងចៅក្រម ចំនួន ១១០រូប មកពីក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន ២៣ និងដល់បុគ្គលរាយការណ៍ក្នុងវិស័យធនាគារ កាស៊ីណូ និងអចលនទ្រព្យ កាលពីថ្ងៃទី២៣-២៦ ខែវិច្ឆិកា ឆ្នាំ២០២០ ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ ក៏ដូចជាជំរុញប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការក្នុងស្រុក និងក្នុងតំបន់ក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្ម និងការរីករាលដាលនៃការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

## ៣-ការពង្រឹងក្របខ័ណ្ឌស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម បានកែលម្អក្របខ័ណ្ឌស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មឱ្យកាន់តែច្បាស់មួយកម្រិតទៀត។ ម្យ៉ាងទៀត

រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ១៥២ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ ដើម្បីកំណត់រចនាសម្ព័ន្ធគ្រប់គ្រងរបស់ ស.ហ.ក ឱ្យស្របតាមស្ថានភាពវិវត្តថ្មីៗ និងទំហំការងារជាក់ស្តែងរបស់ ស.ហ.ក។ បន្ទាប់មក ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យក្រោមឱវាទរបស់នាយកដ្ឋាននីមួយៗ កាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០។ ទន្ទឹមនេះ ដើម្បីមានជាយន្តការជាន់ខ្ពស់ថ្នាក់ជាតិមួយ គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១៦០ អនក្រ.បក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ផងដែរ។

## ៤-កិច្ចសហប្រតិបត្តិការ

### ក- កិច្ចសហប្រតិបត្តិការក្នុងស្រុក

ក្នុងឆ្នាំ២០២០នេះ ស.ហ.ក បានចុះអនុស្សរណៈយោគយល់ស្តីពីការផ្លាស់ប្តូរព័ត៌មានជាមួយក្រសួង-ស្ថាប័នមួយចំនួន និងកំពុងពិភាក្សាជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធសំខាន់ៗផ្សេងទៀត ដើម្បីបន្តចុះអនុស្សរណៈយោគយល់ក្នុងការផ្លាស់ប្តូរព័ត៌មានទាំងនេះ។

ស.ហ.ក បានជួបប្រជុំជាប្រចាំជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិចំនួន ៣លើក ដើម្បីពិនិត្យនិងពិភាក្សាលើ ៖ i/-យន្តការនៃការផ្លាស់ប្តូរព័ត៌មាន ii/-មតិឆ្លើយតបលើការប្រើប្រាស់ព័ត៌មាន និង iii/-វឌ្ឍនភាពនៃការស៊ើបអង្កេតការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម សម្រាប់ផ្តល់ជូនក្រុមការងារត្រួតពិនិត្យរួមគ្នា នៃប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ (ICRG-JG)។ ចំពោះកិច្ចសហប្រតិបត្តិការពហុភាគី ស.ហ.ក បានជួបប្រជុំជាមួយក្រសួង-ស្ថាប័ន ដែលជាសមាជិកក្រុមការងារបច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ចំនួន ៥លើក ដើម្បីពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់ក្រុមការងារ ICRG-JG និងផែនការសកម្មភាពនៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៩-២០២៣។ ដោយឡែក ស.ហ.ក បានចូលរួមការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ស្របតាមផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

### ខ- កិច្ចសហប្រតិបត្តិការអន្តរជាតិ

ស.ហ.ក ក៏បានចុះអនុស្សរណៈយោគយល់ស្តីពីការផ្លាស់ប្តូរព័ត៌មានទាក់ទងនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុនីហ្សេរីយ៉ា ម៉ាដាហ្គាស្កា នូវែលសេឡង់ និងឥណ្ឌា។

ចំពោះកិច្ចសហប្រតិបត្តិការពហុភាគី ស.ហ.ក បានសហការជាមួយក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (APG) ដើម្បីពង្រឹងប្រព័ន្ធប្រឆាំងការសម្អាតប្រាក់នៅក្នុងតំបន់ និងការដំឡើងចំណាត់ថ្នាក់របស់ប្រទេសកម្ពុជា។ ក្នុងនោះ ស.ហ.ក បានបន្តចូលរួមកិច្ចប្រជុំពិភាក្សាមួយចំនួនជាមួយ APG អំពីបញ្ហាប្រឈមថ្មីៗនិងការរៀបចំគោលនយោបាយឆ្លើយតបពាក់ព័ន្ធនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មក្នុងតំបន់។

ទន្ទឹមនេះ ស.ហ.ក បានសហការជាមួយក្រុមអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ (Egmont Group) ក្នុងការចូលរួមសិក្ខាសាលាតាមប្រព័ន្ធអនឡាញ សម្រាប់ប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ

ដែលរៀបចំដោយលេខាធិការដ្ឋាន Egmont ក្នុងគោលបំណងពិភាក្សា និងចែករំលែកបទពិសោធន៍ដល់សមាជិកក្រុម Egmont ពាក់ព័ន្ធនឹងហានិភ័យនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលបណ្តាលមកពីការវិវត្តថ្មីៗនៃបច្ចេកវិទ្យា នៅក្នុងបទល្មើសសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដូចជា បច្ចេកវិទ្យាហិរញ្ញវត្ថុ អ្នកផ្តល់សេវាទ្រព្យសកម្មនិម្មិត និងអ្នកផ្តល់សេវាទូទាត់តាមទូរស័ព្ទ និងបានចូលរួមកិច្ចប្រជុំ ក៏ដូចជាផ្តល់ធាតុចូលដល់ក្រុមការងារប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (Asia Pacific Regional Group) ដែលរៀបចំដោយលេខាធិការដ្ឋាន Egmont ជាប្រចាំ ដើម្បីតាមដានពីវឌ្ឍនភាពគម្រោងថ្មី និងការកែសម្រួលអំពីគោលនយោបាយនិងនីតិវិធីការផ្លាស់ប្តូរព័ត៌មាន ជំនួយបច្ចេកទេស និងការចូលជាសមាជិកភាពរបស់ប្រទេសមួយចំនួនរបស់ក្រុម Egmont។

## VII- កិច្ចសហប្រតិបត្តិការអន្តរជាតិ

### ១- កិច្ចសហប្រតិបត្តិការពហុភាគី

ទោះក្នុងកាលៈទេសៈដែលជំងឺកូវីដ-១៩កំពុងរាតត្បាតជាសកល ធនាគារជាតិនៃកម្ពុជាបន្តខិតខំពង្រឹងកិច្ចសហការប្រតិបត្តិការជាមួយស្ថាប័នអន្តរជាតិដែលជាដៃគូតាមរយៈការចូលរួមក្នុងកិច្ចប្រជុំ និងសិក្ខាសាលា តាមប្រព័ន្ធអនឡាញ និងការចូលជួបពិភាក្សាជាមួយអ្នកតំណាងស្ថាប័នប្រចាំនៅកម្ពុជា ជាដើម។ កិច្ចសហប្រតិបត្តិការពហុភាគីសំខាន់ៗ រួមមាន៖ i/-មូលនិធិរូបិយវត្ថុអន្តរជាតិបានបន្តផ្តល់ជំនួយបច្ចេកទេស ពិសេសទៅលើការពង្រឹងការងារចងក្រងស្ថិតិវិស័យក្រៅប្រទេស និងការចងក្រងសន្ទស្សន៍ថ្លៃអចលនទ្រព្យ និងការជួយតាមដានស្ថានភាពសេដ្ឋកិច្ច ii/-ធនាគារពិភពលោកបានផ្តល់ជំនួយបច្ចេកទេសដល់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការសិក្សាវាយតម្លៃទីផ្សារផ្ទេរប្រាក់អន្តរជាតិ iii/-ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ជំនួយបច្ចេកទេសក្នុងការអនុវត្តអនុកម្មវិធីទី៣នៃកម្មវិធីអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុប្រកបដោយបរិយាបន្ន ដែលពាក់ព័ន្ធនឹងប្រព័ន្ធទូទាត់សងប្រាក់ បរិយាបន្នហិរញ្ញវត្ថុ និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ។

ចំពោះកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ាន ធនាគារជាតិនៃកម្ពុជាបានបន្តរួមចំណែកនិងសហការសម្រេចនូវវឌ្ឍនភាពសំខាន់ៗ ដូចជា៖ i/-ការពិនិត្យ និងដាក់ឱ្យអនុវត្តផែនទីវាយតម្លៃសេរីភាវូបនីយកម្មគណនីមូលធននិងអនុម័តសេចក្តីព្រាងចុងក្រោយស្តីពីក្របខ័ណ្ឌទូទាត់ជារូបិយវត្ថុក្នុងតំបន់អាស៊ាន ii/-ការចុះហត្ថលេខាលើកញ្ចប់ទី៨ និងបន្តការចរចាលើការប្តេជ្ញាសេវាហិរញ្ញវត្ថុក្នុងកញ្ចប់ទី៩ iii/-ការអនុវត្តក្របខ័ណ្ឌគោលនយោបាយសម្រាប់ការភ្ជាប់ប្រព័ន្ធទូទាត់រាយភ្លាមៗ តាមរយៈការភ្ជាប់ប្រព័ន្ធទូទាត់ជាមួយប្រទេសក្នុងតំបន់ iv/-ការពង្រឹងតួនាទីទីផ្សារមូលធនអាស៊ានសំដៅគាំទ្រការធ្វើហិរញ្ញប្បទានហេដ្ឋារចនាសម្ព័ន្ធ លើកកម្ពស់កម្មវិធីហិរញ្ញប្បទានបៃតង និងបង្កើតក្រុមការងារសម្រាប់ធ្វើហិរញ្ញប្បទានប្រកបដោយចីរភាព និងហិរញ្ញប្បទានហេដ្ឋារចនាសម្ព័ន្ធ v/-ការផ្លាស់ប្តូរបទពិសោធន៍ស្តីពីក្របខ័ណ្ឌធនាគារឌីជីថល, រៀបចំផែនទីបង្ហាញផ្លូវដើម្បីធ្វើឱ្យប្រសើរឡើងនូវការបន្សីបទប្បញ្ញត្តិចំពោះការអនុវត្តក្របខ័ណ្ឌបាសែលលើផ្នែកដើមទុន និង IFRS9, និងបញ្ចប់សម្រង់បញ្ជីអំពីបទដ្ឋាននៃការត្រួតពិនិត្យ និងការគ្រប់គ្រង ស្រោចស្រង់ និងដោះស្រាយវិបត្តិ vi/-ការជំរុញការដាក់ចេញនូវគោលនយោបាយគាំទ្រនានា ដើម្បីលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុក្នុងតំបន់ និងបានឯកភាពចាប់ផ្តើមរៀបចំទិវាសន្សំអាស៊ាន នៅរៀងរាល់ថ្ងៃទី៣១ ខែតុលា vii/-ការគាំទ្រការកសាង

សមត្ថភាពមន្ត្រីធនាគារកណ្តាលរបស់ប្រទេស BCLMV ក្រោមសសរស្តម្ភ៣[២៦] viii/-ការចុះអនុស្សរណៈយោគយល់ ពាក់ព័ន្ធនឹងផ្លែតហ្វមចែករំលែកព័ត៌មាននិង Cybersecurity Resilience អាស៊ាន (CRISP) និង ix/-ការបញ្ចប់ភាពជាសហប្រធាននៃកិច្ចប្រជុំគណៈកម្មាធិការជាន់ខ្ពស់អាស៊ានរបស់ធនាគារជាតិនៃកម្ពុជាជាមួយធនាគារកណ្តាលឥណ្ឌូណេស៊ីដោយជោគជ័យក្នុងរយៈពេល២ឆ្នាំកន្លងទៅ ហើយធនាគារជាតិនៃកម្ពុជាក៏ត្រូវបានជ្រើសរើសធ្វើជាសហប្រធានគណៈកម្មការបរិយាបន្នហិរញ្ញវត្ថុអាស៊ាន (WC-FINC) ជាមួយធនាគារកណ្តាលឥណ្ឌូណេស៊ី សម្រាប់រយៈពេល ២ឆ្នាំ ដោយចាប់ផ្តើមពីខែសីហា ឆ្នាំ២០២០ និងបញ្ចប់នៅខែកុម្ភៈ ឆ្នាំ២០២២ ផងដែរ។

ក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអាស៊ាន+៣ ការងារសំខាន់ដែលសម្រេចបាន រួមមាន៖ i/-ការធ្វើវិសោធនកម្មនៃកិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM) ក្នុងនោះរួមមានការដំឡើងទំហំទឹកប្រាក់ឥណទាននៃ CMIM មិនភ្ជាប់ជាមួយលក្ខខណ្ឌរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF Delinked Portion) ពី ៣០% ទៅ ៤០% និងការប្រើប្រាស់រូបិយវត្ថុក្នុងស្រុកសម្រាប់យន្តការ CMIM អាស្រ័យតាមគោលការណ៍ស្ម័គ្រចិត្ត និងតម្រូវការជាក់ស្តែង ii/-ការកែសម្រួលគោលការណ៍ប្រតិបត្តិនៃកិច្ចព្រមព្រៀង CMIM iii/-ការពង្រឹងការអនុវត្តប្រតិបត្តិការ CMIM តាមរយៈការធ្វើការសាកល្បង (Test Run) លើកទី១១ ដោយមានការដកសាច់ប្រាក់ជាក់ស្តែង iv/-ការអនុម័តផែនការសកម្មភាពរយៈពេលមធ្យមរបស់អង្គភាព AMRO ឆ្នាំ២០២០-២០២៤ v/-ការបង្កើតក្រុមការងារដើម្បីសិក្សាពីគំនិតផ្តួចផ្តើមថ្មីៗដើម្បីពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន+៣ និង vi/-ការជំរុញការចេញផ្សាយសញ្ញាបណ្ណជារូបិយវត្ថុក្នុងស្រុកសំដៅកៀរគរការសន្សំនិងការវិនិយោគក្នុងតំបន់។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានពង្រឹងកិច្ចសហប្រតិបត្តិការ៖ i/-ជាមួយមូលនិធិអភិវឌ្ឍន៍មូលធនរបស់អង្គការសហប្រជាជាតិ (UNCDF) តាមរយៈការចុះកិច្ចព្រមព្រៀងថ្មីមួយទៀតដើម្បីរៀបចំធ្វើការប្រមូលទិន្នន័យសម្រាប់ធ្វើជាសូចនាករមូលដ្ឋាន (Baseline Indicators) ii/-ជាមួយគណៈកម្មាធិការជាតិអេស្កាប់ (UNESCAP) ដោយបានចុះកិច្ចព្រមព្រៀងលើជំនួយបច្ចេកទេសសម្រាប់គម្រោងចំនួន ៤ រួមមាន៖ ការសិក្សាពីលទ្ធភាពទទួលបានឥណទានដោយមិនចាំបាច់មានទ្រព្យធានា, ការពង្រីកសមត្ថភាពរបស់ធនាគារជាតិនៃកម្ពុជា, កិច្ចសហការជាមួយក្រសួងកិច្ចការនារីក្នុងការជំរុញបរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី និងការរៀបចំយុទ្ធនាការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ "ការប្រើ-ប្រាស់លុយដោយភាពវៃឆ្លាត" ក្រោមកិច្ចសហការជាមួយអង្គការ Good Return និង iii/-ជាមួយសហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ (Alliance for Financial Inclusion – AFI) ដោយបានចាត់បញ្ជូនមន្ត្រីចូលរួមក្នុងកិច្ចប្រជុំ និងកម្មវិធីបណ្តុះបណ្តាលនានារបស់ AFI តាមប្រព័ន្ធអនឡាញ។ លើសពីនេះ មន្ត្រីធនាគារជាតិនៃកម្ពុជាក៏បានចូលរួមធ្វើជាវាគ្មិនចែករំលែកពីការអនុវត្តនិងបទពិសោធន៍នានាដែលបាននិងកំពុងអនុវត្ត ជាពិសេសលើប្រធានបទពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុដែលកំពុងមានតួនាទីសំខាន់ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។ ធនាគារជាតិនៃកម្ពុជា ក៏បាននិងកំពុងពិភាក្សានិងសិក្សាអំពី

---

[២៦] សសរស្តម្ភ៣៖ A (វគ្គបណ្តុះបណ្តាលមូលដ្ឋានដែលផ្តល់លទ្ធភាពឱ្យមានអ្នកចូលរួមបានច្រើន) B (លើការពង្រឹងសមត្ថភាពក្រុមការងារជំនាញ ការចែករំលែកបទពិសោធន៍ពីគ្នាទៅវិញទៅមក និងការពិភាក្សាក្នុងតំបន់) និង C (ការធ្វើទស្សនកិច្ចសិក្សានៅបណ្តាប្រទេសអាស៊ាន-៥)។

លទ្ធភាពនៃកិច្ចសហការជាមួយ AFI ចំពោះការអនុវត្តសកម្មភាពមួយចំនួនពាក់ព័ន្ធនឹងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុផងដែរ។

### ២- កិច្ចសហប្រតិបត្តិការទ្វេភាគី

នាដើមឆ្នាំ២០២០ ធនាគារកណ្តាលថៃបានរៀបចំកិច្ចប្រជុំទ្វេភាគីនៅទីក្រុងបាងកក ប្រទេសថៃ។ នាឱកាសនោះដែរ ធនាគារជាតិនៃកម្ពុជានិងធនាគារកណ្តាលថៃបានដាក់ឱ្យដំណើរការជាផ្លូវការសេវាទូទាត់ឆ្លងដែនតាមរយៈ QR កូត រវាងប្រទេសកម្ពុជានិងប្រទេសថៃ និងកំពុងបន្តអនុវត្តការភ្ជាប់ប្រព័ន្ធទូទាត់រាយជាមួយប្រទេសផ្សេងៗទៀតក្នុងតំបន់។ ធនាគារជាតិនៃកម្ពុជាក៏បានរៀបចំកិច្ចប្រជុំទ្វេភាគីប្រចាំឆ្នាំជាមួយធនាគារកណ្តាលវៀតណាមនិងឡាវ តាមរយៈប្រព័ន្ធអនឡាញផងដែរ។

ធនាគារជាតិនៃកម្ពុជាបានចុះកិច្ចព្រមព្រៀងជាមួយធនាគារកណ្តាលកូរ៉េ ក្នុងការសហការស្រាវជ្រាវរួមគ្នាក្រោមប្រធានបទ "ប្រតិបត្តិការរូបិយវត្ថុនិងគោលនយោបាយប្តូរប្រាក់" និងបានចូលរួមរៀបចំកម្មវិធី Singapore Fintech Festival នៅកម្ពុជា ក្នុងនាមជាទីក្រុងដៃគូជាមួយសិង្ហបុរី (Partner City) ផងដែរ។

## VIII- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា

### ១- សមាសភាព និងសកម្មភាពក្រុមប្រឹក្សាភិបាល

បច្ចុប្បន្ន ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| - | ឯកឧត្តម ជា ចាន់តូ | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ជាប្រធាន |
| - | លោកជំទាវ នាវ ច័ន្ទថាណា | ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | ជាសមាជិកា |
| - | ឯកឧត្តម ជូ គឹមឡេង | តំណាងប្រមុខរាជរដ្ឋាភិបាល | ជាសមាជិក |
| - | ឯកឧត្តម អ៊ីវ ចុង | តំណាងឱ្យមជ្ឈដ្ឋានឧត្តមសិក្សា | ជាសមាជិក |
| - | ឯកឧត្តម រស់ សីលវ៉ា | តំណាងឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| - | ឯកឧត្តម ឡាយ ម៉េងស៊ុន | តំណាងឱ្យមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច | ជាសមាជិក និង |
| - | លោក មុំ ដារ៉េត | តំណាងឱ្យបុគ្គលិកធនាគារជាតិនៃកម្ពុជា | ជាសមាជិក។ |

ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាបានជួបប្រជុំចំនួន ៦ លើក គឺកិច្ចប្រជុំក្រុមប្រឹក្សាភិបាល៖

- លើកទី១៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៣៨ កាលពីថ្ងៃព្រហស្បតិ៍ ១៣កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២០ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងសេចក្តីសម្រេចស្តីពី ការបង្កើតគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យ ធនាគារជាតិនៃកម្ពុជា សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៩ និងរបាយការណ៍ស្តីពី ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុប្រចាំត្រីមាសទី៣ ឆ្នាំ២០១៩។

- លើកទី២៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៣៩ កាលពីថ្ងៃពុធ ៤រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ស្ថានភាពថវិកាធនាគារជាតិនៃកម្ពុជាឆ្នាំ២០១៩ និងផែនការឆ្នាំ២០២០។

- លើកទី៣៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៤០ កាលពីថ្ងៃពុធ ១៤រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ ដើម្បីពិនិត្យរបាយការណ៍ស្តីពីសកម្មភាពការងារគ្រប់គ្រងទុនបម្រុងវិនិយោគឆ្នាំ២០១៩។

- លើកទី៤៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៤១ កាលពីថ្ងៃព្រហស្បតិ៍ ៥កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២០។

- លើកទី៥៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៤២ កាលពីថ្ងៃចន្ទ ១៤កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៣ ខែសីហា ឆ្នាំ២០២០ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងប្រកាសស្តីពីរចនាសម្ព័ន្ធនិងមុខងារ-ភារកិច្ចរបស់អគ្គនាយកដ្ឋានត្រួតពិនិត្យនិងបណ្តានាយកដ្ឋានក្រោមឱវាទ និង

- លើកទី៦៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៤៣ កាលពីថ្ងៃចន្ទ ១៤រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១។

## ២- ការអភិវឌ្ឍធនធានមនុស្ស

ការគ្រប់គ្រងធនធានមនុស្សត្រូវបានអភិវឌ្ឍជាប្រចាំ ស្របតាមការរីកចម្រើនវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសមាហរណកម្មនៅក្នុងតំបន់និងពិភពលោក ក៏ដូចជាគោលការណ៍ស្ថិរភាពនិងប្រសិទ្ធភាពការងារ។

### ក- ស្ថិតិមន្ត្រីបុគ្គលិក

សរុបក្របខ័ណ្ឌមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទូទាំងប្រទេសប្រចាំឆ្នាំ២០២០នេះ មានចំនួន ១៧៤២ រូប (ប្រុស ៨៩៧ រូប ស្រី ៨៤៥ រូប) ក្នុងនោះទីស្នាក់ការកណ្តាលមាន ១.២៥២រូប (ប្រុស ៦៦៤រូប ស្រី៥៨៨រូប) និងសាខារាជធានី-ខេត្ត មាន ៤៩០រូប (ប្រុស២៣៣រូប ស្រី២៥៧រូប)។ ក្របខ័ណ្ឌមន្ត្រីនៅទីស្នាក់ការកណ្តាលកើនឡើង ៤៤រូប (ជ្រើសរើសថ្មី ៦២រូប, ផ្ទេរចូល ១រូប, ផ្ទេរចេញ ២រូប, ចូលនិវត្តន៍ ៥រូប, លាឈប់ ៦រូប, លុបឈ្មោះ ៤រូប និងមរណភាព ២រូប) ខណៈនៅសាខាខេត្តកើនឡើង ៣៣រូប (ជ្រើសរើសថ្មី៣៨រូប ផ្ទេរចូល១រូប ផ្ទេរចេញ១រូប ចូលនិវត្តន៍ ៤រូប មរណភាព១រូប)។

**តារាង ១៖ ស្ថិតិមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា ប្រចាំឆ្នាំ២០២០**

| | | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ប្រែប្រួល |
|---|---|---|---|---|---|---|
| **ទីស្នាក់ការកណ្តាល** | ប្រុស | ៦២២ | ៦៤២ | ៦៤២ | ៦៦៤ | ២២ |
| | ស្រី | ៥៥៣ | ៥៥០ | ៥៦៦ | ៥៨៨ | ២២ |
| | សរុប | **១១៧៥** | **១១៩២** | **១២០៨** | **១២៥២** | **៤៤** |
| **សាខា** | ប្រុស | ២៣៥ | ២៣២ | ២២៤ | ២៣៣ | ៩ |
| | ស្រី | ២៤៤ | ២៤១ | ២៣៣ | ២៥៧ | ២៤ |
| | សរុប | **៤៧៩** | **៤៧៣** | **៤៥៧** | **៤៩០** | **៣៣** |
| **សរុបទូទាំងប្រទេស** | ប្រុស | ៨៥៧ | ៨៧៤ | ៨៦៦ | ៨៩៧ | ៣១ |
| | ស្រី | ៧៩៧ | ៧៩១ | ៧៩៩ | ៨៤៥ | ៤៦ |
| | សរុប | **១៦៥៤** | **១៦៦៥** | **១៦៦៥** | **១៧៤២** | **៧៧** |

## ខ- ការបណ្តុះបណ្តាល

### - ការបណ្តុះបណ្តាលក្នុងប្រទេស

ធនាគារជាតិនៃកម្ពុជាបានបន្តអភិវឌ្ឍសមត្ថភាពមន្ត្រីបុគ្គលិកតាមរយៈការបើកវគ្គសិក្ខាសាលាចំនួន៦លើក មានសិក្ខាកាមចូលរួម ៩១៨រូប វគ្គសិក្សាចំនួន៤លើក សិក្ខាកាមចូលរួម ៣៥៥រូប កិច្ចប្រជុំចំនួន៤លើក មន្ត្រីបុគ្គលិកចូលរួម ៧១៧រូប និងបានរៀបចំកម្មវិធីចុះកម្មសិក្សានៅធនាគារជាតិនៃកម្ពុជាជូនសិស្ស-និស្សិតមកពីបណ្តាគ្រឹះស្ថានឧត្តមសិក្សាចំនួន១២លើក (សិស្ស-និស្សិតចូលរួម ១៥៣រូប)។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានបន្តបណ្តុះបណ្តាលមន្ត្រីបុគ្គលិកតាមប្រព័ន្ធអនឡាញ ចំនួន ២វគ្គ គឺ i/-កម្មវិធីបណ្តុះបណ្តាល NBC FSI Connect ជំនាញត្រួតពិនិត្យធនាគារ ក្រោមកម្មវិធីរបស់វិទ្យាស្ថានស្ថិរភាពហិរញ្ញវត្ថុនៃធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) មាន៤ជំនាន់ សិក្ខាកាមចូលរួមសិក្សាសរុប ៣០៣រូប ដែលក្នុងនោះមានសិក្ខាកាមអាហារូបករណ៍ ២៥រូប និងបានរៀបចំការប្រឡងអនឡាញជាផ្លូវការដើម្បីវាយតម្លៃគុណភាពសិក្សាជាបន្តបន្ទាប់ ហើយមានមន្ត្រីបុគ្គលិកប្រឡងបញ្ចប់កម្រិតបឋមមានចំនួន ១៨៣រូប កម្រិតមធ្យម ៦១រូប និងកម្រិតខ្ពស់ ១៥រូប និង ii/- កម្មវិធីបណ្តុះបណ្តាល NBC-IMF ស្តីពីកម្មវិធីនិងគោលនយោបាយហិរញ្ញវត្ថុ (FPP) របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) មាន២កម្រិត ហើយធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការចំនួន ២ជំនាន់រួចមកហើយ ដែលមានសិក្ខាកាមសរុបចំនួន១៦៣រូប ក្នុងនោះមន្ត្រីបុគ្គលិកជំនាន់ទី១ មានចំនួន៥៥រូប បានប្រឡងបញ្ចប់កម្មវិធីសិក្សាទាំងពីរកម្រិតតាមប្រព័ន្ធអនឡាញ ជាផ្លូវការដោយជោគជ័យ។ រីឯមន្ត្រីបុគ្គលិកជំនាន់ទី២មាន ១០៨រូប បានប្រឡងបញ្ចប់កម្រិត១ តាមប្រព័ន្ធអនឡាញជាផ្លូវការ និងកំពុងបន្តសិក្សានិងត្រៀមប្រឡងបញ្ចប់កម្រិត២នៅចុងឆ្នាំ២០២០នេះផងដែរ។

ម្យ៉ាងទៀត មណ្ឌលសិក្សាបច្ចេកទេសធនាគារបានរួមចំណែកអភិវឌ្ឍធនធានមនុស្សក្នុងវិស័យធនាគារ ដែលបច្ចុប្បន្ននិស្សិតកំពុងសិក្សាមាន ២៦៥រូប ដែលក្នុងនោះ និស្សិតជំនាន់ទី២៨មាន ១៣២រូប (ស្រី ៩៩រូប) និងជំនាន់ទី២៩មាន ១៣៣រូប (ស្រី ១០៧រូប)។ កម្មវិធីសិក្សានិងសៀវភៅមុខវិជ្ជាជំនាញត្រូវបានធ្វើបច្ចុប្បន្នកម្ម ស្របតាមការអភិវឌ្ឍរីកចម្រើននៃវិស័យធនាគារនិងហិរញ្ញវត្ថុ និងតាមគោលការណ៍ស្តង់ដានិងលក្ខណៈបច្ចេកទេសនៃគុណភាពអប់រំជាតិ។ សាស្ត្រាចារ្យមាន ៥៩រូប ដែលក្នុងនោះសាស្ត្រាចារ្យជាមន្ត្រីធនាគារជាតិនៃកម្ពុជាមាន ៤៧រូប។ មណ្ឌលសិក្សាបច្ចេកទេសក៏បានរៀបចំអភិវឌ្ឍវេទិកា Digital Platform ដើម្បីបណ្តុះបណ្តាលនិងដាក់ឱ្យដំណើរការកម្មវិធីសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក (CBS E-Learning) ជូននិស្សិតទាំងពីរជំនាន់ ក្រោមកិច្ចសហការលក្ខណៈបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និងកីឡា និងអ្នកជំនាញក្រុមហ៊ុន Google នៅកម្ពុជា។

**តារាង ២ ៖ ស្ថិតិនិស្សិតនៅមណ្ឌលសិក្សាបច្ចេកទេសធនាគារឆ្នាំ២០២០**

| បរិយាយ | ជំនាន់ទី២៨ | | | ជំនាន់ទី២៩ | | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| វគ្គសិក្សាទី៥១និងទី៥២ | ៣៣ | ៩៩ | ១៣២ | ២៦ | ១០៧ | ១៣៣ |
| និស្សិតជំនាន់ទី២៨ និងទី២៩ | សរុប ២៦៥រូប (ស្រី ២០៦រូប, ប្រុស ៥៩រូប) | | | | | |

**តារាង ៣ ៖ ស្ថិតិសាស្ត្រាចារ្យនៅមណ្ឌលសិក្សាបច្ចេកទេសធនាគារឆ្នាំ២០២០**

| បរិយាយ | ជំនាន់ទី២៨ (ឆ្នាំទី២) | | | ជំនាន់ទី២៩ (ឆ្នាំទី១) | | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| បរិញ្ញាបត្រ | ១ | ២ | ៣ | ១ | ០ | ១ |
| បរិញ្ញាបត្រជាន់ខ្ពស់ | ១៩ | ៤ | ២៣ | ២៤ | ៥ | ២៩ |
| បណ្ឌិត | ៣ | ០ | ៣ | ០ | ០ | ០ |
| សរុប | ២៣ | ៦ | ២៩ | ២៥ | ៥ | ៣០ |
| **សរុបជំនាន់ទី២៨ និង២៩** | **៥៩ រូប (ប្រុស ៤៨រូប, ស្រី ១១រូប)** | | | | | |

**- ការបណ្តុះបណ្តាលក្រៅប្រទេស**

ធនាគារជាតិនៃកម្ពុជាបានបន្តបង្កើនសមត្ថភាពនិងអភិវឌ្ឍធនធានមនុស្សនៅក្រៅប្រទេស តាមរយៈ ការចាត់តាំងមន្ត្រីបុគ្គលិកឱ្យចូលរួមវគ្គសិក្សារយៈពេលខ្លីចំនួន ២៨លើក (មន្ត្រីបុគ្គលិកចូលរួមចំនួន ៣៤រូប) វគ្គសិក្សារយៈពេលវែងថ្នាក់បណ្ឌិត ចំនួន ១លើក អនុបណ្ឌិត ចំនួន ៧លើក (មន្ត្រីបុគ្គលិកចូលរួមចំនួន ៩រូប) ប្រជុំចំនួន ៣២លើក (មន្ត្រីបុគ្គលិកចូលរួមចំនួន ៩២រូប)។ ដោយសារវិបត្តិជំងឺកូវីដ-១៩ ការបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំក្រៅប្រទេសភាគច្រើនត្រូវធ្វើតាមប្រព័ន្ធអនឡាញជំនួសវិញ។ ទន្ទឹមនឹងការបណ្តុះបណ្តាលជំនាញបច្ចេកទេស ធនាគារជាតិនៃកម្ពុជាក៏បានយកចិត្តទុកដាក់ក្នុងការលើកកម្ពស់គុណភាពស្រាវជ្រាវ និងបានលើកទឹកចិត្តដល់មន្ត្រីបុគ្គលិកបន្តខិតខំសិក្សាស្រាវជ្រាវជុំវិញប្រធានបទស្តីអំពីសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីចងក្រងជាអត្ថបទស្រាវជ្រាវជាលក្ខណៈវិទ្យាសាស្ត្រ។

## ៣- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ

ធនាគារជាតិនៃកម្ពុជាបានបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរឹងមាំ តាមរយៈការដាក់ចេញនូវគោលការណ៍និងសេចក្តីណែនាំផ្សេងៗ ដែលជាមូលដ្ឋានគ្រឹះក្នុងការការពារហានិភ័យ និងជួយឱ្យប្រតិបត្តិការប្រចាំថ្ងៃប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព។ ភាពរឹងមាំនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងការប្រតិបត្តិត្រឹមត្រូវតាមគោលការណ៍ និងសេចក្តីណែនាំ ត្រូវបានធានាតាមរយៈការធ្វើសវនកម្មផ្ទៃក្នុង និងអធិការកិច្ច។

ការងារសវនកម្មនៅស្នាក់ការកណ្តាល ត្រូវបានអនុវត្តលើការងារគ្រប់គ្រងទុនបម្រុង ការងារប្រតិបត្តិការសាច់ប្រាក់ ការងារគ្រប់គ្រងឧបករណ៍អាចជួញដូរបាន និងការងារផ្តល់សន្ទនីយភាព។ ចំពោះសាខា បានអនុវត្តនៅខេត្តចំនួន ៨ ដោយគ្របដណ្តប់លើគ្រប់សកម្មភាពប្រតិបត្តិការ។ រីឯការងារអធិការកិច្ច ត្រូវបានអនុវត្តនៅសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តចំនួន ១២ លើការគ្រប់គ្រង និងរក្សាសុវត្ថិភាពសាច់ប្រាក់។

គណៈកម្មការគ្រប់គ្រងហានិភ័យបានរៀបចំកិច្ចប្រជុំចំនួន ៥លើក ដើម្បីពិនិត្យ និងពិភាក្សាលើការការពារហានិភ័យពាក់ព័ន្ធនឹងដំណើរការប្រព័ន្ធ Flexcube បញ្ហាប្រឈមនិងការរៀបចំនីតិវិធីការងារក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ និងការធ្វើបច្ចុប្បន្នកម្ម ផែនការនិរន្តរភាពធុរកិច្ចសម្រាប់ប្រព័ន្ធ Flexcube។

ទន្ទឹមនេះ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការគ្រប់គ្រងហានិភ័យ ធនាគារជាតិនៃកម្ពុជា បានរៀបចំការបណ្តុះបណ្តាលចែករំលែកចំណេះដឹង ដល់មន្ត្រីបុគ្គលិកសាខាធនាគារជាតិនៃកម្ពុជារាជធានីខេត្តចំនួន ៦ (ខេត្តតាកែវ កំពង់ធំ ក្រចេះ បាត់ដំបង ស្ទឹងត្រែង និងបន្ទាយមានជ័យ)។

## ៤- ការគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជាបាននិងកំពុងពង្រឹងនិងពង្រីកសមត្ថភាពប្រតិបត្តិការនៅតាមសាខារាជធានី-ខេត្ត សំដៅគ្រប់គ្រងការធ្វើចរាចរសាច់ប្រាក់នៅក្នុងប្រព័ន្ធធនាគារឱ្យបានកាន់តែទូលំទូលាយតាមរយៈការផ្តល់សេវា (គ្រប់គ្រងគណនីប្រាក់បញ្ញើ ទទួលនិងបើកសាច់ប្រាក់ និងសេវាផ្ទេរប្រាក់) ជូនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រសួង មន្ទីរ និងអង្គភាពរបស់រាជរដ្ឋាភិបាលឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។ លើសពីនេះ សាខាធនាគារជាតិនៃកម្ពុជា រាជធានី-ខេត្តបានផ្តល់សេវាប្តូរក្រដាសប្រាក់រៀលចាស់ សឹករេចរឹល ទក់របែហក ជូនដល់សាធារណជន ក្នុងគោលដៅជំរុញការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត បានបន្តសហការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល។ ក្រៅពីនេះ សាខាធនាគារជាតិនៃកម្ពុជាក៏បានចូលរួមតាមដានស្ថានភាពសេដ្ឋកិច្ចក្នុងតំបន់ដូចជា ការប្រែប្រួលថ្លៃ អត្រាប្តូរប្រាក់ និងសូចនាករម៉ាក្រូសេដ្ឋកិច្ចដទៃទៀត ដែលរួមចំណែកក្នុងការតាមដានស្ថានភាពសេដ្ឋកិច្ចជារួម និងការអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា។ ម្យ៉ាងទៀត មន្ត្រីជំនាញនៅតាមសាខាក៏បានផ្តល់ព័ត៌មានអំពីការប្រើប្រាស់សេវាហិរញ្ញវត្ថុដល់សាធារណជនតាមប្រព័ន្ធ Hotline ផងដែរ។

## សន្និដ្ឋាន

នៅឆ្នាំ២០២០នេះ សេដ្ឋកិច្ចកម្ពុជាបានទទួលរងឥទ្ធិពលនៃវិបត្តិសុខភាពនិងសេដ្ឋកិច្ចជាសកល ដែលបានធ្វើឱ្យកំណើនធ្លាក់ចុះដល់កម្រិតទាបបំផុតក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ។ វិស័យទេសចរណ៍បានទទួលរងផលប៉ះពាល់ខ្លាំងជាងគេ បន្ទាប់មកគឺវិស័យកម្មន្តសាល និងវិស័យសំណង់និងអចលនទ្រព្យ ខណៈដែលវិស័យកសិកម្មនិងធនាគារបានរួមចំណែកកាត់បន្ថយការធ្លាក់ចុះដ៏គំហុកនៃសេដ្ឋកិច្ច។ ទោះយ៉ាងណា កម្ពុជារក្សាបានស្ថិរភាពថ្លៃនិងអត្រាប្តូរប្រាក់ ដែលគាំទ្រដោយការអនុវត្តគោលនយោបាយរូបិយវត្ថុសមស្របនិងប្រុងប្រយ័ត្ន ហើយទុនបម្រុងអន្តរជាតិបន្តកើនឡើងជាលំដាប់ ដោយសារការបន្តទទួលបានអតិរេកជញ្ជីងទូទាត់ បើទោះជាវិនិយោគផ្ទាល់បរទេសមានកម្រិតទាបជាងប្រក្រតីក៏ដោយ។

ស្ថិរភាពហិរញ្ញវត្ថុបន្តរក្សាបានយ៉ាងរឹងមាំ ស្របនឹងការរីកចម្រើននៃវិស័យធនាគារ ដែលគាំទ្រដោយសុខភាពល្អប្រសើរនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ, ការពង្រឹងការត្រួតពិនិត្យនិងតាមដានហានិភ័យ និងការដាក់ចេញនូវវិធានការប្រុងប្រយ័ត្នសមស្របក្នុងប្រព័ន្ធធនាគារ។ ទន្ទឹមនេះ សន្ទនីយភាពក្នុងប្រព័ន្ធធនាគារបន្តស្ថិតក្នុងកម្រិតខ្ពស់ លទ្ធភាពទទួលបានប្រាក់ចំណេញមានកម្រិតសមស្រប ហើយសំពៀតឥណទានមានគុណភាពល្អ ដែលបន្តអនុញ្ញាតឱ្យប្រព័ន្ធធនាគារដើរតួនាទីសំខាន់ក្នុងការផ្តល់សេវាហិរញ្ញវត្ថុដល់វិស័យសេដ្ឋកិច្ច និងផ្តល់ការអនុគ្រោះដល់អតិថិជនដែលរងការប៉ះពាល់។ ឆ្លើយតបនឹងកំណើនតម្រូវការប្រើប្រាស់ប្រតិបត្តិការទូទាត់អេឡិចត្រូនិកឥតឈប់ឈរ ប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានអភិវឌ្ឍជាបន្តបន្ទាប់ ដែលបានបង្កលក្ខណៈងាយស្រួល និងពង្រឹងបានសុវត្ថិភាពដល់អ្នកប្រើប្រាស់។ ជាមួយគ្នានេះ ការជំរុញបរិយាបន្នហិរញ្ញវត្ថុ, ចំណេះដឹងផ្នែកហិរញ្ញវត្ថុ, កិច្ចការពារអ្នកប្រើប្រាស់, ការប្រើប្រាស់ប្រាក់រៀល និងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ក៏ត្រូវបានលើកកម្ពស់ ដែលបានពង្រឹងទំនុកចិត្តនិងប្រសិទ្ធភាពប្រព័ន្ធធនាគារកម្ពុជា។

ម្យ៉ាងទៀត កិច្ចសហប្រតិបត្តិការក្នុងតំបន់និងពិភពលោក បានរួមចំណែកក្នុងការពង្រឹងប្រសិទ្ធភាពការងារ ការផ្លាស់ប្តូរបទពិសោធន៍ និងការអភិវឌ្ឍសមត្ថភាពនិងជំនាញរបស់មន្ត្រីបុគ្គលិក ដែលជាអាទិភាពចម្បងមួយរបស់ធនាគារជាតិនៃកម្ពុជា។ លើសពីនេះ អភិបាលកិច្ចល្អ គុណវុឌ្ឍិមន្ត្រីបុគ្គលិក និងសេវាធនាគារកណ្តាលត្រូវបានបន្តពង្រឹង និងបានបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពការងាររបស់ធនាគារជាតិនៃកម្ពុជា។

# ផ្នែកទី២ - ទិសដៅការងារឆ្នាំ២០២១

## ទស្សនវិស័យនិងទិសដៅការងារឆ្នាំ២០២១

ជាមួយនឹងការចាប់ផ្តើមបើកដំណើរការឡើងវិញជាបណ្តើរៗនៃសកម្មភាពសេដ្ឋកិច្ចក្នុងបណ្តាប្រទេសជាច្រើនលើសកលលោក និងសុទិដ្ឋិនិយមចំពោះការផលិតវ៉ាក់សាំង កំណើនសេដ្ឋកិច្ចពិភពលោកឆ្នាំ២០២១ ត្រូវបានមូលនិធិរូបិយវត្ថុអន្តរជាតិរំពឹងថាងើបឡើងវិញដល់ ៥,២% ក្នុងនោះ សេដ្ឋកិច្ចសហរដ្ឋអាមេរិកមានកំណើន ៣,១% សហភាពអឺរ៉ុប ៥,២% ចក្រភពអង់គ្លេស ៥,៩% ចិន ៨,២% និងអាស៊ាន ៦,១%។ ទោះយ៉ាងណា សេដ្ឋកិច្ចពិភពលោកកំពុងស្ថិតក្នុងស្ថានភាពផុយស្រួយនៅឡើយ ដោយប្រឈមនឹងហានិភ័យចម្បងៗមួយចំនួន ដូចជា៖ i/-ការអូសបន្លាយនៃជំងឺកូវីដ-១៩ ii/-ការរឹតត្បិតឡើងវិញនៃស្ថានភាពហិរញ្ញវត្ថុ iii/-ការកើនឡើងនៃបំណុលសាធារណៈនិងឯកជន iv/-ភាពតានតឹងភូមិសាស្ត្រនយោបាយនិងកោលាហលសង្គម (social unrest) v/-ភាពមិនប្រាកដប្រជានៃគោលនយោបាយពាណិជ្ជកម្មជាមួយនឹងភាពតានតឹងបច្ចេកវិទ្យា និង vi/-គ្រោះមហន្តរាយធម្មជាតិដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

ការរំពឹងពីភាពប្រសើរឡើងនៃបរិយាកាសខាងក្រៅ គួបផ្សំនឹងការទទួលបានប្រព័ន្ធអនុគ្រោះពន្ធដូចជា ពីសហរដ្ឋអាមេរិក សហភាពអឺរ៉ុប និងថ្មីៗនេះពីចក្រភពអង់គ្លេស និងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) ជាដើម នឹងផ្តល់បច្ច័យវិជ្ជមានចំពោះការនាំចេញរបស់កម្ពុជា ស្របពេលដែលលំហូរវិនិយោគបរទេសរំពឹងមានស្ថានភាពល្អមកវិញ។ កត្តាទាំងនេះ នឹងជួយឱ្យវិស័យកម្មន្តសាលមានកំណើនវិជ្ជមានមកវិញ ក្នុងនោះ វិស័យកាត់ដេរអាចមានកំណើនក្នុងរង្វង់ ៥% ស្របពេលដែលវិស័យកម្មន្តសាលមិនមែនកាត់ដេរអាចនឹងកើនដល់ ១០%។ ភាពមិនប្រាកដ ប្រជាក្នុងការផលិតវ៉ាក់សាំងនិងការភ័យខ្លាចឆ្លងជំងឺកូវីដ-១៩ គួបផ្សំនឹងការធ្លាក់ចុះប្រាក់ចំណូល នឹងអាចបន្តដាក់សម្ពាធលើការធ្វើដំណើររបស់ភ្ញៀវទេសចរបរទេស ដែលធ្វើឱ្យការស្តារវិស័យទេសចរណ៍ឡើងវិញអាចនឹងត្រូវការពេលវេលាយូរដើម្បីត្រឡប់មកស្ថានភាពដើមមុនវិបត្តិ។ ក្នុងស្ថានភាពនេះ វិស័យទេសចរណ៍អាចនឹងមានកំណើនងើបឡើងវិញយឺតក្នុងរង្វង់ ២%។ អន្តរការិយកម្ម ហិរញ្ញវត្ថុបន្តមានតួនាទីគន្លឹះក្នុងការផ្តល់ហិរញ្ញប្បទានទ្រទ្រង់និងស្តារសកម្មភាពសេដ្ឋកិច្ច ដែលធ្វើឱ្យវិស័យហិរញ្ញវត្ថុរំពឹងថាមានកំណើនវិជ្ជមានក្នុងរង្វង់ ៥%។ ទន្ទឹមនឹងការនាំចេញទៅកាន់ទីផ្សារ អាស៊ាន សហរដ្ឋអាមេរិកនិងសហភាពអឺរ៉ុប ប្រទេសចិនបាននិងកំពុងក្លាយជាទីផ្សារដ៏សំខាន់មួយសម្រាប់ផលិតផលកសិកម្មរបស់កម្ពុជា ជាពិសេសក្រោយពីការសម្រេចបានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងប្រទេសទាំងពីរដែលនឹងគាំទ្រវិស័យកសិកម្មថែមទៀត។ កត្តានេះ គួបផ្សំនឹង ការអនុវត្តគោលនយោបាយគាំពារវិស័យកសិកម្មរបស់រាជរដ្ឋាភិបាលនឹងអាចជំរុញឱ្យវិស័យកសិកម្មបន្តងើបឡើងបន្តិចថែមទៀតក្នុងអត្រា ១,៦%។ ផ្អែកតាមគម្រោងសំណង់ដែលបានសុំការអនុញ្ញាតកន្លងមកនិងការរំពឹងនៃការងើបមកវិញនៃលំហូរវិនិយោគក្នុងវិស័យនេះ វិស័យសំណង់និងអចលនទ្រព្យរំពឹងថាមានកំណើនវិជ្ជមានមកវិញក្នុងអត្រា ៣%។ ក្នុងបរិការណ៍នេះ សេដ្ឋកិច្ចកម្ពុជា ត្រូវបានរំពឹងថាងើបមកវិញជាមួយនឹងអត្រាកំណើន ៣,៥%។

## តារាង ៤ ៖ ការព្យាករកំណើនសេដ្ឋកិច្ចកម្ពុជារបស់ស្ថាប័នអន្តរជាតិ

| | ឆ្នាំ២០២០ព | ឆ្នាំ២០២១ព |
|---|---|---|
| រាជរដ្ឋាភិបាល | -១,៩% | ៣,៥% |
| មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) | -២,៨% | ៦,៨% |
| ធនាគារពិភពលោក (WB) | -២.០% | ៤,៣% |
| ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) | -៤,០% | ៥,៩% |

## កត្តាអំណោយផលនិងហានិភ័យចំពោះកំណើនសេដ្ឋកិច្ចកម្ពុជា



**កត្តាអំណោយផល**

+ ការបន្តទទួលបានប្រព័ន្ធអនុគ្រោះពន្ធ
+ ការកើនឡើងវិញនៃការវិនិយោគក្នុងតំបន់
+ មានទីតាំងភូមិសាស្ត្រនៅចំកណ្តាលអាស៊ាន
+ ការកើនឡើងការវិនិយោគក្នុងវិស័យកសិឧស្សាហកម្ម
+ លទ្ធភាពខ្ពស់នៃវិស័យធនាគារក្នុងការឆ្លើយតបនឹងតម្រូវការហិរញ្ញប្បទានក្នុងពេលមានវិបត្តិ
+ សេដ្ឋកិច្ចមានភាពបើកទូលាយនិងសមាហរណកម្មខ្ពស់
+ ស្ថិរភាពនយោបាយ ម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
+ កត្តាភាគលាភប្រជាសាស្ត្រ

**ហានិភ័យនិងបញ្ហាប្រឈម**

- ការអូសបន្លាយនៃជំងឺកូវីដ-១៩
- កំណើនទាបជាងការរំពឹងទុកនៃសេដ្ឋកិច្ចពិភពលោក និងតំបន់
- ការកើនឡើងភាពប្រកួតប្រជែង និងនយោបាយគាំពារនិយម
- ភាពមិនច្បាស់លាស់នៃការប្រែប្រួលអាកាសធាតុ
- ការកើនឡើងបំណុលសាជីវកម្មនិងគ្រួសារ
- កំណើនយឺតនៃទេសចរអន្តរជាតិ
- ការថយចុះល្បឿនកំណើនវិស័យសំណង់ និងអចលនទ្រព្យ
- ពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចនៅមានល្បឿនយឺត
- ការប្រកួតប្រជែងរបស់កម្ពុជានៅមានកម្រិត

ទោះយ៉ាងណា សេដ្ឋកិច្ចកម្ពុជាក៏ប្រឈមនឹងហានិភ័យមួយចំនួនផងដែរ រួមមាន៖ i/-ការរីករាលដាលនៃជំងឺកូវីដ-១៩ ii/-ការកើនឡើងការប្រកួតប្រជែងនៅលើទីផ្សារអន្តរជាតិ ដោយសារប្រទេសមួយចំនួនដែលនាំចេញផលិតផលដូចកម្ពុជាទទួលបានការអនុគ្រោះពន្ធ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយប្រទេសដែលជាទីផ្សារនាំចេញរបស់កម្ពុជា iii/-ការធ្លាក់ចុះចំណូលដែលធ្វើឱ្យបំណុលរបស់សាជីវកម្មនិងក្រុមគ្រួសារកើនឡើង អាចនឹងមានសម្ពាធមកលើវិស័យហិរញ្ញវត្ថុ iv/-ការធ្លាក់ចុះខ្លាំងជាងការរំពឹងទុកនៃវិស័យសំណង់និងអចលនទ្រព្យ និង v/-ការប្រែប្រួលអាកាសធាតុដែលអាចបន្ថយកំណើនក្នុងវិស័យកសិកម្ម។ ទន្ទឹមនេះ បញ្ហាប្រឈមជារចនាសម្ព័ន្ធរបស់សេដ្ឋកិច្ចកម្ពុជា រួមមាន៖ i/-ភាពប្រកួតប្រជែងរបស់កម្ពុជានៅមានកម្រិត ដោយសារថ្លៃដើមផលិតកម្មខ្ពស់ និងកង្វះហេដ្ឋារចនាសម្ព័ន្ធ និង ii/-ការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចមានល្បឿនយឺតនៅឡើយ។

ដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការស្តារកំណើនសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានកំណត់ទិសដៅការងារសំខាន់ៗសម្រាប់ឆ្នាំ២០២១ មានដូចខាងក្រោមៈ

## ១- ការអនុវត្តគោលនយោបាយរូបិយវត្ថុ

- គ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុឱ្យស្ថិតក្នុងកម្រិតសមស្រប
- រក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដើម្បីរួមចំណែកស្ថិរភាពថ្លៃ និងជំនឿទុកចិត្តរបស់សាធារណជន
- លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលតាមយន្តការទីផ្សារ និង
- ជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារតាមរយៈការបង្កើតឧបករណ៍គោលនយោបាយរូបិយវត្ថុចាំបាច់ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ។

## ២- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

- អនុវត្តសេចក្តីណែនាំការវិនិយោគសម្រាប់ឆ្នាំ២០២១
- សិក្សាស្រាវជ្រាវលើឧបករណ៍វិនិយោគថ្មីៗ ដើម្បីសម្រេចបានពិពិធកម្មហានិភ័យនិងបង្កើនចំណូល
- សិក្សាស្រាវជ្រាវលើការរៀបចំថវិកាហានិភ័យ និងពង្រឹងការវាស់វែងសមិទ្ធផលសំពៀតវិនិយោគតាមរយៈការសិក្សាស្រាវជ្រាវលើម៉ូឌែលថ្មីៗ និង
- បន្តសិក្សាជាមួយដៃគូវិនិយោគ អំពីឱកាសនិងលទ្ធភាពវិនិយោគក្រោមក្របខ័ណ្ឌការវិនិយោគប្រកបដោយការទទួលខុសត្រូវ។

## ៣- ការអភិវឌ្ឍប្រព័ន្ធទូទាត់

- បន្តតាមដានការធ្វើសន្ទានកម្មរបស់គ្រឹះស្ថានសមាជិកប្រព័ន្ធខេមបូឌានស៊ែស្វីច និងប្រព័ន្ធរីថែលផេ ព្រមទាំងបន្តអភិវឌ្ឍប្រព័ន្ធទូទាត់ដុលភ្លាមៗ
- បន្តលើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធបាគង និងតាមដានការអនុវត្តស្តង់ដា QR Code
- រៀបចំបទប្បញ្ញត្តិបន្ថែមទៀត ព្រមទាំងបន្តត្រួតពិនិត្យនិងវាយតម្លៃសេវាទូទាត់សងប្រាក់ ឧបករណ៍ទូទាត់សងប្រាក់ និងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ និង
- រៀបចំផែនការនិរន្តរភាពសម្រាប់ប្រព័ន្ធទូទាត់។

## ៤- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

- ពង្រឹងការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមវិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យ និងទស្សនៈអនាគត
- បន្តតាមដាន និងជំរុញការអនុវត្ត CIFRS និង CIFRS សម្រាប់អង្គភាពធុនតូច និងមធ្យម
- បន្តតាមដានវឌ្ឍនភាពប្រតិបត្តិការរបស់ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ ខេមបូឌា ជាប្រចាំ
- បន្តទទួលនិងដោះស្រាយបណ្តឹងនិងសិក្សារៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិទាក់ទងនឹងកិច្ចការពារអតិថិជនវិស័យហិរញ្ញវត្ថុ និងការអនុវត្តតម្លាភាពទីផ្សារ (Regulatory Framework for Consumer Protection and Market Conduct)

- បន្តរៀបចំសិក្ខាសាលាផ្សព្វផ្សាយពាក់ព័ន្ធនឹងវិស័យធនាគារ វិស័យមីក្រូហិរញ្ញវត្ថុ និងកិច្ចគាំពារអតិថិជន
- បន្តតាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រជាតិស្ដីពីបរិយាបន្នហិរញ្ញវត្ថុ
- រៀបចំក្របខ័ណ្ឌសាធនភាព ប្រកាសស្ដីពីដើមទុនតាមបទប្បញ្ញត្តិ (មូលនិធិផ្ទាល់សុទ្ធ) ការរៀបចំគំរូរបាយការណ៍ថ្មី ការធ្វើ Simulation និងការបណ្ដុះបណ្ដាល
- សិក្សា និងរៀបចំកំណត់លក្ខខណ្ឌសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានគោលបំណងណែនាំអតិថិជន ឬធ្វើភ្នាក់ងារសម្រាប់ផលិតផល Bancassurance
- ពិនិត្យឡើងវិញ និងរៀបចំប្រកាសទាក់ទងនឹងអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ និងសេវាហាយភឺឆេស (Hire Purchase)
- សិក្សារៀបចំច្បាប់ស្ដីពី ការការពារប្រាក់បញ្ញើ (Law on Deposit Protection Scheme) និងច្បាប់ស្ដីពី ដំណោះស្រាយធនាគារ (Law on Bank Resolution)
- សហការអនុវត្តគម្រោងការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុដំណាក់កាលទី២ ជាមួយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ CUFA និងសហការជាមួយអង្គការ Good Return ផលិតខ្សែវីដេអូអប់រំ សម្រាប់គម្រោងយុទ្ធនាការផ្សព្វផ្សាយថ្មីដែលមានឈ្មោះថា "ការប្រើប្រាស់លុយដោយឆ្លាតវៃ" និង
- បន្តពង្រឹងសមត្ថភាពមន្ត្រីត្រួតពិនិត្យតាមរយៈការបណ្ដុះបណ្ដាលផ្ទៃក្នុង។

## ៥- ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

- ចេញសេចក្ដីណែនាំអំពីការអនុវត្តច្បាប់ស្ដីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មដល់បុគ្គលរាយការណ៍
- បន្តពង្រឹងសមត្ថភាពវិភាគប្រតិបត្តិការឱ្យបានកាន់តែប្រសើរ
- បន្តសម្របសម្រួលការអនុវត្តផែនការសកម្មភាពដែលកំណត់ក្នុងយុទ្ធសាស្ត្រជាតិ ស្ដីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៩-២០២៣
- បន្តរៀបចំ និងអនុវត្តឧបករណ៍ត្រួតពិនិត្យផ្អែកលើហានិភ័យសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ
- បន្តផ្សព្វផ្សាយនិងពង្រឹងការប្រតិបត្តិតាម និងគុណភាពនៃរបាយការណ៍របស់បុគ្គលរាយការណ៍ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន
- បន្តដឹកនាំនិងសម្របសម្រួលការអនុវត្តផែនការសកម្មភាពរបស់ក្រុមការងារ ICRG-JG របស់ FATF និង
- បន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូក្នុងស្រុកនិងអន្តរជាតិតាមរយៈការចុះអនុស្សរណៈយោគយល់ ក៏ដូចជាការផ្លាស់ប្ដូរព័ត៌មានឱ្យបានទាន់ពេលវេលា។ល។

## ៦- ការងារប្រតិបត្តិការ

- អនុវត្តការផ្តល់សន្ទនីយភាពចំពោះសមាជិកសភាផាត់ទាត់ជាតិ ដើម្បីធានាឱ្យសភាផាត់ទាត់ជាតិប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព
- អនុវត្តប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) តាមកាលវិភាគកំណត់
- អភិវឌ្ឍទីផ្សារអន្តរធនាគារ តាមរយៈការចូលរួមបង្កើតឧបករណ៍ហិរញ្ញវត្ថុក្នុងស្រុកថ្មីៗ និងលើកកម្ពស់តម្រូវការមូលបត្រអាចជួញដូរបាន និង
- ចូលរួមអភិវឌ្ឍប្រព័ន្ធទូទាត់ថ្មីៗទៀត។

## ៧- ការងារបោះផ្សាយនិងឃ្លាំងបេឡា

- បន្តពង្រឹងសេវាបង់និងបើកសាច់ប្រាក់នៅបញ្ជរធនាគារជាតិនៃកម្ពុជា
- បន្តពង្រឹងការងារដឹកជញ្ជូនធនបត្រ និងការរាប់ស្រាល់ជ្រើសក្រដាសប្រាក់
- បន្តលើកកម្ពស់ការងារគ្រប់គ្រងសាច់ប្រាក់ និងការថែរក្សាសុវត្ថិភាពឃ្លាំងប្រាក់ និង
- បន្តសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចទប់ស្កាត់ការចរាចរក្រដាសប្រាក់ក្លែងក្លាយ។

## ៨- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងគ្រប់គ្រងហានិភ័យ

- អនុវត្តការងារសវនកម្មស្របតាមផែនការសវនកម្មឆ្នាំ២០២១
- អនុវត្តការងារអធិការកិច្ចតាមផែនការដែលបានកំណត់ និងតាមការចាំបាច់
- បន្តពង្រឹងសមត្ថភាពសវនករ ដើម្បីបង្កើនគុណភាពសវនកម្មផ្ទៃក្នុង
- សិក្សាអំពីក្របខ័ណ្ឌនៃការគ្រប់គ្រងហានិភ័យ តាមម៉ូឌែលខ្សែការពារបី និង
- សិក្សាអំពីការធ្វើសវនកម្មពីចំងាយ (Remote Audit) និងសវនកម្មផ្អែកលើហានិភ័យ។

## ៩- ការគ្រប់គ្រងសាខា

- ចុះពង្រឹងប្រតិបត្តិការការងារនៅតាមសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ដើម្បីឱ្យស្របតាមការរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ចក្នុងខេត្តនីមួយៗ និង
- ពង្រឹងកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋានប្រចាំសាខារាជធានី-ខេត្ត សំដៅជំរុញការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយបន្ថែមទៀត។

## ១០- គណនេយ្យ

- ពិនិត្យ និងវាយតម្លៃ លើការអនុវត្តផែនការថវិការបស់ធនាគារជាតិនៃកម្ពុជាសម្រាប់ ឆ្នាំ២០២០ និងរៀបចំផែនការថវិកាសម្រាប់ឆ្នាំ២០២១
- បន្តសហការ និងពង្រឹងការងារគ្រប់គ្រងបញ្ជីទ្រព្យសម្បត្តិរបស់ធនាគារជាតិនៃកម្ពុជា
